រាជរដ្ឋាភិបាលកម្ពុជា

កម្មវិធីនយោបាយ

របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា
សម្រាប់ការកសាង និង ការការពារមាតុភូមិ ឆ្នាំ ២០២៣-២០២៨

ធ្វើនៅ រាជធានីភ្នំពេញ, ខែស្រាពណ៌ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
ត្រូវនឹង ខែសីហា គ្រិស្តសករាជ ២០២៣

ឯកសារសម្រាប់ដាក់ប្រជុំគណៈរដ្ឋមន្ត្រី
ថ្ងៃទី...24...ខែ...8...ឆ្នាំ...2023

កម្មវិធីនយោបាយ

របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា
សម្រាប់ ការកសាង និង ការការពារមាតុភូមិ ឆ្នាំ ២០២៣-២០២៨

ធ្វើនៅរាជធានីភ្នំពេញ ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
ត្រូវនឹងខែ សីហា គ្រិស្តសករាជ ២០២៣

សេចក្តីផ្តើម

ក្នុងគោលបំណង តម្កល់ខ្ពស់នូវឧត្តមគតិស្នេហាជាតិដ៏ថ្លៃថ្លា និង បរិសុទ្ធរបស់ខ្លួន; បន្តបំពេញបេសកកម្មជាប្រវត្តិសាស្ត្រក្នុងការបម្រើជាតិ មាតុភូមិ និង ប្រជាជន; និង ប្រែក្លាយកម្ពុជាឱ្យទៅជាទឹកដីដ៏ពិសិដ្ឋ ប្រកបដោយសុខសន្តិភាព និង វិបុលភាព, ជាសង្គមប្រកបដោយភាពសុខដុមរមនា, រួបរួមសាមគ្គីគ្នាជាធ្លុងមួយ, គ្មានការកើតឡើងជាថ្មីនូវសង្គ្រាម អំពើប្រល័យពូជសាសន៍ និង ការបែកបាក់ផ្ទៃក្នុងជាតិ, មានការអភិវឌ្ឍដ៏រស់-រវើក, មានជីវភាពកាន់តែប្រសើរឡើង ឆ្ពោះទៅកាន់ចក្ខុវិស័យប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ និង ជាប្រទេសមានចំណូលខ្ពស់ នៅឆ្នាំ ២០៥០ ព្រមទាំងក្លាយជាអារ្យប្រទេស ជឿនលឿនមួយ ក្នុងតំបន់ ជាមួយនឹងស្នាមញញឹម និង ក្តីសង្ឃឹមរបស់ប្រជាជន; រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា សូមប្រកាសកម្មវិធីនយោបាយរបស់ខ្លួន ដូចតទៅ៖

I. គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

ក្នុងស្មារតីប្រកាន់ខ្ជាប់ឥតប្រែប្រួលនូវគោលបំណង និង ឧត្តមគតិដ៏ថ្លៃថ្លារបស់ខ្លួន និង ផ្តើមចេញពីសំណូមពរនៃសភាពការណ៍ទូទៅបច្ចុប្បន្ន, រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាពុះពារសម្រេច ឱ្យបាននូវគោលដៅធំៗ ជាយុទ្ធសាស្ត្រ ដូចខាងក្រោម៖

១- ការពារសន្តិភាព, ការពារឯករាជ្យ, អធិបតេយ្យ, បូរណភាពទឹកដី និង ការពាររាល់សមិទ្ធផលនៃសង្គមជាតិ ឱ្យបានគង់វង្សស្ថិតស្ថេរ ។

២-កសាងព្រះរាជាណាចក្រកម្ពុជា ជារដ្ឋប្រជាធិបតេយ្យសេរី ពហុបក្ស ដ៏ជឿនលឿន និង រឹងមាំ ដែលផ្អែកលើច្បាប់, មានសេដ្ឋកិច្ចរីកចម្រើន ប្រកបដោយចីរភាព និង សមធម៌, ប្រជាជនមានជីវភាពសម្ព្ធ-សប្ផាយ រស់នៅយ៉ាងសុខដុមរមនា ប្រកបដោយកិត្តិយស, សេចក្តីថ្លៃថ្នូ និង មានការគោរពសិទ្ធិមនុស្ស ។

៣- កសាងប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាប័ន្ន, ប្រសិទ្ធភាព និង ចីរភាពហិរញ្ញវត្ថុ ដែលធានាការផ្តល់ការគាំពារដល់ប្រជាជន ក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ច, ហានិភ័យសុខភាពសាធារណៈ និង ភាពងាយរងគ្រោះផ្សេងៗ ដែលកើតឡើងពីការប្រែប្រួលលក្ខខណ្ឌនៃការងារ និង ការរស់នៅ ។

៤- ជំរុញការអនុវត្ត "**កម្ពុជាគ្មានមីនត្រឹមឆ្នាំ ២០២៥**" និង កាត់បន្ថយគ្រាប់មិនទាន់ផ្ទុះឱ្យបានជាអតិ-បរមា ។

៥- បន្តអនុវត្តនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់, កសាងមិត្តភាព និង កិច្ចសហ-ប្រតិបត្តិការល្អប្រសើរ រវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសទាំងអស់ នៅលើសកលលោក និង អង្គការអន្តរជាតិនានា ហើយចូលរួមយ៉ាងសកម្ម ចំពោះបុព្វហេតុសន្តិភាព, ស្ថិរភាព, សន្តិសុខ និង វិបុលភាព ក្នុងតំបន់ និង ពិភពលោក ។

II. គោលនយោបាយធំៗ ជាអាទិភាព

ដើម្បីសម្រេចគោលដៅជាយុទ្ធសាស្ត្រខាងលើនេះ, រាជរដ្ឋាភិបាលកំណត់បណ្តាគោលនយោបាយធំៗ ជាអាទិភាព ដូចខាងក្រោម៖

១. ការពារសន្តិភាព, ស្ថិរភាពនយោបាយ និង រាល់សមិទ្ធផលសង្គមជាតិឱ្យរឹងមាំស្ថិតស្ថេរគង់វង្ស

១. បន្តជ្រោងខ្ពស់ទង់មហាសាមគ្គីជាតិ នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងក្រោមម្លប់ដ៏ត្រជាក់នៃ **អង្គព្រះមហាក្សត្រជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សំដៅបង្រួបបង្រួម ប្រមូលកម្លាំងប្រជាជាតិខ្មែរទាំងមូល ដោយឥតប្រកាន់ពូជសាសន៍, ពណ៌សម្បុរ, ភេទ, ភាសា, ជំនឿសាសនា, និន្នាការនយោបាយអតីតកាល, ដើមកំណើតជាតិ, ឋានៈសង្គម, ធនធាន ឬ ស្ថានភាពឯទៀត ដើម្បីថែរក្សាសន្តិភាព, ស្ថិរភាពនយោបាយ និង រាល់សមិទ្ធផលសង្គមជាតិ និង បន្តរួមសាមគ្គីគ្នាកសាង និង ការពារមាតុភូមិ ឆ្ពោះទៅរកអនាគតដ៏រុងរឿង ។

២. ពង្រឹងការឯកភាពជាតិ សំដៅទប់ស្កាត់ និង កម្ចាត់គ្រប់ទម្រង់នៃនយោបាយ និង សកម្មភាពជ្រុលនិយម បង្កឡើងដោយបុគ្គល, ក្រុមពួក ឬ អង្គការចាត់តាំងនយោបាយណាមួយ ឬ មជ្ឈដ្ឋានអមិត្តផ្សេងៗ ដែលព្យាយាមញុះញង់បង្ការបែកបាក់ជាតិ, បង្កើតភាពវឹកវរសង្គម, បំផ្លាញស្ថិរភាពនយោបាយ ដើម្បីសម្រេចឧបាយកលទុច្ចរិតរបស់ពួកគេ ក្នុងការប៉ុនប៉ងផ្លាស់ប្តូររបបនយោបាយនៅកម្ពុជាតាមបែបឧក្រិដ្ឋ ដែលផ្ទុយទាំងស្រុងពីគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និង រំលោភបំពានលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ បុគ្គល ឬ អង្គការចាត់តាំងណា ដែលបានប្រព្រឹត្តសកម្មភាពជ្រុលនិយមបែបនេះ ត្រូវតែទទួលការផ្តន្ទាទោសយ៉ាងម៉ឺងម៉ាត់តាមច្បាប់ជាធរមាន ដើម្បីទប់ស្កាត់មិនឱ្យមានការបែកបាក់ជាតិ និង សង្គ្រាម សាជាថ្មីទៀត ។

៣. បន្តលើកកម្ពស់ស្មារតីថែរក្សាសន្តិភាព តាមរយៈ ការរៀបចំពិធីជួបជុំនៅថ្ងៃទី ២៩ ខែ ធ្នូ ជារៀង-រាល់ឆ្នាំ ដើម្បីរំឭកខួបនៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា តាមរយៈ «**នយោបាយឈ្នះ-ឈ្នះ**» និង ការកសាងវិមានឈ្នះ-ឈ្នះ; ការបន្តកសាងស្តូបអនុស្សាវរីយ៍នៃនយោបាយឈ្នះ-ឈ្នះ នៅតាមតំបន់មួយចំនួន ដោយផ្សារភ្ជាប់នឹងប្រវត្តិសាស្ត្រជាក់ស្តែង; ការរំឭកអំពីនយោបាយឈ្នះ-ឈ្នះ តាមរយៈ ការបោះពុម្ព, ផលិតឯកសារ និង រូបភាពផ្សេងៗ; ការបង្កើនការអប់រំសិស្ស-និស្សិត, យុវជន, មន្ត្រីរាជការ, កងកម្លាំងប្រដាប់អាវុធ និង គ្រប់ស្រទាប់ប្រជាជនផ្សេងៗទៀត ឱ្យយល់ច្បាស់អំពីប្រវត្តិនៃការកសាងសន្តិភាព, គុណតម្លៃនៃសន្តិភាព, កាតព្វកិច្ចការពារសន្តិភាព និង រាល់សមិទ្ធផលនៃសង្គមជាតិ ។

២. លើកកម្ពស់ជីវភាពប្រជាជនគ្រប់រូប, ទាំងខាងសម្ភារៈ និង ស្មារតី ឱ្យបានសមរម្យប្រកបដោយភាពថ្លៃថ្នូរ

១. បន្តចាត់ទុកការលុបបំបាត់ភាពក្រីក្ររបស់ប្រជាជន ជាគោលនយោបាយអាទិភាពមួយ ដែលត្រូវប្រមូលកម្លាំង, ទាំងផ្នែករដ្ឋ, ទាំងផ្នែកឯកជន, ក៏ដូចសង្គមជាតិទាំងមូល, ដើម្បីពុះពារអនុវត្តឱ្យបានលទ្ធផលល្អប្រសើរ សំដៅធានាសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្រ តាមដំណាក់កាលនីមួយៗ និង ការពារប្រជាជន ដែលបានឆ្លងផុតបន្ទាត់នៃភាពក្រីក្រហើយ មិនឱ្យត្រឡប់មកស្ថានភាពក្រីក្រវិញ ។

២. បន្តជំរុញការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ឆ្នាំ ២០២៤-២០២៨ ប្រកបដោយភាព-ប្រាកដនិយម និង ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍដោយចីរភាពឆ្នាំ ២០៣០ និង ធានាមិនទុកឱ្យប្រជាជនណាម្នាក់ស្ថិតនៅក្រៅដំណើរការអភិវឌ្ឍ ដោយឈរលើគោលការណ៍ គ្មានប្រជាជនណាម្នាក់ដែលជួបទុក្ខលំបាក គ្មាន

លទ្ធភាពដោះស្រាយ តែរដ្ឋាភិបាលមិនបានជួយដោះស្រាយនោះឡើយ ។

៣. បន្តអភិវឌ្ឍ និង ពង្រឹងប្រព័ន្ធគាំពារសង្គម ប្រកបដោយបរិយាប័ន្ន, ប្រសិទ្ធភាព និង ចីរភាពហិរញ្ញ-វត្ថុ, មានវិសាលភាពគ្របដណ្ដប់សង្គមទាំងមូល ដើម្បីពង្រឹងសមត្ថភាពរបស់សមាជិកគ្រប់រូបក្នុងសង្គម ក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ច និង ដើម្បីកាត់បន្ថយភាពក្រីក្រ និង ភាពងាយរងគ្រោះនានា ហើយរួម-ចំណែកដល់ការគាំពារ និង អភិវឌ្ឍធនធានមនុស្ស កាន់តែទូលំទូលាយ ។ ពង្រឹងការត្រៀមលក្ខណៈសម្រាប់ជួយសង្គ្រោះប្រជាជន ដែលត្រូវជួបគ្រោះមហន្តរាយផ្សេងៗ ដូចជា គ្រោះទឹកជំនន់, គ្រោះរាំងស្ងួត ជាដើម ។

៣. ការពាររបបរាជានិយម លើកស្ទួយលទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាពប្រជាជន និង ពង្រឹងនីតិរដ្ឋ

១. ការពារ និង ប្រកាន់ខ្ជាប់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ តាមប្រព័ន្ធនយោបាយប្រជាធិប-តេយ្យសេរី ពហុបក្សបែបសភានិយម ឱ្យស្ថិតស្ថេរជានិរន្តរ៍ និង ស្របតាមឆន្ទៈរបស់ប្រជាជនកម្ពុជា ដែលមានស្វាមីភក្តិ, គោរពតម្កល់ខ្ពស់ **អង្គព្រះមហាក្សត្រជាទីសក្ការៈ** ដើម្បីព្រះអង្គទ្រង់គង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំនៃប្រជាជាតិខ្មែរទាំងមូល និង ដើម្បីការពារឯករាជ្យជាតិ, អធិបតេយ្យ និង បូរណភាពទឹកដីនៃព្រះ-រាជាណាចក្រកម្ពុជា និង ធានាការគោរពសិទ្ធិ និង សេរីភាពរបស់ប្រជាជន ។ ជ្ពាលទោស និង ប្រឆាំងដាច់ខាតរាល់ទង្វើ និង សកម្មភាពគ្រប់បែបយ៉ាងដែលប៉ះពាល់ ឬ បំពានលើអង្គព្រះមហាក្សត្រជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

២. បន្តពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ឱ្យចាក់គ្រឹះកាន់តែរឹងមាំ ពីថ្នាក់ជាតិរហូតដល់មូលដ្ឋាន ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាជនក្នុងការកសាង និង ការពារមាតុភូមិ ប្រកបដោយភាពជា-ម្ចាស់លើជោគវាសនាអនាគតប្រទេសជាតិ ។ ការពារ និង លើកស្ទួយសិទ្ធិសេរីភាពរបស់ប្រជាជន ក្នុងការចូលរួមសកម្មភាពនយោបាយនានា ស្របតាមគោលការណ៍ប្រជាធិបតេយ្យ និង នីតិរដ្ឋ ដូចជា ការបង្កើត, ការជ្រើសរើស, ការគាំទ្រ និង ការចូលរួមក្នុងគណបក្សនយោបាយ ជាដើម ។ ការពារ និង គាំទ្រយ៉ាងមុឹងម៉ាត់ចំពោះដំណើរការរៀបចំការបោះឆ្នោត, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុ-បក្ស, ទាំងលក្ខណៈជាសកល និង អសកល, ឱ្យបានទៀងទាត់តាមអាណត្តិ ដែលកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ ប្រកបដោយលក្ខណៈសេរី, ត្រឹមត្រូវ, យុត្តិធម៌ និង មានសុវត្ថិភាព ។

៣. ការពារ និង លើកស្ទួយសិទ្ធិសេរីភាពគ្រប់បែបយ៉ាងរបស់ប្រជាជន ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ, សេចក្ដីថ្លែងការណ៍របស់អង្គការសហប្រជាជាតិ, កតិកាសញ្ញា, សន្ធិសញ្ញា និង អនុសញ្ញាអន្តរជាតិទាំងឡាយ ទាក់-ទងទៅនឹងសិទ្ធិមនុស្ស, សិទ្ធិនារី និង សិទ្ធិកុមារ ។ បន្តលើកកម្ពស់ការទទួលខុសត្រូវខាងផ្លូវច្បាប់ ក្នុងការគោរព និង ការផ្ដល់តម្លៃដល់ជីវិតមនុស្ស និង សិទ្ធិសេរីភាពបុគ្គល ដោយប្ដេជ្ញាការពារនូវសិទ្ធិរស់រានមានជីវិត និង សិទ្ធិចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ, សេដ្ឋកិច្ច, សង្គមកិច្ច និង វប្ប្ធម៌ របស់ប្រទេសជាតិ ។ ទន្ទឹមនេះ, បន្តពង្រឹង និង ជំរុញការបំពេញករណីយកិច្ច និង កាតព្វកិច្ចនានារបស់ប្រជាជនគ្រប់រូប ក្នុងសង្គមឱ្យមានការគោរពច្បាប់, សីលធម៌, សុជីវធម៌, សេចក្ដីថ្លៃថ្នូរ ព្រមទាំងធានាការពារមិនឱ្យមានការបំពានសិទ្ធិសេរីភាព និង ការប្រើ-ប្រាស់សិទ្ធិសេរីភាព ប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃ និង ប៉ះពាល់ដល់សន្តិសុខ និង សណ្ដាប់ធ្នាប់សាធារណៈ ។

៤. ការពារ និង លើកកម្ពស់នីតិរដ្ឋ តាមរយៈ ការពង្រឹងការបែងចែកអំណាច តាមគោលការណ៍ប្រជាធិបតេយ្យបែបសភានិយម, ការពង្រឹងប្រព័ន្ធយុត្តិធម៌, ការលើកកម្ពស់ការយល់ដឹងអំពីច្បាប់, ការគោរពច្បាប់ និង ការអនុវត្តច្បាប់ដោយត្រឹមត្រូវ និង ស្មើភាពគ្នា ព្រមទាំងការទប់ស្កាត់រាល់ទម្រង់នៃការប្រើប្រាស់សិទ្ធិ

អំណាចដោយបំពាន និង ទប់ស្កាត់និទ្ធណ្ហភាព និង អំពើហិង្សាគ្រប់រូបភាព ។

៤. ពង្រឹងរដ្ឋបាលសាធារណៈនៅគ្រប់ថ្នាក់ ជារដ្ឋបាលប្រជាជន និង បម្រើផលប្រយោជន៍ប្រជាជន

១. រៀបចំ, ពង្រឹង និង កែលម្អ រចនាសម្ព័ន្ធ, ប្រព័ន្ធគ្រប់គ្រងការងារ និង ការបែងចែកមុខងារ, តួនាទី និង ការទទួលខុសត្រូវរបស់ស្ថាប័នសាធារណៈនីមួយៗ ឱ្យបានច្បាស់លាស់ ក្នុងការរៀបចំគោលនយោបាយ, យុទ្ធសាស្ត្រ, ស្តង់ដាជាតិ, ការតាមដានត្រួតពិនិត្យ, អធិការកិច្ច, ការផ្តល់ការគាំទ្រ និង អន្តរាគមន៍ និង ការទទួល-ខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ សំដៅបង្ហិតសេវាសាធារណៈឱ្យទៅកៀកជិតជាមួយប្រជាជនដើម្បីឆ្លើយតបទៅនឹងតម្រូវការ, សំណូមពរ និង ដោះស្រាយបញ្ហាប្រឈមនានា របស់ប្រជាជន ប្រកបដោយប្រសិទ្ធភាព, រហ័ស និង ចំគោលដៅនៃតម្រូវការ នៅតាមមូលដ្ឋាននីមួយៗ ។

២. បន្តពង្រឹង និង លើកកម្ពស់សមត្ថភាពស្ថាប័នសាធារណៈនៅគ្រប់ថ្នាក់ តាមរយៈ ១). ការពង្រឹងសមត្ថភាពមន្ត្រីសាធារណៈ ប្រកបដោយជំនាញវិជ្ជាជីវៈ, នវានុវត្តន៍ និង ក្រមសីលធម៌; ២). ការផ្តល់ធនធានហិរញ្ញវត្ថុ, មធ្យោបាយ, ឧបករណ៍, សម្ភារៈ និង ធនធានមនុស្ស ឱ្យបានសមស្រប ដល់ស្ថាប័នសាធារណៈនីមួយៗ; និង ៣). ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងការងារ, ការប្រាស្រ័យទាក់ទង និង ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ប្រកបដោយគណនេយ្យភាព, គុណភាព, តម្លាភាព, រហ័ស និង ភាពជឿទុកចិត្ត ។

៣. ពង្រឹងសិទ្ធិអំណាច, សមត្ថភាព និង ការទទួលខុសត្រូវ របស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ក្នុងការដឹកនាំ, ការធ្វើសេចក្តីសម្រេចចិត្តលើការផ្តល់សេវា និង ការអភិវឌ្ឍមូលដ្ឋាន ឱ្យកាន់តែមានប្រសិទ្ធភាព, គណនេយ្យភាព, បរិយាប័ន្ន, យុត្តិធម៌ និង សមធម៌សង្គម ដើម្បីធ្វើជាតំណាងឱ្យផលប្រយោជន៍ និង សំឡេងរបស់ប្រជាជន ។

៤. លើកកម្ពស់តួនាទី, សិទ្ធិអំណាច និង ការទទួលខុសត្រូវរបស់ស្ត្រី, យុវជន, ជនមានពិការភាពក្នុងវិស័យសាធារណៈ, រួមទាំងការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីជាស្ត្រី, យុវជន និង ជនមានពិការភាព ដើម្បីទទួលបានមុខតំណែងគ្រប់គ្រងនានា នៅក្នុងស្ថាប័នសាធារណៈ សំដៅធានាការបង្កើនការចូលរួមរបស់ស្ត្រី, យុវជន និង ជនមានពិការភាព ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ប្រកបដោយបរិយាប័ន្ន និង សមធម៌សង្គម ។

៥. លើកកម្ពស់សិទ្ធិអំណាច និង ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការធ្វើសេចក្តីសម្រេចចិត្តនានាពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និង ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈ ការរៀបចំ, ការពង្រឹង និង ការកែលម្អយន្តការនៃការផ្តល់ព័ត៌មាន, ការចូលរួម និង ការតាមដានត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និង យន្តការទទួលដោះស្រាយបណ្តឹងតវ៉ា, សំណូមពរនានា និង ការទទួលយោបល់ត្រឡប់របស់ប្រជាពលរដ្ឋ ដោយមិនមានការរើសអើង និង មិនប្រកាន់និន្នាការនយោបាយ ។

៦. លើកកម្ពស់ និង ពង្រឹង ភាពជាដៃគូរវាងរដ្ឋបាលសាធារណៈជាមួយនឹងអង្គការសង្គមស៊ីវិល និង វិស័យឯកជន ក្នុងការកៀរគរធនធាន និង រួមចំណែកដល់ការផ្តល់សេវាសាធារណៈ និង ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ។

៧. ពង្រឹងភាពស្អាតស្អំ និង ភាតព្វកិច្ចទទួលខុសត្រូវរបស់រដ្ឋបាលគ្រប់ថ្នាក់ តាមរយៈ ១). ការរៀបចំ និង ការពង្រឹងយន្តការគ្រប់គ្រង និង ផ្តល់សេវាសាធារណៈប្រកបដោយលក្ខណៈទំនើប និង តម្លាភាព; ២). ការ-បង្កើនបៀវត្ស និង ប្រាក់សោធននិវត្តន៍ និង ការផ្តល់ការលើកទឹកចិត្តនានា, ទាំងផ្នែកហិរញ្ញវត្ថុ និង មិនមែន

ហិរញ្ញវត្ថុ, ដល់មន្ត្រីសាធារណៈដែលបំពេញការងារបានល្អ; និង ៣). ការចាត់វិធានការយ៉ាងម៉ឹងម៉ាត់តាមច្បាប់ ក្នុងការដាក់ទណ្ឌកម្មវិន័យ និង វិធានការច្បាប់ ចំពោះមន្ត្រីសាធារណៈ ដែលប្រព្រឹត្តអំពើពុករលួយ, បំពានក្រមសីលធម៌វិជ្ជាជីវៈ ឬ បំពានអំណាច ក្នុងការអនុវត្តតួនាទី និង ការកិច្ចរបស់ខ្លួន ។

៥. បន្តជំរុញការកែទម្រង់ដើម្បីអភិបាលកិច្ចល្អ

១. បន្តកិច្ចការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីកសាងឱ្យបាននូវរដ្ឋបាលសាធារណៈមានសមត្ថ-ភាព, ខ្លាំង, ស្អាតស្អំ, រៀឆ្លាត និង ផ្តោតលើប្រជាជន តាមរយៈ ការកែទម្រង់ និង ការពង្រឹងប្រសិទ្ធភាពស្ថាប័ន, ការលើកកម្ពស់ប្រសិទ្ធភាពនៃសមិទ្ធកម្មស្ថាប័នសាធារណៈ និង គណនេយ្យភាពសមិទ្ធកម្មសាធារណៈ សំដៅធានាការផ្តល់សេវាសាធារណៈ និង ការអភិវឌ្ឍសង្គមប្រកបដោយសមធម៌, យុត្តិធម៌ និង បរិយាប័ន្ន ដោយផ្តោតលើការជំរុញនវានុវត្តន៍ និង ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មានក្នុងរដ្ឋបាលសាធារណៈ និង ការជំរុញការដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម, ការរៀបចំយន្តការគណនេយ្យភាពរបស់ស្ថាប័នសាធារណៈចំពោះប្រជាជន និង ការចូលរួមវាយតម្លៃរបស់ប្រជាជន ក្នុងដំណើរការនៃការផ្តល់សេវាសាធារណៈ ។

២. បន្តកិច្ចការកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីលើកកម្ពស់សិទ្ធិអំណាច និង ការចូលរួមរបស់ប្រជាពលរដ្ឋ ព្រមទាំងដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និង ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយគុណភាព, តម្លាភាព, គណនេយ្យភាព, បរិយាប័ន្ន, សមធម៌ និង យុត្តិធម៌សង្គម តាមរយៈ ការបន្តផ្ទេរសិទ្ធិអំណាចមុខងារ, ធនធាន និង ការទទួលខុសត្រូវ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ, ការរៀបចំកែលម្អរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងការងារ ក៏ដូចជា ការអភិវឌ្ឍសមត្ថភាពស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ, ការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិ និង ការកែលម្អដំណើរការផ្តល់សេវាសាធារណៈ និង គុណភាពសេវាសាធារណៈ ។

៣. លើកកម្ពស់គុណភាព, សមត្ថភាព និង ផ្តល់ការគាំទ្រនានា ដល់មន្ត្រីបង្គោលសំខាន់ៗ នៅមូលដ្ឋាន រួមមាន មេឃុំ, ចៅសង្កាត់, ស្មៀនឃុំ-សង្កាត់, ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ, សង្កាត់, មន្ត្រីសុខាភិបាលបម្រើការនៅតាមប៉ុស្តិ៍សុខភាព, មណ្ឌលសុខភាព, មន្ទីរពេទ្យបង្អែក និង គ្រូបង្រៀនសាលាចំណេះដឹងទូទៅរបស់រដ្ឋ គ្រប់កម្រិតនៅមូលដ្ឋាន ដើម្បីបម្រើសំណូមពរ, សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ប្រកបដោយតម្លាភាព និងគណនេយ្យភាព ។

៤. បន្តជំរុញការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើលទ្ធផល (ឬ សមិទ្ធកម្ម) និង វិមជ្ឈការ ស្របតាមស្តង់ដា និង ឧត្តមានុវត្តន៍អន្តរជាតិ តាមរយៈ ការបង្កើតនូវភាពជឿទុកចិត្តនៃថវិកា, គណនេយ្យភាពហិរញ្ញវត្ថុ, ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង គណនេយ្យភាពសមិទ្ធកម្ម សំដៅធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រមូលចំណូល ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពចំណាយសាធារណៈ ។

៥. បន្តជំរុញការកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដើម្បីទទួលបានយុត្តិធម៌សម្រាប់ទាំងអស់គ្នា តាមរយៈ ការលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃសេវាយុត្តិធម៌ និង សិទ្ធិទទួលបានយុត្តិធម៌របស់ពលរដ្ឋគ្រប់រូប ដោយផ្តោតលើការពង្រឹងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ, ការពង្រឹងភាពស្អាតស្អំ, ក្រមសីលធម៌ និង ការអប់រំ បណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់, ការពង្រឹងយន្តការវិន័យការងារ, ការធ្វើទំនើបកម្មរដ្ឋបាលយុត្តិធម៌, ការលើកកម្ពស់ការផ្តល់សេវាច្បាប់ និង ការពង្រឹងនិងកែលម្អយន្តការដោះស្រាយវិវាទ ដែលអាចឆ្លើយតបបានទៅ

នឹងស្ថានភាពជាក់ស្តែងរបស់សង្គម ប្រកបដោយប្រសិទ្ធភាព ។

៦. បន្តជំរុញការកែទម្រង់វិស័យអាទិភាពផ្សេងទៀត ដូចជា ការកែទម្រង់វិស័យអប់រំ, ការកែទម្រង់វិស័យសុខាភិបាល, ការកែទម្រង់ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន និង ការកែទម្រង់ការគ្រប់គ្រងដីធ្លី ជា-ដើម ដើម្បីលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និង លើកកម្ពស់ជីវភាពប្រជាជន ។

៧. ពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ ដោយឆន្ទៈមុតស្រួច និង ការប្តេជ្ញាខ្ពស់ តាមរយៈ ការលើកកម្ពស់ការអនុវត្តវិធានការស្នូលទាំង ៣ គឺ ការអប់រំ, ការបង្ការទប់ស្កាត់ និង ការអនុវត្តច្បាប់ប្រឆាំងអំពើ-ពុករលួយ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់, លើកស្ទួយភាពស្អាតស្អំ ក្នុងរដ្ឋបាលសាធារណៈ និង វិស័យឯកជន, លើកកម្ពស់អភិបាលកិច្ច និង ការត្រួតពិនិត្យផ្ទៃក្នុង និង ចូលរួមជាមួយសហគមន៍អន្តរជាតិលើការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ និង ប្រឆាំងការសម្អាតប្រាក់ ។

III. គោលនយោបាយអភិវឌ្ឍតាមវិស័យ

ក្នុងផ្នែកនេះ, រាជរដ្ឋាភិបាលបន្តផ្តោតការយកចិត្តទុកដាក់លើគោលនយោបាយជាអាទិភាព ដូចតទៅ៖

១. ការគ្រប់គ្រងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ

បន្តធានាស្ថិរភាពសេដ្ឋកិច្ច និង ជំរុញកំណើនសេដ្ឋកិច្ចខ្ពស់

១. បន្តពង្រឹងយន្តការគ្រប់គ្រងហានិភ័យ និង វិបត្តិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងកិច្ចអន្តរាគមន៍ក្នុងសេដ្ឋកិច្ច និង ពង្រឹងគោលនយោបាយរូបិយវត្ថុ ដើម្បីរក្សាអត្រាអតិផរណា ឱ្យស្ថិតក្នុងកម្រិតទាប និង អត្រាប្តូរប្រាក់មានស្ថិរភាព ដែលអាចគ្រប់គ្រងបាន ។

២. បន្តពង្រឹងប្រព័ន្ធហិរញ្ញវត្ថុឯកជន ឬវិស័យហិរញ្ញវត្ថុ តាមរយៈ យន្តការនិយ័តកម្ម និង ប្រព័ន្ធសុវត្ថិ-ភាពហិរញ្ញវត្ថុ ដើម្បីធានាភាពរឹងមាំ និង ភាពធន់ទៅនឹងវិបត្តិ នាអនាគត ។

៣. ធានាស្ថិរភាពហិរញ្ញវត្ថុ តាមរយៈ ការគ្រប់គ្រងកំណើនឥណទាន ដែលមានលក្ខណៈសមស្រប សម្រាប់គាំទ្រកំណើនសេដ្ឋកិច្ច ព្រមទាំងការអភិវឌ្ឍក្របខ័ណ្ឌគ្រប់គ្រងវិបត្តិពេញលេញ និង ការឃ្លាំមើលវិស័យហិរញ្ញវត្ថុ ឱ្យបានជិតដល់ និង ជាប្រចាំ ។

៤. ពង្រឹងការគ្រប់គ្រងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដូចជា អចលនវត្ថុបញ្ចាំ និង ប្រាតិភោគ ដោយអនុប្បទាន, ធានារ៉ាប់រង និង ទីផ្សារមូលបត្រ ជាដើម ឱ្យមានការរីកចម្រើនប្រកបដោយភាពធន់រឹងមាំ ដើម្បីចូលរួមចំណែកជាវិជ្ជមានដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ក៏ដូចជា ដល់ការលើកកម្ពស់ការប្រើប្រាស់ និង ការវិនិយោគ ។

៥. បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ ព្រមទាំងសមត្ថភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុ ឱ្យកាន់តែមានពិពិធភាព, រឹងមាំធន់នឹងវិបត្តិ និង ប្រកបដោយបរិយាប័ន្ន សំដៅគាំទ្រសកម្មភាពសេដ្ឋកិច្ចទាំងមូល ព្រមទាំងធ្វើការសម្របខ្លួន ដើម្បីឆ្លើយតប និង ទាញប្រយោជន៍ ឱ្យបានជាអតិបរមា ពីការ-ផ្លាស់ប្តូរចរន្តនៃសមាហរណកម្មសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងតំបន់ និង ជាសកល ។

៦. បន្តជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច តាមរយៈ ការពង្រឹងក្បាលម៉ាស៊ីនកំណើន ដែលមានស្រាប់ ក្នុងវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម, ទេសចរណ៍, កាត់ដេរ និង កម្មន្តសាលមិនមែនកាត់ដេរ; បង្កើតកត្តាជំរុញកំណើនថ្មី ដែលផ្អែកលើផលិតភាព, បច្ចេកវិទ្យា និង នវានុវត្តន៍ ព្រមទាំងបន្តស្តារ និង ពង្រឹងមូលដ្ឋាន អភិវឌ្ឍសង្គម- សេដ្ឋកិច្ចឱ្យកាន់តែរឹងមាំ ស្របតាម **"ក្របខ័ណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣"** និង គោលនយោ-បាយពាក់ព័ន្ធ ។

៧. ជំរុញការអនុវត្តគោលនយោបាយសំខាន់ៗ រួមមាន គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥, ក្របខ័ណ្ឌគោលនយោបាយសង្គម-សេដ្ឋកិច្ចឌីជីថលកម្ពុជា ឆ្នាំ ២០២១-២០៣៥, ក្របខ័ណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ឆ្នាំ ២០២២-២០៣៥ និង គោលនយោបាយជាតិប្រសិទ្ធភាពថាមពល ឆ្នាំ ២០២២-២០៣០ ជាដើម ។

៨. បន្តគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម រួមទាំងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈ ច្បាប់ស្តីពីវិនិយោគថ្មី និង ភាពប្រទាក់ក្រឡា ក្នុងការរៀបចំច្បាប់ស្តីពីសារពើពន្ធថ្មី ព្រមទាំងការដាក់ចេញវិធាន-ការលើកទឹកចិត្តជាក់លាក់ ដើម្បីកែលម្អបរិយាកាសធុរកិច្ចសម្រាប់សហគ្រាសធុនតូច និង មធ្យម, ព្រមទាំង

រៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រអភិវឌ្ឍវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជំរុញបន្ថែមការអភិវឌ្ឍ វិស័យកសិ-ឧស្សាហកម្ម, ទេសចរណ៍, សហគ្រាសធុនតូច និង មធ្យម តាមរយៈ ធនាគារសហគ្រាសធុន តូច និង មធ្យម, ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម, ក្រុមហ៊ុនសាជីវកម្មធានាឥណទានកម្ពុជា, មូលនិធិអភិវឌ្ឍសហគ្រិន និង មូលនិធិអភិវឌ្ឍជំនាញ ជាដើម ។

៩. ជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ការអភិវឌ្ឍបៃតង, ព្រមទាំងលើកកម្ពស់ឥណទានបៃតង សំដៅតភ្ជាប់ក្នុងសេដ្ឋកិច្ច និង គាំទ្រការធ្វើបរិវត្តកម្មឌីជីថល និង ការអភិវឌ្ឍ ប្រកបដោយចីរភាព ។

១០. ជំរុញការវិនិយោគសាធារណៈដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ និង បង្កើនហិរញ្ញ-ប្បទានចីរភាព ដើម្បីលើកកម្ពស់ឱ្យបានដល់កម្រិតអតិបរមា, ទាំងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង ការថែរក្សាបរិស្ថាន ព្រមទាំងបង្កើនភាពធន់ទៅនឹងអាកាសធាតុ ។

រក្សាចីរភាពថវិកា

១. បន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្ពោះទៅរកកម្រិតស្តង់ដាអន្តរជាតិ តាមរយៈ ការកែទម្រង់ការគ្រប់គ្រងចំណូលថវិកាជាតិ និង បង្កើនប្រសិទ្ធភាពចំណាយ; ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ; និង ការរៀបចំឱ្យមានក្របខ័ណ្ឌថវិកាជាក់លាក់ទៅនឹងការពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និង ផែនការថវិកាគ្រប់ក្រសួង-ស្ថាប័ន, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, សម្រាប់ការអនុវត្តថវិកាកម្មវិធី និង ការឈានទៅពង្រឹងការអនុវត្តថវិកាផ្អែកលើសមិទ្ធកម្ម ។

២. បន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវការដ្ឋានកែទម្រង់ការគ្រប់គ្រងចំណូលថវិកាជាតិ រួមមាន ១). ការកែ-លម្អគោលនយោបាយសារពើពន្ធ ដោយឈរលើគោលការណ៍នៃការបង្កើនប្រសិទ្ធភាព ក្នុងការប្រមូលចំណូលថវិកាជាតិ, ការធានាបាននូវបរិយាកាសប្រកួតប្រជែងដោយតម្លាភាព, គណនេយ្យភាព, ស្មើភាព និង យុត្តិធម៌, ការ-លើកទឹកចិត្តដល់សកម្មភាពសេដ្ឋកិច្ច, ធុរកិច្ច និង ការវិនិយោគ, ព្រមទាំងការធានាបាននូវសមធម៌សង្គម; ២). វិធានការពង្រឹង និង ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ដើម្បីបន្តវិឌ្ឍខ្លួនជារដ្ឋបាលសារពើពន្ធទំនើបបែបឌីជីថល ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និង បរិការណ៍សង្គម-សេដ្ឋកិច្ចឌីជីថល ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព; ៣). ការកែលម្អអភិបាលកិច្ចសារពើពន្ធ; ៤). ការលើកកម្ពស់វប្បធម៌បង់ពន្ធ; ៥). ការ-កែលម្អការផ្តល់សេវាបង់ពន្ធ; ៦). ការរៀបចំយន្តការសំខាន់ៗ ដើម្បីពង្រឹងប្រសិទ្ធភាពប្រមូលចំណូល; និង ៧). ការកែលម្អរដ្ឋបាល និង អភិបាលកិច្ចចំណូលមិនមែនសារពើពន្ធ ។

៣. បន្តចាត់វិធានការបង្កើនប្រសិទ្ធភាពចំណាយ តាមរយៈ ការកែលម្អការវិភាជថវិកាឱ្យចំទិសដៅទៅតាមអាទិភាពគោលនយោបាយ, ការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការចំណាយ និង ការពង្រឹងលទ្ធកម្មសាធា-រណៈ, រួមជាមួយនឹងការផ្តោតការវិនិយោគសាធារណៈ លើអាទិភាពចំនួន ៥ សម្រាប់ការកសាងមាតុភូមិ រួមមាន : **"មនុស្ស, ផ្លូវ, ទឹក, ភ្លើង និង បច្ចេកវិទ្យា"** ដែលឈរលើគោលការណ៍ **"ប្រសិទ្ធភាព, ផលិតភាព, គុណភាព, ភាពធន់ និង ចីរភាព"** ។

៤. បន្តពង្រឹងភាពប្រុងប្រយ័ត្នខ្ពស់ ក្នុងការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីធានាចីរភាពថវិកា ដោយប្រកាន់ខ្ជាប់គោលការណ៍គន្លឹះចំនួន ៥ រួមមាន : ១). ខ្វីឥណទាន ក្នុងទំហំសមស្របដែលស្ថានភាពថវិកា និង

សេដ្ឋកិច្ចអាចទ្រាំទ្របាន; ២). ខ្ចីតែឥណទាន ដែលមានកម្រិតសម្បទាន ឬ លក្ខខណ្ឌអនុគ្រោះខ្ពស់; ៣). ខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និង វិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬ ផលិតភាពផលិតកម្ម; ៤). ប្រើប្រាស់ឥណទានប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាពខ្ពស់បំផុត; និង ៥). ប្រើប្រាស់ឥណទាន សម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវមានស្ពង់ជា និង គុណភាពខ្ពស់ ស្របតាមគោលការណ៍គ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយ-តបទៅនឹងតម្រូវការអភិវឌ្ឍជាតិ ក្នុងជំណាក់កាលថ្មី ពិសេស ការធានាបានចីរភាពសេដ្ឋកិច្ច សង្គម, បរិស្ថាន និង ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ។

៥. បន្តជំរុញការអភិវឌ្ឍមូលបត្ររដ្ឋ ជាយន្តការ និង ឧបករណ៍ហិរញ្ញប្បទាន ដើម្បីគាំទ្រ និង លើក-ស្ទួយការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

៦. ពង្រឹងការកែទម្រង់ការគ្រប់គ្រងការងារអធិការកិច្ចហិរញ្ញវត្ថុ និង សវនកម្ម ដើម្បីរួមចំណែកទប់ស្កាត់កំហុស និង ពង្រឹងអភិបាលកិច្ច ក្នុងការគ្រប់គ្រង និង ការអនុវត្តហិរញ្ញវត្ថុសាធារណៈ ក៏ដូចជា ពង្រឹងការ-គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ឱ្យមានប្រសិទ្ធភាពខ្ពស់ និង ទាន់ពេល ។

បង្កើនបរិយាប័ន្ននៃកំណើនសេដ្ឋកិច្ច

១. បន្តដាក់ចេញកញ្ចប់វិធានការអន្តរាគមន៍សង្គម-សេដ្ឋកិច្ច ដោយយក "**មនុស្ស**" ជាអាទិភាពទី ១ ដើម្បី ១). ដោះស្រាយផលប៉ះពាល់ផ្សេងៗ ជាអាទិ៍ ក្នុងគ្រាមានអតិផរណាខ្ពស់ និង មានវិបត្តិ និង គ្រោះអាសន្ន ដែលបង្កផលប៉ះពាល់អាក្រក់ធ្ងន់ធ្ងរដល់ជីវភាពប្រជាជន ពិសេស ដល់គ្រួសារប្រជាជនក្រីក្រងាយរងគ្រោះ និង ងាយរងហានិភ័យ; ២). លើកកម្ពស់សុខុមាលភាពសង្គម; ៣). បង្កើតការងារជូនប្រជាពលរដ្ឋ; ៤). ជំរុញការ-បណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ; និង ៥). ពន្លឿនការចាប់យកបច្ចេកវិទ្យាឌីជីថល សំដៅជំរុញពិពិធកម្ម សេដ្ឋកិច្ច និង លើកកម្ពស់ឧត្តមភាពប្រកួតប្រជែងកម្ពុជា ។

២. បន្តអភិវឌ្ឍ និង ពង្រឹងប្រព័ន្ធសុខាភិបាល និង ពង្រីកប្រព័ន្ធគាំពារសង្គម, ទាំងគុណភាព និង វិសាលភាពគ្របដណ្តប់, ដោយពង្រឹងការអនុវត្តគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០១៦-២០២៥ ។

៣. បន្តកែលម្អ "**ប្រព័ន្ធស្បៀងបម្រុងកម្ពុជា**" ឱ្យមានលទ្ធភាពកាន់តែច្រើន និង អនុវត្តរហ័សទាន់ចិត្ត ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីធ្វើអន្តរាគមន៍ជួយប្រជាជនក្រីក្រ និង ងាយរងគ្រោះផ្នែកស្បៀងអាហារ សម្រាប់ទ្រទ្រង់ជីវភាព ក៏ដូចជាដើម្បីធ្វើអន្តរាគមន៍ជួយប្រជាជនក្រីក្រងាយរងគ្រោះផ្នែកគ្រាប់ពូជ ស្រូវ និង ដំណាំបន្លែ សម្រាប់ស្តារដំណាំស្រូវ និង ដំណាំបន្លែឡើងវិញ ក្រោយពីដំណាំត្រូវខូចខាតដោយសារគ្រោះមហន្តរាយធម្ម-ជាតិ; ព្រមទាំងបន្តផ្តល់គ្រាប់ពូជបន្លែ ដើម្បីជំរុញការដាំបន្លែជាលក្ខណៈគ្រួសារទ្រង់ទ្រាយធំ សម្រាប់ធានាសន្តិសុខស្បៀង និង អាហារូបត្ថម្ភគ្រួសារ, និង សម្រាប់រួមចំណែក ក្នុងការធ្វើពិពិធកម្មផលិតផល និង ចំណូល ។

៤. បន្តអនុវត្តគោលនយោបាយមិនយកពន្ធលើដីកសិកម្មជាលក្ខណៈគ្រួសារ និង ផ្តល់ការលើកទឹក-ចិត្តផ្នែកពន្ធចំពោះការដាំដុះ, ការប្រមូលទិញ និង ការផលិតអង្ករ ដើម្បីនាំចេញ ។

៥. បន្តកាត់បន្ថយចំណាយនៃការរស់នៅរបស់ប្រជាជន តាមរយៈ យន្តការរក្សាស្ថិរភាពថ្លៃម្ហូបអាហារ និង កាត់បន្ថយថ្លៃទឹក, ថ្លៃភ្លើង សម្រាប់ប្រជាជនទូទៅ, ជាពិសេស អ្នកដែលរស់នៅទីជនបទ; និង បន្តអនុវត្តការ-មិនយកកម្រៃសេវាលើការធ្វើអត្តសញ្ញាណបណ្ណ, សៀវភៅគ្រួសារ, សៀវភៅស្នាក់នៅ, និង អត្រានុកូលដ្ឋាន ។

៦. បន្តអនុវត្តគោលការណ៍លុបការបង់ភាសុី និង ការបង់ថ្លៃផ្សេងទៀត ចំពោះការលក់ដូររបស់ប្រជា-ពលរដ្ឋ តាមកន្ត្រែង, កញ្ជើ, ល្ហ, នៅតាមទីផ្សារនៅទូទាំងប្រទេស; អនុញ្ញាតឱ្យអាជីវករដែលមានតូបរាន, ស្តង់ ឬ កន្លែងលក់ដូរដទៃទៀត ទទួលបានសិទ្ធិ កាន់កាប់, ប្រើប្រាស់ និង អាស្រ័យផល ហើយអាចផ្ទេរទៅកូនចៅ ឬអ្នក-ដទៃទៀតបាន ។

៧. បន្តអនុវត្តគោលនយោបាយលើកលែងពន្ធប្រថាប់ត្រា លើការផ្ទេរអចលនទ្រព្យ នៅក្នុងរង្វង់ញាតិ ស្របតាមបទប្បញ្ញត្តិជាធរមាន និង បន្តជំរុញការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ ។

៨. បន្តពង្រីក និង បង្កើតគម្រោងឥណទាន ដែលផ្តោតសំខាន់លើខ្សែច្រវាក់តម្លៃផលិតកម្មកសិកម្ម ដោយផ្តល់ហិរញ្ញប្បទានគាំទ្រដល់តួអង្គដែលពាក់ព័ន្ធ, រួមទាំង កសិករខ្នាតតូច និង សហគមន៍កសិកម្ម សំដៅរួម-ចំណែកលើកកម្ពស់ជីវភាពប្រជាជន, ពិសេស នៅតាមទីជនបទ ។

៩. បន្តដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធ, រួមទាំងដំឡើងកម្រិត អប្បបរមានៃប្រាក់ឈ្នួលកម្មករ ក្នុងកម្រិតសមស្រប; និង ដាក់ចេញនូវក្របខ័ណ្ឌនៃការលើកទឹកចិត្តមន្ត្រី ដោយ-ផ្អែកជាចម្បងលើសមិទ្ធកម្ម ឬ គុណាធិបតេយ្យ ដើម្បីលើកកម្ពស់ផលិតភាពការងារ និង ជីវភាព ព្រមទាំងពង្រឹង សមត្ថភាពស្ថាប័ន និង គុណភាពនៃការផ្តល់សេវាសាធារណៈ ។

១០. បន្តអនុវត្តគោលនយោបាយមិនយកពន្ធលើបៀវត្សអប្បបរមា របស់មន្ត្រីរាជការគ្រប់ប្រភេទ និង ប្រាក់ឈ្នួលអប្បបរមារបស់កម្មករ-និយោជិត ។

១១. បន្តបង្កើនកញ្ចប់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតជាពិសេសលើរដ្ឋបាលមូលដ្ឋាន ដូចជា ក្រុង ស្រុក ខណ្ឌ និង ឃុំ-សង្កាត់ ដើម្បីគាំទ្រដល់លទ្ធភាពប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុង ការផ្តល់សេវាសាធារណៈជូនប្រជាជន និង ជំរុញការអភិវឌ្ឍនៅមូលដ្ឋានឱ្យបានកាន់តែប្រសើរឡើង ។

ពង្រឹងសមត្ថភាពប្រកួតប្រជែង

១. លើកកម្ពស់ឧត្តមភាពប្រកួតប្រជែង តាមរយៈ ការអភិវឌ្ឍវិស័យឧស្សាហកម្ម ដែលមានសក្តា-នុពល, ការលើកកម្ពស់គុណភាពស្ថាប័នសេដ្ឋកិច្ច, និង ការពង្រីកការចាប់យកដៃគូពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌ ទ្វេភាគី និង ពហុភាគី ។

២. បង្កើនឧត្តមភាពប្រកួតប្រជែង ដោយបង្កបរិយាកាសអំណោយផលផ្នែកធុរកិច្ច; កាត់បន្ថយថ្លៃ-ដើមធុរកិច្ច ដូចជា ថ្លៃឡូជីស្ទីក និង អគ្គិសនី; លើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម; ជំរុញការកែទម្រង់ពន្ធដារ; ព្រមទាំងកែលម្អប្រព័ន្ធឡូជីស្ទីក និង លើកកម្ពស់ការដឹកជញ្ជូន, ការតភ្ជាប់ផ្នែកថាមពល ទៅនឹងការប្រើប្រាស់ បច្ចេកវិទ្យាឌីជីថល ។

៣. ជំរុញឌីជីថលូបនីយកម្មសេដ្ឋកិច្ច សង្គម, ទាំងក្នុងវិស័យសាធារណៈ និង វិស័យឯកជន, ជា-ពិសេស ការកសាងហេដ្ឋារចនាសម្ព័ន្ធ ទាំងផ្នែកវីង និង ផ្នែកទន់, ឡូជីស្ទីក, ថាមពលបៃតង និង បច្ចេកវិទ្យា ឌីជីថល ប្រកបដោយគុណភាពខ្ពស់ ។

៤. បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស និង មូលធនមនុស្ស តាមរយៈ ការលើកកម្ពស់គុណភាព អប់រំ និង ការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈគ្រប់កម្រិត ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយ ផលិតភាពខ្ពស់ ឱ្យបានគ្រប់គ្រាន់ និង ឆ្លើយតបតម្រូវការទីផ្សារការងារ និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

៥. ជំរុញកិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលរវាងក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និង គ្រប់តួអង្គពាក់ព័ន្ធ ឱ្យស្ថិតនៅក្នុង "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**" ដើម្បីពង្រឹងសមត្ថភាពស្ថាប័នជាតិ សំដៅកែលម្អការផ្តល់សេវា និង ពង្រឹងភាពប្រកួតប្រជែង ។

២. ការពង្រឹងភាពជាដៃគូក្នុងការអភិវឌ្ឍ

១. បន្តពង្រឹងភាពជាដៃគូជាមួយបណ្តាតួអង្គអភិវឌ្ឍ ដើម្បីកៀរគរធនធានហិរញ្ញប្បទានពីគ្រប់ប្រភពយកមកបម្រើឱ្យកិច្ចការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដោយឈរលើគោលការណ៍ភាពជាម្ចាស់ និង ភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ។

២. បន្តជំរុញជំណើរការសមាហរណកម្ម និង ទំនាក់ទំនងក្នុងតំបន់ និង ពិភពលោក តាមរយៈ យន្តការ, វិធានការ, កម្មវិធី និង គំនិតផ្តួចផ្តើមនានា ដើម្បីលើកកម្ពស់កិត្យានុភាពរបស់កម្ពុជា, បង្កើនកាលានុវត្តភាព សម្រាប់ការអភិវឌ្ឍប្រទេស និង ទាក់ទាញទំនុកចិត្តមកលើសុខសន្តិភាព, សុវត្ថិភាព និង បរិស្ថាននៃការវិនិយោគ និង ពាណិជ្ជកម្មនៅកម្ពុជា ដោយឈរលើគោលការណ៍ "**ស្មើសិទ្ធិ និង ស្មើភាព**" ។

៣. បន្តជំរុញកិច្ចសម្រួលពាណិជ្ជកម្មអន្តរជាតិ តាមរយៈ ការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ទ្វេ-ពហុភាគី, ការសម្រួលលើនីតិវិធីបំពេញបែបបទបញ្ជូនទំនិញពីគយ, ការកាត់បន្ថយថ្លៃស្ថេន និង ការផ្លាស់ប្តូរគោលការណ៍ និង នីតិវិធីនៃការកំណត់មុខសញ្ញាទំនិញដែលត្រូវស្ថេន, ការលុបចោលការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (Certificate of Origin-CO) សម្រាប់ប្រទេសមិនមានតម្រូវការ និង ការបញ្ចុះថ្លៃសេវាផ្ទៃ ជាដើម ។

៤. បន្តលើកកម្ពស់ប្រសិទ្ធភាពប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍ ដោយរក្សាហានិភ័យ និង បន្ទុកសេវាបំណុល ឱ្យនៅក្នុងកម្រិតអប្បបរមា ដោយប្រុងប្រយ័ត្នខ្ពស់ និង អាចគ្រប់គ្រងបាន ។

៥. បន្តការអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន តាមរយៈ ការពង្រឹងការអនុវត្តច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និង ឯកជន ។

៦. បន្តពង្រឹងភាពជាដៃគូ ជាមួយសង្គមស៊ីវិល, សមាគម និង អង្គការមិនមែនរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល ដើម្បីលើកកម្ពស់នីតិរដ្ឋ, ពង្រឹងលទ្ធិប្រជាធិបតេយ្យ និង ចូលរួមអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។

៣. ការអភិវឌ្ឍវិស័យឯកជន

១. ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និង ការវិនិយោគក្នុងស្រុក, រួមទាំងសហគ្រាសធុន តូច និង មធ្យម លើគ្រប់វិស័យ, ពិសេស ឧស្សាហកម្មថ្មីៗ ដូចជា យានយន្ត, គ្រឿងអេឡិកត្រូនិក, គ្រឿងបង្គុំ និង ការកែច្នៃម្ហូបអាហារ ជាដើម ដើម្បីធ្វើពិពិធកម្មឧស្សាហកម្ម, ផ្ទេរបច្ចេកវិទ្យា, ពង្រឹងសមត្ថភាពជំនាញ និង បច្ចេកទេស, ព្រមទាំងបង្កើតតម្លៃបន្ថែម, ការងារ, មុខរបរ និង ប្រាក់ចំណូល ។

២. បង្កើតបរិស្ថានអនុគ្រោះ សម្រាប់ការវិនិយោគ និង ធុរកិច្ច តាមរយៈ ការអនុវត្តច្បាប់វិនិយោគ; ការបន្តកែលម្អក្របខ័ណ្ឌគតិយុត្ត និង អភិបាលកិច្ច; ការពង្រឹងប្រសិទ្ធភាពនៃស្ថាប័នសាធារណៈពាក់ព័ន្ធ; ការកាត់បន្ថយចំណាយ និង កែលម្អប្រព័ន្ធឡូជីស្ទីក; ការកែលម្អកិច្ចសម្រួលពាណិជ្ជកម្ម; ការកាត់បន្ថយការិយាធិបតេយ្យ, ការពង្រឹងការអនុវត្តយន្តការច្រកចេញចូលតែមួយ និង ការលុបបំបាត់ចំណាយក្រៅផ្លូវការ ។

៣. បន្តកសាងអភិបាលកិច្ចសាធារណៈកម្មល្អ សម្រាប់ពង្រឹងភាពប្រកួតប្រជែង, កសាងភាពរឹងមាំ និងអភិវឌ្ឍសមត្ថភាពស្ថាប័ន, ព្រមទាំង ពង្រឹងវប្បធម៌គណនេយ្យភាពចំពោះសង្គម និង ពង្រឹងការបំពេញកាតព្វកិច្ចពន្ធ និង អាករ ។

៤. ពង្រឹងសមត្ថភាពសហគ្រិនភាព និង អភិវឌ្ឍធុរកិច្ច តាមរយៈ យន្តការ, កម្មវិធី, គម្រោង និង គំនិតផ្តួចផ្តើមនានារបស់រាជរដ្ឋាភិបាល; កិច្ចសហការជាមួយដៃគូអភិវឌ្ឍ និង វិស័យឯកជន ដើម្បីកែលម្អខ្សែច្រវាក់ផលិតកម្ម, ពង្រឹងគុណភាព និង ពង្រីកទីផ្សារ; ព្រមទាំងការផ្សារភ្ជាប់ និង ការទាញយកផលប្រយោជន៍ពីសក្តានុពលសហគ្រាស និង ការវិនិយោគបរទេសធំៗ ។

៥. លើកកម្ពស់, ជំរុញ និង ពង្រឹង ប្រសិទ្ធភាពនៃការផ្តល់សេវាដល់វិស័យឯកជន តាមរយៈ ការសម្រួលដល់ការចុះបញ្ជី, ការផ្ទូផ្ទង និង ការកសាងបណ្តាញទំនាក់ទំនង, ការផ្សព្វផ្សាយព័ត៌មានទីផ្សារឱ្យបានទូលំទូលាយ និង ទាន់ពេលវេលា, ការផ្សព្វផ្សាយ និង ការបញ្ជ្រាបបច្ចេកវិទ្យាថ្មី និង ការបន្តខិតខំស្វែងរក និងជ្រៀតចូលទីផ្សារនាំចេញសម្រាប់ផលិតផលកម្ពុជា ។

៦. បន្តអនុវត្ត និង ដំណើរការយន្តការ "**វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន**" ក្នុងកម្រិតគោលនយោបាយ និង បច្ចេកទេស, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈម និង ពង្រឹងវិស័យឯកជន ឱ្យកាន់តែមានជវភាព សំដៅជំរុញឱ្យយន្តការទាំងនេះ ក្លាយជា "**វេទិការអភិវឌ្ឍកម្ពុជា**" ។

៧. លើកកម្ពស់សហគ្រិនភាព និង ពង្រឹងសមត្ថភាពរបស់វិស័យឯកជន, រួមទាំងធុរជនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈ ការផ្តល់ការលើកទឹកចិត្ត, ការប្រឹក្សាយោបល់, ការបណ្តុះបណ្តាល និង លទ្ធភាពទទួលបានហិរញ្ញប្បទាន ។

៨. រៀបចំ និង អនុវត្តក្របខ័ណ្ឌគោលនយោបាយ និង យុទ្ធសាស្ត្រ ទាក់ទាញការវិនិយោគឯកជន តាមរយៈ ការលើកទឹកចិត្តសមស្រប និង ចំគោលដៅ, ការគាំទ្រការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ការសម្រួលរដ្ឋបាល និង នីតិវិធី ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍរយៈពេលវែង ។

៤. ការអភិវឌ្ឍឧស្សាហកម្ម, សិប្បកម្ម និង សហគ្រាសធុន តូច និង មធ្យម

១. បន្តជំរុញវិស័យឧស្សាហកម្ម, សិប្បកម្ម និង សហគ្រាសធុន តូច និង មធ្យម ព្រមទាំងគាំទ្រការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ក្នុងការលើកកម្ពស់ផលិតកម្ម ក្នុងនោះ យកចិត្តទុកដាក់លើការសិក្សាផ្នែកបច្ចេកវិទ្យា ដើម្បីចូលរួមជាបណ្តើរៗ ក្នុងចរន្តសកលនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី ៤ ។

២. ជំរុញការបង្កើតតំបន់ឧស្សាហកម្មថ្មីៗថែមទៀត, ជាពិសេស បង្កើតបណ្តុំសហគ្រាសធុន តូច និង មធ្យម, ព្រមទាំងសួនវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ដែលជាកន្លែងផលិតកម្មគាំទ្រគ្នាទៅវិញទៅមករវាងឧស្សាហកម្មសហគ្រាសធុន តូច មធ្យម និង ធំ ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសផ្នែកផលិតកម្ម ឱ្យមានបទដ្ឋានបច្ចេកទេសសមស្រប និង ជានាលើការប្រកួតប្រជែង នៅក្នុងបរិការណ៍សកលនាបច្ចុប្បន្ន ។

៣. ជំរុញភាពជាដៃគូក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម និង សហគ្រាសធុន តូច និង មធ្យម, វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, ភាពជាដៃគូរវាងរដ្ឋ និង វិស័យឯកជន ដើម្បីជាកាតាលីករ ក្នុងការអភិវឌ្ឍវិស័យនេះ ប្រកបដោយប្រសិទ្ធភាព ។

៤. បន្តជំរុញការអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណង ។

៥. បន្តអភិវឌ្ឍតំបន់ឧស្សាហកម្មតាមខេត្ត ដែលជាមូលដ្ឋានប្រមូលផ្តុំនៃសហគ្រាសធុន មីក្រូ តូច និង មធ្យម សំដៅជំរុញ និង លើកកម្ពស់ភាពប្រកួតប្រជែងសហគ្រាស, គាំទ្រសាជីវកម្មដំបូង (Start-up), ព្រមទាំងរៀបចំផែនការរយៈពេលមធ្យម សម្រាប់អភិវឌ្ឍសហគ្រាសធុន តូច និង មធ្យម ដោយកំណត់យកមុខសញ្ញាសហគ្រាស ដែលមានសក្តានុពលក្នុងការនាំចេញ, ការអភិវឌ្ឍផលិតផលថ្មី, ការតភ្ជាប់ទៅនឹងសាជីវកម្មពហុ-ជាតិ, ការតភ្ជាប់ខ្សែច្រវាក់តម្លៃ និង ការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មតំបន់ ។

៦. ចូលរួមអភិវឌ្ឍតំបន់ជុំវិញរាជធានីភ្នំពេញ ឱ្យក្លាយជាតំបន់ឧស្សាហកម្មប្រមូលផ្តុំ ដោយមានផែនការ ប្រើប្រាស់ដីធ្លីច្បាស់លាស់ និង បែងចែករវាងតំបន់ឧស្សាហកម្ម, ធុរកិច្ច និង តំបន់និវេសនដ្ឋាន ឬ ទីប្រជុំ-ជន, រួមទាំងដាក់ចេញនូវផែនការរយៈពេលវែង សម្រាប់ប្រែក្លាយរាជធានីភ្នំពេញ ទៅជាមជ្ឈមណ្ឌលរដ្ឋបាល, ឧស្សាហកម្ម, វិទ្យាសាស្ត្រ, បច្ចេកវិទ្យា និង នវានុវត្តន៍ ។

៧. លើកកម្ពស់គុណភាព និង ផលិតភាពដល់សហគ្រាសធុន តូច មធ្យម និង សិប្បកម្ម ដោយផ្អែកលើគោលការណ៍ «**ស៥**» ពោលគឺ "**សម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត ស្តង់ដា ស្ថិរភាព**" និង ការស្រាវជ្រាវ និងការអភិវឌ្ឍ ព្រមទាំងលើកកម្ពស់ការបង្កើតតក្កកម្ម និង ការបណ្តុះបណ្តាលកម្មសិទ្ធិឧស្សាហកម្ម ។

៨. ផ្តល់ការគាំទ្រដល់សហគ្រាសធុន តូច មធ្យម និង សិប្បកម្ម សម្រាប់ការបណ្តុះបណ្តាល និងការវិនិយោគលើគ្រឿងម៉ាស៊ីន ឬ បរិក្ខារផលិតកម្ម ព្រមទាំងការលើកទឹកចិត្តផ្សេងៗទៀត ដោយផ្សារភ្ជាប់លក្ខ-ខណ្ឌនៃផលិតកម្មប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក, ការលើកកម្ពស់គុណភាពផលិតផល និង ទំនើបកម្មខ្សែច្រវាក់ផលិតកម្ម សំដៅផ្សារភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ ។

៥. ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ធនាគារ

១. បន្តអនុវត្តគោលនយោបាយរូបិយវត្ថុដោយសកម្ម, ទន់ភ្លន់ និង ប្រុងប្រយ័ត្ន និង បន្តអភិវឌ្ឍបន្ថែមឧបករណ៍នយោបាយរូបិយវត្ថុថ្មីៗ ដោយផ្អែកលើទីផ្សារជាតិ និង អន្តរជាតិ ដើម្បីធានាប្រក្រតីភាពសង្គម និង ជីវភាពប្រជាជន តាមរយៈការរក្សាស្ថិរភាពថ្លៃ, ការពង្រឹងស្ថិរភាពអតិផរណា ឱ្យស្ថិតក្នុងកម្រិតទាបអាចគ្រប់គ្រងបាន, ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ និង តម្លៃប្រាក់រៀល និង ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងសេដ្ឋកិច្ច ឱ្យកាន់តែមានកម្រិតខ្ពស់ ដោយសន្សឹមៗ ។

២. បន្តពង្រឹងក្របខ័ណ្ឌច្បាប់ និង បទដ្ឋានគតិយុត្ត ដោយផ្អែកលើមូលដ្ឋានការបង្ការហានិភ័យ និងការប្រមើលមើលទៅមុខ តាមរយៈ ការត្រួតពិនិត្យ និង ការធ្វើវិសោធនកម្មនូវបទប្បញ្ញត្តិជាធរមាន ឱ្យមានលក្ខ-ណៈអន្តរជាតិ ស្របតាមវឌ្ឍនភាពនៃវិស័យធនាគារ និង ហិរញ្ញវត្ថុ; ព្រមទាំងបន្តអនុវត្តយ៉ាងម៉ឹងម៉ាត់នូវបទ-ប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីពង្រឹងប្រព័ន្ធធនាគារ ឱ្យកាន់តែរឹងមាំ, មានប្រសិទ្ធភាព និងអាចវិវត្តតាមទាន់ស្ថានភាពទីផ្សារ, ព្រមទាំងធានាបានស្ថិរភាពហិរញ្ញវត្ថុ ។

៣. បន្តពង្រឹង និង ពង្រីកតួនាទីនៃវិស័យធនាគារ ដើម្បីកៀរគរធនធានហិរញ្ញវត្ថុក្នុងស្រុក សម្រាប់បំពេញតម្រូវការសេដ្ឋកិច្ចឱ្យកាន់តែរីកចម្រើនឆាប់រហ័ស ស្វែងរកប្រភពទុនដែលមានតម្លៃទាប និង សិក្សាអំពីកត្តារួមផ្សំទាំងឡាយ ដែលធ្វើឱ្យថ្លៃដើមនៃទុនមានកម្រិតខ្ពស់ និងរិះរកគ្រប់មធ្យោបាយ ដើម្បីបញ្ចុះអត្រាការប្រាក់ដោយគោរពតាមយន្តការទីផ្សារ ។

៤. បន្តពង្រឹងការត្រួតពិនិត្យ និង បន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់; ពង្រីកមធ្យោបាយទូទាត់ និង ផ្ទេរ-ប្រាក់ឆ្លងដែន; លើកកម្ពស់ និង រៀបចំវេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មី ដើម្បីជំរុញប្រតិបត្តិការធនាគារឱ្យកាន់តែសម្បូរបែប, មានភាពងាយ និង ជឿនលឿនស្របតាមបច្ចេកវិទ្យាថ្មីៗ; បង្កើនជំនឿទុកចិត្តសាធារណជនលើប្រព័ន្ធទូទាត់; និង ជំរុញការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកឱ្យមានប្រសិទ្ធភាព, សុវត្ថិភាព និង តម្លៃសមរម្យ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការរីកចម្រើនផ្នែកសេដ្ឋកិច្ច និង សមាហរណកម្ម ក្នុងតំបន់ និង ពិភពលោក ។

៥. បន្តពង្រឹង និង ពង្រីកបន្ថែមកិច្ចសហប្រតិបត្តិការទ្វេភាគី និង ពហុភាគី តាមរយៈការជំរុញសមា-ហរណកម្មហិរញ្ញវត្ថុកម្ពុជា ទៅក្នុងតំបន់ និង ពិភពលោក និង ការពង្រឹងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុ ដើម្បីទាញយកផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច, ការកៀរគរធនធាន, ការអភិវឌ្ឍទីផ្សារ និង បច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ ។

៦. បន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ តាមរយៈ ការពង្រឹង និង ការពង្រីកបន្ថែមនូវគោលនយោ-បាយហិរញ្ញវត្ថុ, កម្មវិធីអប់រំហិរញ្ញវត្ថុ, ការលើកកម្ពស់ការធ្វើពិពិកម្មផលិតផលហិរញ្ញវត្ថុ, ការពង្រឹងកិច្ចសហ-ប្រតិបត្តិការ និង ការបង្កើនការផ្សព្វផ្សាយតាមបណ្តាញសង្គមផ្សេងៗ ដើម្បីធានាថា ប្រជាជនទទួលបាន និង ប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែទូលំទូលាយ សម្រាប់ការវិនិយោគ, ការពង្រីក និង ការបង្កើតមុខរបរ, ការលើក-កម្ពស់ជីវភាព និង ការកាត់បន្ថយភាពក្រីក្រ ។

៧. បន្តពង្រីកយន្តការការពារអ្នកប្រើប្រាស់សេវាធនាគារ និង ហិរញ្ញវត្ថុ តាមរយៈ ការរៀបចំកម្មវិធីលើកកម្ពស់អក្ខរកម្មហិរញ្ញវត្ថុ និង ការកំណត់ច្បាស់ពីលក្ខខណ្ឌនានា ចំពោះការផ្តល់ និង ការទទួលឥណទានធនាគារ និង មីក្រូហិរញ្ញវត្ថុ, ការផ្សព្វផ្សាយពាណិជ្ជកម្ម, នីតិវិធីប្តឹង និង តវ៉ា ដើម្បីបង្កើនទំនុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ និង ដើម្បីរួមចំណែករក្សាស្ថេរភាពហិរញ្ញវត្ថុ ។

៨. បន្តពង្រឹងការអនុវត្តកិច្ចការប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម តាមរយៈ ការ-បន្តពង្រឹងក្របខ័ណ្ឌច្បាប់ និង បទប្បញ្ញត្តិទាក់ទងនានា, ការបង្កើនសមត្ថភាពវិភាគ, តាមដាន និង ត្រួតពិនិត្យ ព្រមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរពាក់ព័ន្ធ និង ដៃគូអន្តរជាតិ ក្នុងការផ្លាស់ប្តូរព័ត៌មាន និង ការចាត់វិធានចាំបាច់នានា ដើម្បីធានាឱ្យប្រទេសកម្ពុជាមានសុវត្ថិភាព មិនមែនជាគោលដៅនៃបទល្មើសសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម ។

៦. ការអភិវឌ្ឍវិស័យកសិកម្ម, ការអភិវឌ្ឍជនបទ, ការជំរុញពាណិជ្ជកម្ម, ការគ្រប់គ្រងដីធ្លី, ធនធានធម្មជាតិ និង បរិស្ថាន, និង ការអភិវឌ្ឍទេសចរណ៍

ការអភិវឌ្ឍវិស័យកសិកម្ម

១. បន្តធ្វើទំនើបកម្មក្នុងវិស័យកសិកម្ម, បង្កើនផលិតភាព, ធ្វើពិពិធកម្ម, អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្នុងខ្សែច្រវាក់តម្លៃកសិកម្ម, លើកកម្ពស់សុវត្ថិភាពផលិតផលកសិកម្ម និង បង្កើនការនាំចេញ ដោយអនុវត្តឱ្យមានប្រសិទ្ធភាព នូវគោលនយោបាយជាតិអភិវឌ្ឍវិស័យកសិកម្ម ឆ្នាំ ២០២២-២០៣០ ។

២. បន្តពង្រឹងសមត្ថភាពផលិតដល់កសិករ និង សហគមន៍កសិកម្ម, ពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់ សម្រាប់ការកែច្នៃផលិតផលកសិកម្ម និង បង្កើនសមត្ថភាពកែច្នៃផលិតផលកសិកម្ម តាមរយៈ ការអនុវត្តយន្តការផលិត-កម្មកសិកម្មតាមកិច្ចសន្យា, ការបង្កើនការផ្សព្វផ្សាយអំពីការអនុវត្តបច្ចេកទេសកសិកម្មវៃឆ្លាត ធន់នឹងការប្រែប្រួលអាកាសធាតុ និង ការជំរុញអនុវត្តកម្មវិធីសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី ។

៣. បន្តអនុវត្តវិធានការបច្ចេកទេស សំដៅធានាឱ្យមានអាហារដែលមានសុវត្ថិភាព និង មានអាហារូបត្ថម្ភគ្រប់គ្រាន់ និង ពង្រឹងប្រព័ន្ធស្បៀងអាហារ តាមរយៈ ការធ្វើទំនើបកម្មផលិតកម្មស្បៀងអាហារ ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និង ការអនុវត្តផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជាឆ្នាំ ២០៣០ ។

៤. បន្តគាំទ្រការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ និង ពាណិជ្ជកម្ម, បង្កើនការផ្គត់ផ្គង់សាច់, លើកកម្ពស់សុខភាពសត្ត និង សុខុមាលភាពសាធារណៈ, បង្កើនសមត្ថភាពស្រាវជ្រាវ និង មន្ទីរពិសោធន៍វិនិច្ឆ័យជំងឺសត្ត, ពង្រឹងភាពជាដៃគូជាមួយសហគមន៍ចិញ្ចឹមសត្ត ព្រមទាំងពង្រឹងការអនុវត្តច្បាប់ស្តីពីសុខភាពសត្ត និង ផលិត-កម្មសត្ត ។

៥. រៀបចំយុទ្ធសាស្ត្រកសិកម្មអេឡិចត្រូនិក, បង្កើតប្រព័ន្ធបច្ចេកទេសកសិកម្មតាមបែបឌីជីថល និង សម្របសម្រួលដល់ការប្រើប្រាស់រេទិកាឌីជីថលសម្រាប់កសិ-ធុរកិច្ច, ព្រមទាំងពង្រីកសេវាកម្មព័ត៌មានទីផ្សារកសិកម្មបែបឌីជីថល ឱ្យបានទូលំទូលាយដល់កសិករ ។

៦. បង្កើនការគ្រប់គ្រងធនធានព្រៃឈើ ដោយខិតខំជំរុញការគ្រប់គ្រង និង អភិវឌ្ឍព្រៃឈើ និង សត្ត-ព្រៃ, ការរៀបចំផែនការអភិវឌ្ឍវិស័យព្រៃឈើនិងសត្តព្រៃ, ការបង្កើនប្រសិទ្ធភាពក្នុងការអភិវឌ្ឍព្រៃឈើសហ-គមន៍, ការអនុវត្តប្រព័ន្ធកសិ-រុក្ខកម្ម, ការលើកកម្ពស់ការគ្រប់គ្រង និង អភិវឌ្ឍសត្តព្រៃ និង ជីវៈចម្រុះ, ការជំរុញការដាំឈើឡើងវិញ ជាពិសេស ប្រភេទពូជឈើដែលមានតម្លៃសេដ្ឋកិច្ច ។ បន្តការចុះបញ្ជីដីព្រៃឈើ និង ដីព្រៃសហគមន៍ព្រៃឈើ, បង្កើនការពិនិត្យតាមដានការអនុវត្តសម្បទានដីសេដ្ឋកិច្ច និង ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃ-ឈើឱ្យមានប្រសិទ្ធភាពខ្ពស់ ។

៧. បន្តអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យជលផល, ពង្រឹងការគ្រប់គ្រង និង ការអភិវឌ្ឍសហ-គមន៍នេសាទ, បង្កើនការស្រាវជ្រាវ និង ផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម, កែលម្អពូជត្រី និង អភិរក្សពូជត្រី ដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ ។ ជំរុញការអភិវឌ្ឍសមត្ថភាព និង បច្ចេកវិទ្យាកែលម្អគុណភាពផលិតផលជលផល, ជំរុញវារីវប្បកម្ម និង ចងក្រងបណ្តុំវារីវប្បករ ដោយអនុវត្តនូវយន្តការផលិតកម្មវារីវប្បកម្មតាមកិច្ចសន្យា និង បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

៨. បន្តកែទម្រង់ការគ្រប់គ្រងស្ថាប័ន; ពង្រឹងអភិបាលកិច្ច និង អភិវឌ្ឍធនធានមនុស្ស ស្របតាមគោលនយោបាយធនធានមនុស្សក្នុងវិស័យកសិកម្ម លើកកម្ពស់គុណភាពនៃការអប់រំកសិកម្ម តាមរយៈ ការអនុវត្តផែនការមេឆ្នាំ ២០៣០ របស់គ្រឹះស្ថានអប់រំកសិកម្ម; បង្កើតបណ្ណាល័យសកាវិទ្យាសាស្ត្រកសិកម្ម; និង បង្កើនសមត្ថ-ភាពស្រាវជ្រាវសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មកម្ពុជា ។

៩. បង្កើនសមត្ថភាពសេវាផ្សព្វផ្សាយបច្ចេកទេសលើជំនាញផ្នែកកសិកម្ម និង បណ្តុះបណ្តាលកសិករវ័យក្មេងជាមួយនឹងបច្ចេកវិទ្យាកសិកម្មថ្មីៗ និង ឌីជីថល ដោយផ្សារភ្ជាប់រវាងការស្រាវជ្រាវ និង ការផ្សព្វផ្សាយតាមមុខជំនាញនីមួយៗ ឱ្យបានល្អប្រសើរ ។ ពង្រីកបរិយាកាសគាំទ្រដល់អ្នកផលិត, អ្នកកែច្នៃ និង អ្នកនាំចេញ, ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់ តាមអភិក្រម **"ផ្ទៃ-ឯកជន-ដៃគូអភិវឌ្ឍ និង សហគមន៍"** ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម ។

ការអភិវឌ្ឍជនបទ

១. ជំរុញការអភិវឌ្ឍជនបទ, ទាំងផ្នែកសេដ្ឋកិច្ច និង សង្គមកិច្ច, ដើម្បីលើកកម្ពស់គុណភាពនៃជីវិតរបស់ប្រជាជន និង ប្រែក្លាយជនបទឱ្យទៅជាតំបន់ដែលមានភាពរីកចម្រើន, ជឿនលឿន និង ស៊ីវិលីយ, ស័ក្តិសមជាជនបទនៃប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ និង ប្រាក់ចំណូលខ្ពស់ នៅឆ្នាំ ២០៥០ ។

២. បន្តកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ តាមរយៈ ការលើកកម្ពស់ការផ្តល់សេវាសង្គមនានា ជាអាទិ៍ សេវាអប់រំ, សេវាសុខាភិបាល, សេវាទឹកស្អាត, អនាម័យ, ទូរគមនាគមន៍ ; និង ពង្រឹងកិច្ចសហ-ប្រតិបត្តិការ, ការសម្របសម្រួល និង ការកៀរគរធនធាន ដើម្បីពង្រីកវិសាលភាពនៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និង លើកកម្ពស់អនាម័យជនបទឱ្យកាន់តែខ្លាំងក្លា និង មានប្រសិទ្ធភាពថែមទៀត ដោយបន្តជំរុញការអនុវត្តផែនការសកម្មភាពផ្គត់ផ្គង់ទឹកស្អាត និង អនាម័យជនបទឱ្យបានសម្រេចអត្រាគ្របដណ្តប់ ៩០% នៅឆ្នាំ ២០២៣ និង ១០០% នៅឆ្នាំ ២០៣០ សំដៅឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ, បញ្ហាប្រឈម ក្នុងតំបន់ និង វិសម-ភាពនៃការទទួលបានសេវា ។

៣. បន្តជំរុញការលើកកម្ពស់ជីវភាពប្រជាជននៅជនបទ តាមរយៈ ការស្តារ, ការស្ថាបនាហេដ្ឋារចនា-សម្ព័ន្ធគមនាគមន៍ដឹកជញ្ជូននៅជនបទ និង ការលើកកម្រិតផ្លូវជនបទពីផ្លូវក្រាលក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូ ឬ ផ្លូវបេតុង សំដៅធានាបានការប្រើប្រាស់យូរអង្វែង, ធន់នឹងការប្រែប្រួលអាកាសធាតុ ដើម្បីជំរុញដំណើរអន្តរកម្មផ្នែកសង្គម-សេដ្ឋកិច្ច និង ការផ្សារភ្ជាប់សកម្មភាពធុរកិច្ចផ្សេងៗ រវាងតំបន់ជនបទ និង ទីប្រជុំជន ។

៤. បន្តយកចិត្តទុកដាក់លើការថែទាំជួសជុលផ្លូវជនបទជាប្រចាំ; ពង្រឹងការងារតាមដាន, ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តគម្រោង; រៀបចំចងក្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងដីចំណីផ្លូវ; និង បន្តធ្វើបច្ចុប្បន្នភាពបញ្ជីសារពើកណ្ឌផ្លូវជនបទ ។

៥. បន្តជំរុញការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ ដើម្បីបង្កើនប្រាក់ចំណូលប្រចាំថ្ងៃតាមគ្រួសារនីមួយៗនៅសហគមន៍ជនបទឱ្យមានជីវភាពសមរម្យ ដោយជំរុញការងារដាំដុះដំណាំ, ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ, សិប្បកម្ម, សេវាកម្មខ្នាតតូច, ការប្រកបរបរអាជីវកម្ម, សហគ្រាសខ្នាតគ្រួសារ, និង ការសាងសង់ផ្សារជនបទ ជាដើម ។

៦. បន្តអភិវឌ្ឍតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅឱ្យរីកចម្រើន, ទាំងខាងសេដ្ឋកិច្ច, សង្គម-កិច្ច និង វប្បធម៌; និង ធានាសិទ្ធិទទួលបានការការពារដោយច្បាប់ និង វិធានការសង្គមនានា ដែលឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាមូលដ្ឋាន សម្រាប់ការរស់នៅប្រកបដោយភាពថ្លៃថ្នូរ, ព្រមទាំងការគោរពចំពោះទំនៀមទម្លាប់ប្រពៃណី, ភាសា និង ជំនឿ របស់ជនជាតិដើមភាគតិច ។

ការជំរុញពាណិជ្ជកម្ម

១. បន្តពង្រឹងការគ្រប់គ្រងទីផ្សារ និង ការពារផលប្រយោជន៍អ្នកផលិត និង អ្នកប្រើប្រាស់ តាមរយៈ ការជំរុញបង្កើតទីផ្សារនៅមូលដ្ឋាន សម្រាប់អាជីវករ, សហគ្រិន និង កសិករខ្នាតតូច និង ការអភិវឌ្ឍខ្សែច្រវាក់តម្លៃ និង ផ្គត់ផ្គង់ ដើម្បីផ្សារភ្ជាប់រវាងអ្នកដាំដុះ, អ្នកផលិត, អ្នកកែច្នៃ, អ្នកប្រមូលទិញ និង អ្នកនាំចេញ; និង ជាពិសេស បន្តកែលម្អ និង តភ្ជាប់ប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម និង ការផ្តល់លិខិតអនុញ្ញាត និង អាជ្ញាបណ្ណនានា តាមរយៈប្រព័ន្ធថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាល ។

២. រៀបចំយុទ្ធសាស្ត្រជំរុញការប្រើប្រាស់ផលិតផលខ្មែរនៅទីផ្សារក្នុងស្រុក និង ទីផ្សារអន្តរជាតិ តាមរយៈ ការរៀបចំពិព័រណ៍ក្នុងស្រុក និង អន្តរជាតិនានា, ព្រមទាំងជួយដល់វិស័យឯកជន ក្នុងការបង្កើតសភាពាណិជ្ជកម្ម នៅតាមរាជធានី-ខេត្តទាំងអស់ និង តំណាងសភាពាណិជ្ជកម្មកម្ពុជានៅក្រៅប្រទេស ក៏ដូចជា ការបង្កើតសមាគមតាមមុខរបរ និង ផលិតផល ដើម្បីចូលរួមក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ និង ចាប់យកឱកាសពាណិជ្ជកម្ម ។

៣. ចងក្រង និង គ្រប់គ្រងទិន្នន័យស្ថិតិពាណិជ្ជកម្ម សម្រាប់ធ្វើជាមូលដ្ឋានក្នុងការវិភាគ និង ប្រើប្រាស់ជាព័ត៌មានពាណិជ្ជកម្មសម្រាប់ស្ថាប័នរដ្ឋ, គ្រឹះស្ថានសិក្សា និង វិស័យឯកជន ។ បន្ត និង ពង្រឹងយន្តការតាមដានថ្លៃទំនិញ និង តុល្យភាពនៃការផ្គត់ផ្គង់ និង តម្រូវការទីផ្សារ លើបណ្ណាទំនិញជាយុទ្ធសាស្ត្រ ដូចជា ស្រូវ, អង្ករ, ប្រេងឥន្ធនៈ និង បណ្ណាមុខទំនិញផ្សេងទៀត ដោយចាត់វិធានការលើបាតុភាពស្តុកទំនិញលក់ដំឡើងថ្លៃ ដែលនាំឱ្យប៉ះពាល់ដល់ជីវភាពប្រជាជន ។

៤. រៀបចំផែនការចូលរួមអនុវត្តគោលនយោបាយសេដ្ឋកិច្ចឌីជីថល តាមរយៈការជំរុញលើកទឹកចិត្ត ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយបង្កើតនូវចំណងទាក់ទងរវាងទីផ្សារធំៗជាមួយនឹងសហគ្រាសធុន តូច និង មធ្យម ក្នុងស្រុក និង ការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមក្របខ័ណ្ឌច្បាប់ និង កិច្ចព្រមព្រៀងជាតិ និង អន្តរជាតិ ជាពិសេស កិច្ចសម្រួលពាណិជ្ជកម្មឱ្យបានឆាប់រហ័សតាមទម្រង់អេឡិចត្រូនិក ។

៥. រៀបចំយុទ្ធសាស្ត្រទាញយកអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតំបន់ និង ទ្វេភាគីនានា សំដៅឱ្យអ្នកផលិត និង អ្នកនាំចេញកម្ពុជា អាចចូលរួមក្នុងខ្សែច្រវាក់ផ្គត់ផ្គង់អន្តរជាតិ និង បង្កើនការនាំចេញ ។

៦. ពង្រឹងសមត្ថភាពកម្ពុជាសម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌអាស៊ាន ជាមួយដៃគូពាណិជ្ជកម្មរបស់អាស៊ាន និង ក្នុងក្របខ័ណ្ឌអន្តរជាតិ ព្រមទាំងបន្តសម្របសម្រួលសហការលើការងារជំរុញពាណិជ្ជកម្មតាមព្រំដែនជាមួយប្រទេសជិតខាង និង ដៃគូពាណិជ្ជកម្មផ្សេងទៀត សំដៅធានាបាននូវតុល្យភាពជញ្ជីងពាណិជ្ជកម្ម ។

៧. កសាង និង អនុវត្តផែនការមេ និង ផែនការសកម្មភាពសាងសង់ផ្សារ តាមព្រំដែន និង តាមបណ្ណាខេត្ត ព្រមទាំងរៀបចំផ្សារលក់ទំនិញតាមអនឡាញ សំដៅជួយទ្រទ្រង់ការផលិត និង ការលក់ទំនិញ ។

៨. បន្តស្រាវជ្រាវ និង ចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ និង ម៉ាកសមូហភាព ឱ្យបានកាន់តែច្រើន សំដៅលើកស្ទួយគុណភាព និង ការផ្គត់ផ្គង់ផលិតផលរបស់កម្ពុជា ទៅកាន់ទីផ្សារក្នុងស្រុក និង ក្រៅប្រទេស និង កាត់បន្ថយការនាំចូល ។

៩. បន្តរៀបចំយុទ្ធសាស្ត្រ និង កម្មវិធីការងារ សម្រាប់ជំរុញផលិតកម្មស្រូវ និង ផលិតកម្មដំណាំសក្តានុពលផ្សេងៗទៀត សម្រាប់ការនាំចេញ ។

១០. រៀបចំកម្មវិធី និង ផែនការសកម្មភាព ដើម្បីអនុវត្តលិខិតបទដ្ឋានច្បាប់ ទាក់ទងនឹងកិច្ចការប្រកួតប្រជែង, ការពារអ្នកប្រើប្រាស់ និង ច្បាប់ស្តីពីម្ហូបអាហារ ដើម្បីរក្សាសុខភាព, សុវត្ថិភាព និង សុខុមាលភាពអ្នកប្រើប្រាស់ និង ដើម្បីបង្កបរិយាកាសស្មើភាព និង យុត្តិធម៌ សម្រាប់ការធ្វើពាណិជ្ជកម្ម និង ការវិនិយោគ នៅកម្ពុជា ។

១១. បន្តអភិវឌ្ឍវិស័យពាណិជ្ជកម្មនៅថ្នាក់ក្រោមជាតិ ដោយបន្តអនុវត្ត **"ចលនាភូមិមួយ ផលិតផលមួយ"** ឱ្យបានទូលំទូលាយ និង មានប្រសិទ្ធភាព តាមរយៈ ការជំរុញឱ្យប្រជាជនផលិតស្របតាមលក្ខខណ្ឌភូមិសាស្ត្រ និង លក្ខខណ្ឌទីផ្សារក្នុងប្រទេស និង ក្រៅប្រទេស, ផលិតឱ្យបានច្រើន, មានគុណភាពល្អ និង បានថ្លៃ

ខ្ពស់ និង ប្រើប្រាស់គំនិតច្នៃប្រឌិត និង ទេពកោសល្យរបស់ប្រជាជនតាមមូលដ្ឋាន ។

ការគ្រប់គ្រងដីធ្លី និង សំណង់

១. បន្តអនុវត្តការកែទម្រង់ឱ្យកាន់តែសកម្ម និង ស៊ីជម្រៅលើវិស័យដីធ្លី តាមរយៈការពង្រឹងការ-គ្រប់គ្រងដីធ្លី ដោយជំរុញបញ្ចប់ការចុះបញ្ជីដីលើកដំបូង, ជំរុញការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និង ជំរុញការចុះបញ្ជីបន្តដីគ្រប់ប្រភេទ ព្រមទាំងផ្តល់ប័ណ្ណកម្មសិទ្ធិជូនអ្នកកាន់កាប់ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌ ។ ដាក់ចេញនូវវិធានការទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីគ្រប់ប្រភេទរបស់រដ្ឋ ដោយខុសច្បាប់ និង បន្តពិនិត្យធ្វើប្រទានកម្មដីជូនប្រជាជនរស់នៅ និង អាស្រ័យផលលើទីតាំងដីរដ្ឋ, ជាពិសេស នៅតំបន់ ៣ និង តំបន់ ២ នៃបឹងទន្លេសាប ដែលជាមូលដ្ឋានចាស់បូរាណរបស់ប្រជាជន និង ជំរុញការពង្រឹងគ្រប់យន្តការដោះ-ស្រាយវិវាទដីធ្លី ដើម្បីផ្តល់ភាពសុខដុមរមនាក្នុងសង្គម ។

២. បន្តអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ដើម្បីចែកដីជូនប្រជាពលរដ្ឋស៊ីវិលក្រីក្រ និង/ឬ ផ្ទះជូនកងកម្លាំងកំពុងឈរជើងតាមព្រំដែន និង ជូនអតីតកងកម្លាំងប្រដាប់អាវុធ និង គ្រួសារដែលក្រីក្រ និង ខ្វះដី ប្រកបដោយតម្លាភាព និង សមធម៌ ។

៣. បន្តពង្រឹងការកសាងផែនការរៀបចំដែនដី, ប្លង់គោលប្រើប្រាស់ដី និង ផែនការប្រើប្រាស់ដីជាពិសេសនៅតាមតំបន់អាទិភាព ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព ។ បន្តកសាង និង គ្រប់គ្រងស្ថានីយ-វាស់វែងអចិន្ត្រៃយ៍ ក៏ដូចជា ដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មាន និង ទិន្នន័យសុរិយោដី, ទិន្នន័យ រៀបចំដែនដី និង នគរូបនីយកម្ម, ទិន្នន័យសំណង់ និង លំនៅឋានទូទាំងប្រទេស ប្រកបដោយប្រសិទ្ធភាព ក្នុងបរិការណ៍នៃបច្ចេកវិទ្យាឌីជីថល ។

៤. បន្តពង្រឹងការអភិវឌ្ឍវិស័យសំណង់ ដោយអនុលោមទៅតាមច្បាប់ស្តីពីសំណង់ និង បទដ្ឋានគតិយុត្តនគរូបនីយកម្ម និង បច្ចេកទេស ដើម្បីធានាបាននូវ គុណភាព, សន្តិសុខ, សុវត្ថិភាព, សោភ័ណភាព, សណ្តាប់ធ្នាប់សាធារណៈ និង បរិស្ថាន ព្រមទាំងចាត់វិធានការទប់ស្កាត់ការសាងសង់លើដីចំណីសាធារណៈ ។

៥. ជំរុញការសាងសង់លំនៅឋានតម្លៃសមរម្យសម្រាប់ជួល និង លក់ជូនប្រជាពលរដ្ឋ ដែលមានប្រាក់ចំណូលមធ្យម, ចំណូលទាប និង ជនងាយរងគ្រោះ ស្របតាមគោលនយោបាយជាតិស្តីពីលំនៅឋាន និង គោល-នយោបាយស្តីពីការលើកទឹកចិត្ត និង ការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ ។

ការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន

១. កាត់បន្ថយការបំពុលបរិស្ថានដោយបន្តពង្រឹងការគ្រប់គ្រងសំណល់ទីប្រជុំជនប្លាស្ទីក និងសំណល់គ្រោះថ្នាក់, ការត្រួតពិនិត្យការបំពុលទឹក ខ្យល់ និង សំឡេង ព្រមទាំងបន្តជំរុញថាមពលស្អាត, ប្រសិទ្ធភាពថាមពល, ការអនុវត្តកសិកម្មឆ្លាតធន់នឹងអាកាសធាតុ, ការដឹកជញ្ជូនបៃតង, ដំណើរការឧស្សាហកម្មស្អាត, ការអនុវត្តសេដ្ឋកិច្ច-ចក្រា, យន្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន, វិញ្ញាបនកម្មបៃតង និង ការប្រតិបត្តិមេត្រីភាពបរិស្ថាន ។

២. ពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ, ការអភិរក្សជីវៈចម្រុះ និង ការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយចីរភាព ដោយបន្តចុះបញ្ជីដីរដ្ឋ, ចោះបង្គោលព្រំ, ពង្រឹងការអនុវត្តច្បាប់, ស្តារទីជម្រក និង ពូជសត្ត្ববៃព្រៃ និង អភិរក្សប្រព័ន្ធការពារធម្មជាតិ ដើម្បីធានាមុខងារសេវាកម្មអេកូឡូស៊ី ក៏ដូចជា បន្តលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និង ពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចនៃសហគមន៍តំបន់ការពារធម្មជាតិ តាមរយៈ ការអនុវត្តគោលនយោ-

បាយរដ្ឋ, ការលើកទឹកចិត្តដល់ការវិនិយោគឯកជន, ការដាំដំណាំចម្រុះ, ដំណាំសេដ្ឋកិច្ច និង ឈើឧស្សាហកម្ម, និង ការចិញ្ចឹមសត្វ ដែលមានភាពធន់នឹងអាកាសធាតុ ។

៣. បន្តលើកកម្ពស់ការអប់រំផ្សព្វផ្សាយអំពីបរិស្ថាន និង ការប្រែប្រួលអាកាសធាតុ ដោយបង្កើនមធ្យោបាយផ្សព្វផ្សាយនវានុវត្តន៍ និង ជំរុញការចូលរួមពីដៃគូ ដើម្បីលើកកម្ពស់ការយល់ដឹង និង ការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋចំពោះបរិស្ថាន ព្រមទាំងរឹតចំណងជិតស្និទ្ធរវាងមនុស្ស និង ធម្មជាតិ តាមរយៈ ការជំរុញស្មារតី "**កម្ពុជាមាតុភូមិខ្ញុំ**" និង ទេសចរណ៍ផ្សារភ្ជាប់ជាមួយធម្មជាតិ និង ទឹកដី ។

៤. បន្តពង្រឹងរដ្ឋបាលទំនើប, ពង្រីកហិរញ្ញវត្ថុប្រកបដោយចីរភាព និង កែលម្អក្របខ័ណ្ឌគោលនយោ-បាយ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនិងនិន្នាការបរិស្ថាន តាមរយៈ ការធ្វើឱ្យប្រសើរឡើងនូវយន្តការស្ថាប័ន, មូលដ្ឋានសម្ភារៈ បច្ចេកទេស, ធនធានមនុស្ស និង ធនធានហិរញ្ញវត្ថុ ក្នុងនោះ រួមមាន ការជំរុញការចូលរួមចំណែកពីបណ្តាប្រភពហិរញ្ញប្បទានពាក់ព័ន្ធនឹងបរិស្ថាន ដូចជា មូលបត្របៃតង, ឥណទានកាបូន និង ការទូទាត់ថ្លៃសេវាប្រព័ន្ធអេកូឡូស៊ី ជាដើម ។

៥. លើកកម្ពស់ការទូតបៃតង ដោយបន្តចូលរួមជាមួយសហគមន៍ប្រជាជាតិ ក្នុងការអនុវត្តកាតព្វកិច្ចអន្តរជាតិពាក់ព័ន្ធនឹងបរិស្ថាន រួមចំណែកដោះស្រាយបញ្ហាបរិស្ថានសកល និង ជំរុញរបៀបវារៈបៃតង, ការប្រែប្រួលអាកាសធាតុ, អព្យាក្រឹតកាបូន, ទីផ្សារកាបូន និង ហិរញ្ញប្បទានអាកាសធាតុ សំដៅលើកស្ទួយកិត្យានុភាពរបស់កម្ពុជាលើឆាកអន្តរជាតិ និង ទាញយកឧត្តមប្រយោជន៍ជូនជាតិមាតុភូមិ ។

ការអភិវឌ្ឍទេសចរណ៍

១. ជំរុញវិស័យទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌ និង ធម្មជាតិ ដែលត្រូវបានចាត់ទុកជា "**មាសបៃតង**" ។ ការអភិវឌ្ឍទេសចរណ៍ គឺជាការរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, ផ្តល់ឱកាសការងារ, ផ្តល់ប្រាក់-ចំណូល និង លើកកម្ពស់ជីវភាពរបស់ប្រជាជន ។

២. បន្តអនុវត្តគោលនយោបាយ និង ផែនការយុទ្ធសាស្ត្រសំខាន់ៗ ដើម្បីជំរុញការលើកកម្ពស់ប្រកប-ដោយប្រសិទ្ធភាព នូវការគ្រប់គ្រង និង ការអភិវឌ្ឍទេសចរណ៍ ស្របតាមចក្ខុវិស័យឆ្ពោះទៅគោលដៅអនាគតនៃទេសចរណ៍កម្ពុជា **ស្អាត បៃតង និង ចីរភាព** ដើម្បីទាក់ទាញទេសចរអន្តរជាតិប្រមាណ ៨ លាននាក់ និង ទេសចរផ្ទៃក្នុងប្រមាណ ១៦ លាននាក់ នៅឆ្នាំ ២០២៨ ។

៣. បន្តជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទេសចរណ៍ ដូចជា ផ្លូវ, ទឹកស្អាត, អគ្គិសនី, ព្រ-លានយន្តហោះ, កំពង់ផែ, ប្រព័ន្ធទូរគមនាគមន៍ និង មូលដ្ឋានសម្បទាសេវាកម្មគាំទ្រផ្សេងទៀត ឱ្យបានល្អប្រសើរ ។

៤. បង្កើនការទាញយកផលប្រយោជន៍ជាអតិបរមានៃវិស័យទេសចរណ៍ សំដៅបង្កើត និង ពង្រីកការងារថ្មី, ជំរុញឧត្តមភាពប្រកួតប្រជែងទេសចរណ៍, លើកកម្ពស់កិត្យានុភាពវប្បធម៌ និង ប្រពៃណីរបស់មាតុភូមិយើង ជាគោលដៅទេសចរណ៍ដ៏ទាក់ទាញប្រកបដោយសុវត្ថិភាព និង ផាសុកភាព ។

៥. ជំរុញការអភិវឌ្ឍផលិតផល និង សេវាកម្មទេសចរណ៍ ប្រកបដោយនវានុវត្តន៍ និង ភាពច្នៃប្រឌិត, ជាពិសេស ការពង្រឹងគុណភាពសេវាកម្មទេសចរណ៍ ក៏ដូចជា ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍បន្ថែមទៀត និង សម្រួលការធ្វើដំណើរ និង ការដឹកជញ្ជូនទេសចរណ៍ប្រកបដោយសុវត្ថិភាព ។

៦. ពង្រឹងសមត្ថភាពសិក្សាទីផ្សារ និង ផ្សព្វផ្សាយទេសចរណ៍, ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ, ការ-

លើកកម្ពស់ប្រសិទ្ធភាពអភិបាលកិច្ច និង ការអភិវឌ្ឍធនធានមនុស្ស ។

៧. បង្កើនការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍, ផែនទីចង្អុលផ្លូវ, ផែនការយុទ្ធសាស្ត្រ, គោលការណ៍ណែនាំ និង យន្តការនានា ប្រកបដោយប្រសិទ្ធភាព ។

៨. បន្តជំរុញសកម្មភាពទេសចរណ៍ផ្ទៃក្នុង និង រំហូរទេសចរអន្តរជាតិ ក្នុងការទស្សនាកម្ពុជា ស្របនឹងការអប់រំលើកទឹកចិត្តប្រជាជនឱ្យចូលរួមកិច្ចអភិវឌ្ឍទេសចរណ៍ប្រកបដោយភាពទាក់ទាញ ។

៩. បន្តពង្រឹង និង ពង្រីកការអភិវឌ្ឍទេសចរណ៍នៅតាមគោលដៅនានា ដូចជា សហគមន៍ទេសចរណ៍, អេកូទេសចរណ៍ និង កសិ-ទេសចរណ៍ ក្រោមកិច្ចសហការជាមួយអន្តរស្ថាប័ន និង ភាគីពាក់ព័ន្ធ ឱ្យបានល្អប្រសើរ ។

៧. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និង ដឹកជញ្ជូន

១. បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និង ឡូជីស្ទីកឱ្យមានសមត្ថភាពគ្រប់គ្រាន់ និង ឆ្លើយតបទៅនឹងការប្រែប្រួលប្រជាសាស្ត្រ និង កំណើននគរូបនីយកម្ម, ពាណិជ្ជកម្ម, ការធ្វើពិពិធកម្មវិស័យឧស្សាហកម្ម, កសិកម្ម និង ទេសចរណ៍, ព្រមទាំងការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និង ការធ្វើសមាហរណកម្មតំបន់ ។

២. បន្តកែលម្អ និង អភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន ទាំងផ្លូវគោក, ផ្លូវដែក, ផ្លូវទឹក (នាវាចរ និង កំពង់ផែ) និង ផ្លូវអាកាស ដោយផ្តោតលើការពង្រឹងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការតម្រង់ទិសឆ្ពោះទៅរកការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ ដែលមានភាពប្រទាក់ក្រឡា, កាត់បន្ថយពេល និង ចំណាយ ក្នុងការធ្វើដំណើរ និង ការដឹកជញ្ជូនទំនិញ និង ដោយផ្តោតលើការពង្រឹងសមត្ថភាពផ្តល់សេវាកម្មឡូជីស្ទីកឱ្យមានភាពងាយស្រួល, ស្ថិរភាព, ផាសុកភាព, ប្រសិទ្ធភាពសេដ្ឋកិច្ច និង សុវត្ថិភាព ។

៣. បន្តស្តារ, ជួសជុល, ថែទាំ, ពង្រីក និង អភិវឌ្ឍថ្មី នូវបណ្តាញផ្លូវជាតិ, ផ្លូវខេត្ត, ផ្លូវក្នុងទីប្រជុំជន និង ផ្លូវយុទ្ធសាស្ត្រ ដែលមានសក្តានុពលសេដ្ឋកិច្ច និង តំបន់ខ្សែក្រវាត់ការពារព្រំដែន ឱ្យមានគុណភាពធន់នឹងការផ្លាស់ប្តូរអាកាសធាតុ និង គ្រោះធម្មជាតិ, មានសុវត្ថិភាព និង សោភ័ណភាព ។

៤. ជំរុញការរៀបចំប្លង់មេ និង ធ្វើឱ្យប្រសើរឡើងនូវការដឹកជញ្ជូនសាធារណៈ ក្នុងក្រុង និង តាម-ទីប្រជុំជន ដែលស្ថិតនៅលើដងផ្លូវជាតិ និង ផ្លូវខេត្តសំខាន់ៗ ។

៥. ជំរុញការសាងសង់ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់, ទីលានទុកដាក់ និង កែច្នៃសំរាម និង ពង្រីកតំបន់គ្របដណ្តប់នៃប្រព័ន្ធលូនៅតាមទីក្រុង និង ទីប្រជុំជនសំខាន់ៗ ព្រមទាំងជំរុញការកសាងប្រព័ន្ធការពារទឹកជំនន់ និងការពារច្រាំងទន្លេ ដើម្បីរក្សាបរិស្ថានល្អ, លើកកម្ពស់សុខុមាលភាពប្រជាជន និង បញ្ចៀសការជន់លិចនៅតាមតំបន់ប្រជាជនរស់នៅ ។

៦. បន្តអភិវឌ្ឍ, ជួសជុល និង ថែទាំបណ្តាញផ្លូវដែកនៅកម្ពុជាដែលមានស្រាប់នៅពាយ័ព្យទិស និង និរតីទិស ដើម្បីពង្រីកវិសាលភាពនៃការដឹកជញ្ជូនទំនិញ និង អ្នកដំណើរ និង ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន, ព្រម-ទាំងធ្វើសមាហរណកម្មផ្លូវដែកកម្ពុជា ទៅក្នុងប្រព័ន្ធផ្លូវដែកតំបន់អាស៊ាន និង មហាអនុតំបន់មេគង្គ ។

៧. បន្តស្វែងរកដៃគូវិនិយោគ និង ជំរុញការសាងសង់ប្រព័ន្ធរថភ្លើងធុនស្រាល នៅលើខ្សែអាទិភាពនៅរាជធានីភ្នំពេញ ។

៨. បន្តអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនផ្លូវសមុទ្រ, ផ្លូវទឹក និង កំពង់ផែ, ជាពិសេស ពង្រីកកំពង់ផែទឹកជ្រៅ

និង ធ្វើទំនើបកម្មរចនាសម្ព័ន្ធរូបវន្តកំពង់ផែ ដើម្បីលើកកម្ពស់ផលិតភាព និង សមត្ថភាពប្រតិបត្តិការ ក្នុងការសម្រួលពាណិជ្ជកម្ម, ការចរាចរទំនិញ និង ទេសចរណ៍ ។

៩. ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក តាមរយៈ ការបង្កើនការត្រួតពិនិត្យបច្ចេកទេសយានយន្ត, ការបញ្ឈប់ការកែច្នៃយានយន្តខុសលក្ខណៈបច្ចេកទេស និង ការលុបបំបាត់ការដឹកជញ្ជូនលើសទម្ងន់កំណត់ ព្រមទាំងចាត់វិធានការចាំបាច់នានា ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និង ការខូចខាតហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ។

អាកាសចរណ៍ស៊ីវិល

១. បន្តអនុវត្តគោលនយោបាយបើកចំហដើងមេឃ និង ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យអាកាសចរណ៍ស៊ីវិល និង ការតភ្ជាប់ការហោះហើរ ដើម្បីធ្វើសមាហរណកម្ម និង សុខដុមនីយកម្មគោលនយោបាយ និង ផែនទីមគ្គទ្វេសក៏អាកាសចរណ៍ស៊ីវិលកម្ពុជា ជាមួយនឹងគោលនយោបាយអភិវឌ្ឍវិស័យអាកាសចរណ៍ស៊ីវិល ក្នុងអនុតំបន់, តំបន់ និង ពិភពលោក ។

២. បន្តអភិវឌ្ឍ និង ធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិ-អន្តរជាតិ ដើម្បីឆ្លើយតបទៅនឹងកំណើននៃតម្រូវការដឹកជញ្ជូនតាមផ្លូវអាកាស និង ជួយសម្រួលដល់ការចុះចតអាកាសយានធំ-តូចគ្រប់ប្រភេទ ។

៣. បន្តយកចិត្តទុកដាក់ពង្រឹងសន្តិសុខអាកាសចរណ៍ស៊ីវិល ដោយអនុវត្តយ៉ាងហ្មត់ចត់តាមបទដ្ឋានជាតិ និង អន្តរជាតិ ស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល សំដៅការពារ, ទប់ស្កាត់ និង ប្រឆាំងរាល់អំពើភេរវកម្ម, ការបំផ្លិចបំផ្លាញ និង ការគំរាមដល់ជីវិត និង ទ្រព្យសម្បត្តិរបស់អ្នកដំណើរ ។

៤. បន្តពង្រឹងសុវត្ថិភាពហោះហើរ និង ធ្វើទំនើបកម្មសេវាកម្មនាំផ្លូវអាកាស ស្របតាមបទដ្ឋានអន្តរជាតិ ដើម្បីធានាដល់ប្រតិបត្តិការអាកាសយាន និង ការនាំផ្លូវហោះហើរប្រកបដោយសុវត្ថិភាពខ្ពស់ ។

៨. ការគ្រប់គ្រងធនធានទឹក និង ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ

១. ពង្រឹងវិធានការការពារ, ទប់ស្កាត់ និង អភិរក្សធនធានទឹក តាមរយៈ ការពង្រឹងការគ្រប់គ្រង និង ថែរក្សាអាងទន្លេ, ស្ទឹង, បឹងបួ, ព្រៃក, ប្រព័ន្ធធារាសាស្ត្រ និង ផ្លូវទឹកធម្មជាតិ ដោយរៀបចំឱ្យបានច្បាស់លាស់នូវផែនទីកំណត់តំបន់គ្រប់គ្រង និង ប្រើប្រាស់ទឹក, ផែនទីប្រព័ន្ធធារាសាស្ត្រ និង ស្រោចស្រព និង កំណត់បរិមាណផ្ទៃទឹក, ចំណីទន្លេ, ចំណីអាងស្ទឹង, ចំណីបឹង, ចំណីព្រៃក ជាដើម ព្រមទាំងបន្តអនុវត្តវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះ ដើម្បីធានាចីរភាពនៃធនធានទឹក ។

២. បន្តអភិវឌ្ឍ និង ជំរុញការធ្វើទំនើបកម្មប្រព័ន្ធធារាសាស្ត្រ និង សំណង់សិល្បការទឹក តាមរយៈ ការបង្កើនទុនវិនិយោគសាធារណៈ, ការទាក់ទាញជំនួយពីដៃគូអភិវឌ្ឍ និង ការចូលរួមពីវិស័យឯកជន ក្នុងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ, ការស្រាវជ្រាវ និង ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ។

៣. បន្តស្តារ, ជួសជុល និង ថែទាំប្រព័ន្ធធារាសាស្ត្រជាប្រចាំ ដើម្បីរក្សាបាននូវអត្ថិភាព និង ចីរភាពនៃការផ្គត់ផ្គង់ទឹកសម្រាប់ស្រោចស្រពផ្ទៃដីបង្កបង្កើនផល, ជលវប្បកម្ម និង បំពេញតម្រូវការនៃការប្រើប្រាស់ប្រចាំថ្ងៃ ។

៤. បន្តជំរុញលើកទឹកចិត្ត ឱ្យប្រជាកសិករស្ម័គ្រចិត្តចូលរួមបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក

នៅតាមគ្រប់ប្រព័ន្ធធារាសាស្ត្រ ក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីលើកកម្ពស់ភាពជាម្ចាស់ ក្នុងការចូលរួមទទួលខុស-ត្រូវលើការគ្រប់គ្រង, ការប្រើប្រាស់ និង ការថែទាំ ប្រព័ន្ធធារាសាស្ត្រនោះ ។

៥. បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានជលសាស្ត្រ, ឧតុនិយមព្យាករអាកាសធាតុ និង ផ្តល់ព័ត៌មានធាតុអាកាសបានមុនហេតុការណ៍ ជាពិសេស ព័ត៌មានស្តីពីបាតុភូតគ្រោះមហន្តរាយធម្មជាតិ ដែលអាចកើតមានឡើង ដូចជា គ្រោះទឹកជំនន់, ខ្យល់ព្យុះ, រាំងស្ងួត និង រលកកម្តៅ ដល់ប្រជាជនឱ្យប្រុងប្រយ័ត្ន និង ចាត់វិធានការត្រៀមបង្ការ, បញ្ជៀស, ឆ្លើយតបទាន់ពេល និង កាត់បន្ថយផលប៉ះពាល់ ។

៩. ការអភិវឌ្ឍទឹកស្អាត

១. បន្តអភិវឌ្ឍវិស័យទឹកស្អាត ដោយឈរលើបុរេលក្ខខណ្ឌ, គុណភាព, សុវត្ថិភាព, និរន្តរភាព និង ថ្លៃសមរម្យ ។

២. បង្កើនការផ្គត់ផ្គង់ទឹកស្អាតតាមប្រព័ន្ធបណ្តាញបំពង់ទឹកស្អាតនៅទីក្រុង, ទីប្រជុំជន, តំបន់ជុំវិញទីប្រជុំជន និង ជនបទ ដែលមានលក្ខខណ្ឌសមស្រប អាចផ្តល់សេវាទឹកស្អាតតាមប្រព័ន្ធបណ្តាញ ស្របតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ ២០១៦-២០៣០ ។

៣. ពង្រីកវិសាលភាពនៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត តាមរយៈ ការពង្រឹងការអនុវត្តតួនាទី និងភារកិច្ច របស់អង្គភាពរដ្ឋាភិបាលទឹកសាធារណៈ និង ការលើកទឹកចិត្តឱ្យមានការចូលរួមដាក់ទុនវិនិយោគពីវិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត នៅតំបន់ដែលមិនទាន់មានទឹកស្អាតប្រើប្រាស់ ។

៤. បង្កើតមូលនិធិអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាត និង កៀរគរធនធានពីប្រភពនានា ដើម្បីពន្លឿនការអភិវឌ្ឍ និង បង្កើនប្រសិទ្ធភាព និង ចីរភាពនៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត, ជាពិសេស នៅតំបន់អភិវឌ្ឍ, តំបន់ងាយរងគ្រោះ និង តំបន់ដាច់ស្រយាល ។

៥. បន្តពង្រីកការភ្ជាប់បណ្តាញទឹកស្អាត និង ការលក់ទឹកស្អាតដែលមានថ្លៃទាបជូន កម្មករ-និយោជិត, សិស្ស-និស្សិត ដែលស្នាក់នៅតាមបន្ទប់ជួលតូចៗក្នុងទីក្រុង និង ទីប្រជុំជន ។

១០. ការអភិវឌ្ឍថាមពលអគ្គិសនី

១. លើកកម្ពស់ប្រសិទ្ធភាពនៃការផ្គត់ផ្គង់ និង ការប្រើប្រាស់ថាមពលអគ្គិសនី ឱ្យបានគ្រប់គ្រាន់, មានស្ថេរភាព និង អាចជឿទុកចិត្តបាន ។

២. បន្តពង្រឹង និង ជំរុញតួនាទីរបស់រដ្ឋនាំមុខ ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ថាមពលអគ្គិសនី ។

៣. បន្តអភិវឌ្ឍប្រភពអគ្គិសនី, អនុស្ថានីយ និង ខ្សែបណ្តាញគ្រប់ប្រភេទបន្ថែមទៀត ធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រង និង បញ្ជា និង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដោយលើកទឹកចិត្ត និង ជំរុញវិស័យឯកជនចូលរួមវិនិយោគ ។

៤. បន្តជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល, ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ; និង បន្តបង្កើនការប្រើប្រាស់ប្រភពថាមពលស្អាត ឱ្យបានជាអតិបរមា ដើម្បីចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និង បរិស្ថាន ។

៥. បន្តពង្រីកវិសាលភាព និង ពង្រឹងការផ្គត់ផ្គត់ថាមពលទៅកាន់តំបន់ផលិតកម្មសំខាន់ៗ ដោយ

ធានាឱ្យបាននូវប្រសិទ្ធភាព, ស្ថិរភាព និង បរិមាណគ្រប់គ្រាន់ តាមតម្រូវការ ។

៦. ខិតខំរក្សាលំនឹងថ្លៃលក់អគ្គិសនី និង ពិនិត្យលទ្ធភាពបន្ថយថ្លៃ, រួមទាំង ការអនុគ្រោះចំពោះការប្រើប្រាស់អគ្គិសនីពេលយប់ សម្រាប់វិស័យឧស្សាហកម្ម, សិប្បកម្ម និង កសិកម្ម ដើម្បីជួយកាត់បន្ថយថ្លៃដើមផលិតកម្ម និង លើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ។

៧. ជំរុញការផ្តល់សេវាតាមប្រព័ន្ធអនឡាញ សម្រាប់ការស្នើសុំសេវាផ្តត់ផ្គង់អគ្គិសនី, ការផ្តល់វិក្កយ-បត្រ, ការទូទាត់, ការផ្តល់ព័ត៌មាន និង ការទំនាក់ទំនង ឱ្យកាន់តែមានភាពងាយស្រួល, រហ័ស និង មានតម្លាភាព និង ប្រសិទ្ធភាព ។

៨. បន្តការអនុគ្រោះថ្លៃអគ្គិសនីដល់ ប្រជាជនដែលមានចំណូលទាប, បន្ទប់ជួលរបស់កម្មករ-និយោជិត, សិស្ស-និស្សិត ដែលប្រើថាមពលអគ្គិសនីមិនលើស ២០០ គីឡូវ៉ាត់ម៉ោងក្នុង ១ ខែ, សាលារៀន, មន្ទីរពេទ្យ និង មណ្ឌលសុខភាពនៅជនបទ និង អ្នកប្រើប្រាស់ថាមពលអគ្គិសនីក្នុងវិស័យកសិកម្ម ។

៩. ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងតំបន់ និង ពិភពលោក ដើម្បីផ្លាស់ប្តូរពាណិជ្ជកម្មអគ្គិសនី, ពិពិធកម្មប្រភពអគ្គិសនី និង ភាពបំពេញឱ្យគ្នាទៅវិញទៅមក តាមរយៈ ការផ្លាស់ប្តូរបទពិសោធន៍ និង ការចែក-រំលែកបច្ចេកវិទ្យាថ្មីៗ ។

១១. ការអភិវឌ្ឍធនធានរ៉ែ

១. ពង្រឹងការគ្រប់គ្រង និង ជំរុញការអភិវឌ្ឍធនធានរ៉ែ ឱ្យមានប្រសិទ្ធភាព, ចីរភាព និង អស់ពីសក្តា-នុពល ដើម្បីប្រែក្លាយធនធាននេះ ឱ្យទៅជាប្រភពថ្មីមួយទៀត សម្រាប់ចូលរួមអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង ផលប្រយោជន៍យូរអង្វែងរបស់ជាតិ ។

២. ជំរុញនិងលើកទឹកចិត្តឱ្យវិស័យឯកជនសិក្សាស្រាវជ្រាវ, ស្វែងរុករក និង វិនិយោគ ក្នុងវិស័យរ៉ែ តាមរយៈ ការរៀបចំរបបពន្ធអាករពិសេស និង លើកទឹកចិត្ត ឱ្យមានការកែច្នៃធនធានរ៉ែ និង ផលិតផលរ៉ែ ក្នុងស្រុក មុនធ្វើការនាំចេញ ស្របតាមការប្រែប្រួលតម្រូវការនៅលើទីផ្សារអន្តរជាតិ ដោយយកចិត្តទុកដាក់ខ្ពស់លើការគិត-គូរប្រើប្រាស់បច្ចេកវិទ្យាទំនើប ដើម្បីបង្កើនតម្លៃបន្ថែម និង ទាញយកផលប្រយោជន៍ជាអតិបរិមា ពីពាណិជ្ជកម្ម អន្តរជាតិ ។

៣. រៀបចំផែនការអភិវឌ្ឍវិស័យរ៉ែ ឱ្យមានសង្គតិភាពទៅនឹងផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីធានាចីរភាពនៃការផ្តត់ផ្គង់វត្ថុធាតុដើមរ៉ែសំណង់ សម្រាប់បំពេញសេចក្តីត្រូវការក្នុងស្រុក ។

៤. បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា ក្នុងសហគមន៍ដែលមានប្រតិបត្តិការធនធានរ៉ែ តាមរយៈ ការប្រើប្រាស់មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋានឱ្យមានប្រសិទ្ធភាព ដើម្បីលើកកម្ពស់ការអភិវឌ្ឍ សហគមន៍មូលដ្ឋាន និង ជីវភាពប្រជាជននៅតំបន់ទាំងនោះ ឱ្យកាន់តែប្រសើរឡើង ។

១២. ការអភិវឌ្ឍវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និង បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន

១. បន្តជំរុញការធ្វើទំនើបកម្មសេវាប្រៃសណីយ៍ តាមរយៈ ការពង្រឹងក្របខ័ណ្ឌគតិយុត្ត និង យន្តការ ក្នុងការគ្រប់គ្រងឱ្យបានច្បាស់លាស់ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាស្នូល, ការកសាងហេដ្ឋារចនាសម្ព័ន្ធ បណ្តាញប្រៃសណីយ៍ពីថ្នាក់កណ្តាលដល់ថ្នាក់ឃុំ-សង្កាត់ ឱ្យក្លាយជាប្រព័ន្ធជាតិ ដែលមានភាពប្រទាក់ក្រឡា-គ្នា និង ឆ្លើយតបទៅនឹងតម្រូវការធុរកិច្ច, សហគ្រាស និង ប្រជាជន ។

២. បន្តអភិវឌ្ឍវិស័យទូរគមនាគមន៍ តាមរយៈការជំរុញវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល មានជាអាទិ៍ ស្ថានីយអង់តែន, បណ្តាញខ្សែកាបអុបទិកក្រោមបាតសមុទ្រ, បណ្តាញខ្សែកាបអុបទិកធ្នឹងខ្នង និង ខ្សែកាបអុបទិកចែកចាយ ដើម្បីពង្រីកវិសាលភាពគ្របដណ្តប់នៃសេវាទូរគមនាគមន៍ សំដៅកាត់បន្ថយគម្លាតឌីជីថលរវាងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ និង នៅក្នុងចំណោមប្រជាជន ជាពិសេស ជំរុញការតភ្ជាប់បណ្តាញខ្សែកាបអុបទិកពីគ្រប់ក្រុង ស្រុក ខណ្ឌ ទៅដល់គ្រប់ឃុំ-សង្កាត់ ឱ្យបានត្រឹមឆ្នាំ ២០២៧ និង ការពង្រីកវិសាលភាពនៃសេវាទូរគមនាគមន៍ នៅតាមតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច និង ទេសចរណ៍, ព្រមទាំងជំរុញឱ្យប្រតិបត្តិករយកចិត្តទុកដាក់លើការពង្រឹងគុណភាពសេវា ។

៣. អភិវឌ្ឍថ្នាល និង ប្រព័ន្ធជំរុញឌីជីថល (Digital Enabler) ដើម្បីបង្កើនល្បឿននៃការអភិវឌ្ឍ និង ការធ្វើឌីជីថលូបនីយកម្មស្ថាប័នសាធារណៈ និង ឯកជន តាមរយៈ ការផ្តល់ថ្នាលនិម្មាបនកម្មរួម (Common Enterprise Architecture) ដែលអនុញ្ញាតឱ្យស្ថាប័នទាំងនោះ អាចធ្វើឌីជីថលូបនីយកម្មបានរហ័សជាងមុន និង ដោយមិនបារម្ភអំពីសុវត្ថិភាពអ្នកប្រើប្រាស់, សុវត្ថិភាពប្រព័ន្ធ និង សុវត្ថិភាពទិន្នន័យ ក៏ដូចជា ជួយបង្កើនចំនួនអ្នកប្រើប្រាស់ប្រព័ន្ធ ជាដើម ។ ថ្នាល និង ប្រព័ន្ធជំរុញឌីជីថលនេះ ក៏នឹងជួយបង្កើនល្បឿននៃការធ្វើទំនើបកម្មលើវិស័យឌីជីថលឱ្យទាន់ពេល ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ធុរកិច្ចសហគ្រាស និង ប្រជាជន ប្រកបដោយនវានុវត្តន៍, ប្រសិទ្ធភាព និង ចីរភាព ។

៤. បន្តជំរុញការកសាងមូលធនមនុស្សឌីជីថល ដើម្បីធ្វើបរិវត្តកម្មឌីជីថលឱ្យកាន់តែល្អប្រសើរឡើង ដោយផ្តោតលើ : ១). ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និង អ្នកប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាឌីជីថល ដល់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់ក្រសួង-ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដឹកនាំការងារបរិវត្តកម្មនៅតាមស្ថាប័ន និង ជំរុញការផ្តល់សេវាសាធារណៈ តាមប្រព័ន្ធឌីជីថលជូនប្រជាជន ។ ដើម្បីសម្រេចបាននូវដំណើរការឌីជីថលូបនីយកម្ម គ្រប់ក្រសួង-ស្ថាប័នរដ្ឋ ត្រូវបង្កើតអង្គភាពបរិវត្តកម្មឌីជីថល; ២). បណ្តុះបណ្តាលធនធានមនុស្សជំនាញឌីជីថលដែលមានស្រាប់ ក្នុងវិស័យឯកជន ក៏ដូចជា លើកទឹកចិត្ត និង ចូលរួមបណ្តុះបណ្តាលបុគ្គលិក ក្រុមហ៊ុនឱ្យចេះប្រើប្រាស់បច្ចេកវិទ្យាឌីជីថល; ៣). លើកកម្ពស់គុណភាពអប់រំផ្នែកបច្ចេកវិទ្យាឌីជីថល នៅតាមសាលារៀន និង សកលវិទ្យាល័យ ដើម្បីឱ្យសិស្ស-និស្សិត ក្លាយជាធនធានឌីជីថលរបស់ប្រទេសនាអនាគត; ៤). ជំរុញការផ្សព្វផ្សាយ និង ការទទួលយកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងចំណោមប្រជាជន ដើម្បីកាត់បន្ថយគម្លាតឌីជីថលរវាងទីក្រុង និង ជនបទ; និង ៥). បង្កើនសមត្ថភាព ប្រសិទ្ធភាព និង ប្រសិទ្ធផលនៃបរិវត្តកម្ម តាមរយៈ កិច្ចសហប្រតិបត្តិការជាតិ និង អន្តរជាតិ និង ការពង្រឹងការស្រាវជ្រាវ នវានុវត្តន៍ លើបច្ចេកវិទ្យាថ្មីៗ ។

៥. ជំរុញការអនុវត្តក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ឆ្នាំ ២០២១-២០៣៥ សំដៅរៀបចំឱ្យមានប្រព័ន្ធអេកូឡូស៊ីឌីជីថល ដែលមានភាពរឹងមាំធន់នឹងវិបត្តិផ្សេងៗ ព្រមទាំងឆ្លើយតបទាន់ពេលនឹងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល ដោយឈរលើសសរស្តម្ភសំខាន់ ៣ គឺ : ពលរដ្ឋឌីជីថល, រដ្ឋាភិបាលឌីជីថល និង ធុរកិច្ចឌីជីថល; និង ជំរុញការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ឆ្នាំ ២០២២-២០៣៥ ដែលផ្តោតលើចក្ខុវិស័យ "**ការកសាងរដ្ឋាភិបាលឌីជីថល ដើម្បីលើកកម្ពស់គុណភាពជីវិត និង ទំនុកចិត្តប្រជាពលរដ្ឋ តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ**" ។

១៣. ការអភិរក្ស និង ការអភិវឌ្ឍវប្បធម៌ និង សាសនា

ការអភិរក្ស និង ការអភិវឌ្ឍវប្បធម៌

១. ថែរក្សា, ការពារ អភិរក្សបេតិកភណ្ឌវប្បធម៌ជាតិ ឱ្យធានាបាននូវសុវត្ថិភាព, សុខដុមភាព និង វឌ្ឍនភាព ប្រកបដោយនិរន្តរភាព ស្របតាមទិសស្លោក "**កម្ពុជា! ព្រះរាជាណាចក្រនៃវប្បធម៌**" ។ បន្តស្នើសុំបញ្ចូលបេតិកភណ្ឌវប្បធម៌ និង ប្រវត្តិសាស្ត្រកម្ពុជា ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក, បញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ, ស្មារតីចងចាំពិភពលោក និង បណ្ណាញទីក្រុង ដែលមានភាពច្នៃប្រឌិតរបស់អង្គការយូណេស្កូ, ធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌ជាតិ ដោយបង្កើតឱ្យមានប្រព័ន្ធទិន្នន័យមូលដ្ឋានជាតិ, រៀបចំយន្តការច្បាប់, បទដ្ឋានគតិយុត្ត និង ផែនការការងារ ដែលឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងក្នុងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ទាំងរូបី និង អរូបី, រៀបចំវិធានការសមស្រប និង ទាន់ពេល ក្នុងការការពារ, ទប់ស្កាត់, ថែទាំ និង ជួសជុលសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិ ដែលប្រឈមនឹងគ្រោះថ្នាក់ ឬ ឈានទៅរកការបាត់បង់, ពង្រឹងយន្តការទាមទារយកត្រឡប់មកវិញនូវវត្ថុបុរាណខ្មែរដែលត្រូវបានលួច និង កាន់កាប់ខុសច្បាប់ទាំងក្នុង និង ក្រៅប្រទេស, ព្រមទាំង លើកកម្ពស់ការយល់ដឹង និង ការចូលរួមពីសាធារណជន ក្នុងការថែរក្សា, ការពារបេតិក-ភណ្ឌវប្បធម៌ជាតិ, ទាំងរូបី និង អរូបី ។

២. លើកស្ទួយតម្លៃវប្បធម៌ជាតិ ដោយបន្តលើកកម្ពស់ការយល់ដឹង, ការយកចិត្តទុកដាក់ និង ការ-ចូលរួមរបស់មហាជន ជាពិសេស យុវជន, ស្ត្រី និង កុមារ ក្នុងវិស័យវប្បធម៌ឱ្យបានកាន់តែច្រើនឡើង តាមរយៈការអប់រំ ការបណ្តុះបណ្តាល ដោយឈរលើគោលការណ៍ «**អប់រំដើម្បីវប្បធម៌ និង វប្បធម៌ដើម្បីអប់រំ**», ជំរុញការអប់រំ ផ្សព្វផ្សាយ និង បញ្ជ្រាបចំណេះដឹងវប្បធម៌ជូនប្រជាជន និង ជាពិសេស យុវជនក្នុងមូលដ្ឋាន និង សហគមន៍ ដើម្បីបង្កើនការចូលរួមថែរក្សា, ការពារវប្បធម៌ជាតិ, លើកកម្ពស់សីលធម៌សង្គម, រក្សាបាននូវប្រពៃណីទំនៀមទម្លាប់ជាតិ, ធ្វើឱ្យសង្គមមានរបៀបរៀបរយ និង កាត់បន្ថយសកម្មភាពអសីលធម៌ ។

៣. បន្តពង្រឹង និង ពង្រីកវិសាលភាពនៃការផ្សព្វផ្សាយវប្បធម៌ជាតិ ឱ្យកាន់តែទូលំទូលាយ តាមរយៈការសម្តែង, ការរៀបចំមហោស្រព និង ការតាំងពិព័រណ៍; ពង្រឹង និង ពង្រីកតួនាទីរបស់សារមន្ទីរ ក៏ដូចជាទីតាំងវប្បធម៌ផ្សេងៗ; បន្តសិក្សាស្រាវជ្រាវ និង ផ្សព្វផ្សាយអំពីបេតិកភណ្ឌវប្បធម៌ជាតិ ទាំងរូបី និង អរូបី; ថែរក្សា និង ការពារវប្បធម៌របស់ជនជាតិដើមភាគតិច; ជំរុញលើកកម្ពស់វិស័យភាពយន្តនៅកម្ពុជា ។

៤. បង្កើនការជួយទ្រទ្រង់ដល់សិល្បករ, ផលិតករ, អង្គការ, សមាគម និង សហគ្រិន ដែលប្រកបអាជីពក្នុងវិស័យវប្បធម៌; ជំរុញការពង្រីកទីផ្សារផលិតផលវប្បធម៌ និង ទីផ្សារការងារ ក្នុងវិស័យវប្បធម៌ និង សិល្ប:; លើកទឹកចិត្ត និង ជំរុញការច្នៃប្រឌិតបង្កើតស្នាដៃថ្មីទាំងក្នុងផ្នែកតន្ត្រី, ភាពយន្ត, សិល្ប:ទស្សនីយភាព, សិប្បកម្ម, វិចិត្រកម្ម, តម្បាញប្រពៃណី និង ការចនាច្នៃម៉ូដ; ជំរុញការរៀបចំពិព័រណ៍ស្នាដៃច្នៃប្រឌិតបង្កើតថ្មី ក្នុងវិស័យសិល្ប:វប្បធម៌; និង ជំរុញការផ្សព្វផ្សាយផលិតផលវប្បធម៌កម្ពុជា ។

ការអភិរក្ស និង ការអភិវឌ្ឍវិស័យសាសនា

១. គោរពសេរីភាពខាងជំនឿ និង ធ្វើប្រណិប័តន៍ខាងផ្លូវសាសនា; លើកស្ទួយព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ; និង គាំទ្រការគោរពប្រតិបត្តិសាសនាផ្សេងៗទៀត ក្នុងព្រះរាជាណាចក្រកម្ពុជា ។ ខិតខំធ្វើឱ្យវត្តអារាម និង វិហារសាសនាឯទៀតៗ ក្លាយជាមជ្ឈមណ្ឌលមួយនៃជីវភាពខាងស្មារតី ដែលចូលរួមសកម្ម ក្នុង

ការអភិវឌ្ឍសង្គមជាតិ ខាងផ្នែកវប្បធម៌, អប់រំ, សុខាភិបាល, សង្គមកិច្ច និង សីលធម៌សង្គម ។

២. ពង្រឹងសុខដុមនីយកម្មរវាងគ្រប់សាសនា, ជាតិសាសន៍ ក្នុងព្រះរាជាណាចក្រកម្ពុជា; រាំងស្កាត់ការធ្វើអាជីវកម្មលើសាសនា; និង ប្រឆាំងការរើសអើង, បែងចែកក្នុងប្រជាជន ដែលបណ្តាលមកពីភាពខុសគ្នាខាងជំនឿ និង សាសនា សំដៅប្រែក្លាយសក្តានុពលរបស់សាសនាទាំងអស់ ទៅជាកម្លាំងសាមគ្គីជាតិតែមួយដ៏ខ្លាំងក្លា ក្នុងការការពារសន្តិភាព, ឯកភាពជាតិ និង ជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

៣. បន្តពង្រឹង និង ពង្រីកការអប់រំពុទ្ធិកសិក្សាពីកម្រិតបឋមសិក្សា ដល់ឧត្តមសិក្សា និង ក្រោយ-ឧត្តមសិក្សា ។ ថែរក្សាមរតក ប្រពៃណី និង ទំនៀមទម្លាប់ក្នុងវិស័យពុទ្ធចក្រ; បណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យសាសនា; បណ្តុះបណ្តាលធនធានព្រះសង្ឆប្រកបដោយចំណេះដឹង ជំនាញ និង គុណធម៌, ប្រកាន់ក្រឹត្យ, វិន័យបានខ្ជាប់ខ្ជួនតាមពុទ្ធប្បញ្ញត្តិ និង ពុទ្ធានុញ្ញាត ។ ជំរុញការស្រាវជ្រាវ និង បកប្រែគម្ពីរភាសាបាលី, ក្បួនច្បាប់ព្រះពុទ្ធសាសនាជាភាសាបរទេសមកជាភាសាខ្មែរ; បន្តបោះពុម្ពគម្ពីរ, ដីកា, ព្រឹត្តិបត្រមហាសង្ក្រាន្ត, ប្រវត្តិវត្តទូទាំងប្រទេស, សៀវភៅតួនាទី, ភារកិច្ច, ក្រមសីលធម៌របស់ព្រះមេគណ, អនុគណ, ចៅអធិការ, អាចារ្យ, សៀវភៅប្រជុំបុណ្យ, ទំនៀមទម្លាប់ខ្មែរ ។ល។; បន្តជំរុញការបណ្តុះបណ្តាលធនធានមនុស្សនៃសាសនាផ្សេងៗទៀត ។

១៤. ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍវិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកទេស និង បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ

១. បន្តជំរុញការអភិវឌ្ឍធនធានមនុស្សលើគ្រប់វិស័យប្រកបដោយគុណភាព និង មានតុល្យភាពរវាងវិជ្ជាសម្បទា, បំណិនសម្បទា, ចរិយាសម្បទា, កាយសម្បទា, មនសិការស្នេហាជាតិ និង មនុស្សជាតិ ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរយៈ ការលើកកម្ពស់ការអប់រំប្រកបដោយគុណភាព, សមធម៌ និង បរិយាប័ន្ន, ព្រមទាំងការបង្កើនឱកាសទទួលបានការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា ។

២. បង្កើនគុណភាពអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារ តាមរយៈ ការយកចិត្តទុកដាក់លើគុណភាពនៃការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគ្រប់កម្រិត, ទាំងក្នុងគ្រឹះស្ថានសិក្សារដ្ឋ និង ឯកជន; ការលើកកម្ពស់សមត្ថភាព, គុណវុធិ, កិត្តិយស និង សេចក្តីថ្លៃថ្នូរគ្រូបង្រៀន និង គ្រូបច្ចេកទេស; ការបន្តអភិវឌ្ឍកម្មវិធីសិក្សា និង សៀវភៅសិក្សាគោល; ការពង្រឹងវិធីសាស្ត្របង្រៀន និង រៀនតាមនិន្នាការថ្មី; ការពង្រឹងការធ្វើអធិការកិច្ច និង ការគ្រប់គ្រងសាលារៀន; ការពង្រឹង ទំនាក់ទំនងជិតស្និទ្ធរវាងសាលា និង មាតាបិតាសិស្ស; ការពង្រឹងការប្រឡងគ្រប់ប្រភេទ; ការអនុវត្តតេស្តវាយតម្លៃលទ្ធផលសិក្សាសិស្សថ្នាក់ជាតិ និង អន្តរជាតិ; និង ការបង្កើនការស្រាវជ្រាវ និង នវានុវត្តន៍ នៅឧត្តមសិក្សា ។

៣. បន្តអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ដោយផ្តោតជាពិសេស លើការអភិវឌ្ឍកម្លាំងពលកម្មប្រកបដោយចំណេះដឹង និង ជំនាញ ដើម្បីក្លាយជាធនធានជន្ទល់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និង រក្សាភាពប្រកួតប្រជែងរបស់ជាតិ តាមរយៈ ការជំរុញការអនុវត្តកម្មវិធីបណ្តុះ-បណ្តាលជំនាញ, កម្មវិធីបណ្តុះបណ្តាលជំនាញឡើងវិញ, កម្មវិធីបង្កើនសមត្ថភាពជំនាញ, កម្មវិធីលើកកម្ពស់ផលិតភាព និង ប្រសិទ្ធភាពការគ្រប់គ្រង; ការទទួលស្គាល់ជំនាញគ្នាទៅវិញទៅមកក្នុងតំបន់អាស៊ាន និង ការទទួល-ស្គាល់សមត្ថភាពពីមុន និង សមត្ថភាពបច្ចុប្បន្នរបស់កម្មករ-និយោជិត និង ពលករទេសន្តរប្រវេសន៍ ដើម្បីធានាថា **"ប្រជាពលរដ្ឋម្នាក់ មានជំនាញមួយយ៉ាងតិចប្រចាំជីវិត"** ។

៤. បន្តពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដោយជំរុញការអនុវត្តកម្មវិធីបណ្តុះបណ្តាលផ្អែកលើសមត្ថភាព និង វិធីសាស្ត្របង្រៀនតាមបរិបទបដិវត្តន៍ឧស្សាហកម្មទី ៤; ការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ; និង ការពង្រឹងភាពជាដៃគូរវាងរដ្ឋ និង ឯកជន ដើម្បីភ្ជាប់លទ្ធផលសិក្សាស្រាវជ្រាវរបស់សិស្ស-និស្សិត យកទៅផលិត និង ប្រើប្រាស់ ក្នុងឧស្សាហកម្ម ។

៥. បន្តការកែទម្រង់វិស័យអប់រំ ដោយផ្តោតលើអាទិភាព ៨ ចំណុច រួមមាន : ១). កម្មវិធីកែទម្រង់សាលារៀន, ២). ការអភិវឌ្ឍគ្រូបង្រៀន, ៣). ការអប់រំទីជីថល, ៤). ការអប់រំវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា, ៥). ការលើកកម្ពស់សុខភាពសិក្សា, ៦). ការអភិវឌ្ឍយុវជន, ៧). ការបង្កើនមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា, និង ៨). ការកសាងប្រព័ន្ធ និង អភិវឌ្ឍសមត្ថភាព ។

៦. បន្តជំរុញការបង្កើនថ្នាក់មត្តេយ្យសិក្សាគ្រប់រូបភាព, ពង្រីកសាលាបឋមសិក្សាឱ្យបានដល់គ្រប់ភូមិ, ពង្រីកអនុវិទ្យាល័យនៅលើមូលដ្ឋានសាលាបឋមសិក្សា ដែលមានសក្តានុពលឱ្យបានដល់គ្រប់ឃុំ, បង្កើនចំនួនវិទ្យាល័យនៅតាមស្រុកនីមួយៗ, ពង្រឹងការគ្រប់គ្រងវិទ្យាល័យធនធាន, ពង្រីកចំនួនសាលាជំនាន់ថ្មីនៅគ្រប់ក្រសួង, ពង្រឹងការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និង បង្កើតមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ។ សាងសង់អគារសិក្សាថ្មី និង ជួសជុលអគារសិក្សាទ្រុឧទ្រោម; និង សាងសង់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ, បណ្ណាល័យ និង បន្ទប់កុំព្យូទ័រ និង រៀបចំទឹកស្អាត និង បង្គន់អនាម័យ ។ កាត់បន្ថយចំណាយរបស់មាតាបិតាសិស្ស; បង្កើនថវិកាសម្រាប់ដំណើរការគ្រឹះស្ថានសិក្សា; ពង្រាយគ្រូបង្រៀនឱ្យដល់គ្រប់ទីកន្លែង; ពង្រីកចំនួនអន្តេវាសិកដ្ឋាន នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

៧. លើកកម្ពស់តម្លៃវិជ្ជាជីវៈ និង កិត្តិយសគ្រូបង្រៀន តាមរយៈ ការកែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ, ការប្រារព្ធទិវាគ្រូបង្រៀនជារៀងរាល់ឆ្នាំ, ការបង្កើនបៀវត្សជូនគ្រូបង្រៀន ដើម្បីកែលម្អលក្ខខណ្ឌការងារ និងការរស់នៅ, ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ, ការអនុវត្តគន្លងអាជីពគ្រូបង្រៀន និង ការផ្តល់ **ពានរង្វាន់សម្តេចតេជោ** ជារៀងរាល់ឆ្នាំដល់សាលារៀនស្អាត, នាយកសាលាល្អ, គ្រូបង្រៀនល្អ, គ្រូបង្រៀនល្អភាសាខ្មែរ និង គណិតវិទ្យាថ្នាក់ដំបូង ។

ការលើកកម្ពស់សុខភាពប្រជាជន

១. ពង្រឹងខឿនការពារសុខភាពរបស់ប្រជាជន ដោយបន្តអភិវឌ្ឍវិស័យសុខាភិបាលសំដៅ "**ធានាឱ្យប្រជាពលរដ្ឋគ្រប់រូបរស់នៅប្រកបដោយសុវត្ថិភាព និង សុខភាពល្អ លើមូលដ្ឋានគ្រឹះដ៏រឹងមាំនៃសន្តិភាព**" ដោយផ្តោតលើគោលដៅធំ ២ : **ទី១.** ការពារអាយុជីវិតប្រជាពលរដ្ឋពីហានិភ័យនៃការរាតត្បាតនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវផ្សេងទៀតដែលអាចលេចឡើងជាយថាហេតុ ក្នុងបច្ចុប្បន្ន និង ក្នុងអនាគត; និង **ទី២.** លើកកម្ពស់សុខភាព និង សុខុមាលភាពរបស់ប្រជាពលរដ្ឋ ឱ្យកាន់តែប្រសើរឡើង ជាពិសេស ប្រជាពលរដ្ឋក្រីក្រ, ជនងាយរងគ្រោះ ដូចជា ស្ត្រី, កុមារ, វ័យជំទង់, មនុស្សចាស់ជរា, ជនមានពិការភាព តាមរយៈ ការពង្រឹងភាពធន់នៃប្រព័ន្ធសន្តិសុខសុខភាព និង ទំនើបភាវូបនីយកម្មប្រព័ន្ធផ្តល់សេវាថែទាំសុខភាព ក្នុងដំណើរឆ្ពោះទៅសម្រេចការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា នៅដំណាច់ឆ្នាំ ២០៣០ ។

២. បន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាល, ក្របខ័ណ្ឌជាតិនៃគោលដៅអភិវឌ្ឍ

ប្រកបដោយចីរភាពកម្ពុជាឆ្នាំ ២០១៦-២០៣០ តាមរយៈ ការពង្រឹងការគ្រប់គ្រងប្រព័ន្ធសុខាភិបាល ជាពិសេស ការលើកកម្ពស់ការផ្តល់សេវាថែទាំសុខភាពមានគុណភាព, សុវត្ថិភាព, ប្រសិទ្ធភាព និង សមធម៌ជូនប្រជាជននៅទូទាំងប្រទេស ដោយផ្តោតអន្តរាគមន៍ជាចម្បងលើការកាត់បន្ថយការឈឺ និង ស្លាប់របស់មាតា ទារក និង កុមារ, និង ការឈឺ និង ការស្លាប់របស់ប្រជាជនបណ្តាលមកពីជំងឺឆ្លង, ជំងឺមិនឆ្លង និង បញ្ហាសុខភាពសាធារណៈសំខាន់ៗ, ព្រមទាំងការពង្រឹងប្រព័ន្ធសុខាភិបាល តាមរយៈ ១). ការពង្រឹង និង ការពង្រីកប្រព័ន្ធផ្តល់សេវាថែទាំសុខភាព ដែលមានគុណភាព, សុវត្ថិភាព និង ប្រសិទ្ធភាពប្រកបដោយសមធម៌, និង ២). ការពង្រីកការគ្រប-ដណ្តប់នៃប្រព័ន្ធគាំពារសុខភាពសង្គម ដើម្បីកាត់បន្ថយរបាំងហិរញ្ញវត្ថុ ក្នុងការមកប្រើប្រាស់សេវាថែទាំសុខភាពជាពិសេស ប្រជាជនក្រីក្រ និង គ្រួសារមានប្រាក់ចំណូលទាប ។

៣. ពង្រឹងភាពធន់ប្រព័ន្ធសន្តិសុខសុខភាព ដោយផ្តោតជាចម្បងលើការពង្រឹងសមត្ថភាពប្រព័ន្ធសុខាភិបាលក្នុងការត្រៀមលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបទាន់ពេល ប្រកបដោយប្រសិទ្ធភាពទៅនឹងការផ្ទុះរាតត្បាតឡើងវិញនៃជំងឺកូវីដ-១៩ ឬ ការលេចឡើងនៃជំងឺឆ្លងកាចសាហាវផ្សេងៗ និង គ្រោះអាសន្ន ឬ ការគំរាមសុខភាពសាធារណៈ តាមរយៈ ការអនុវត្តសកម្មភាពសំខាន់ៗ ខាងក្រោម ៖

- បន្តផ្តល់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទាំងដូសមូលដ្ឋាន, ទាំងដូសជំរុញ ដោយឥតគិត-ថ្លៃជូនដល់ប្រជាពលរដ្ឋគ្រប់រូប;
- ជួយសម្រួលឱ្យប្រជាពលរដ្ឋអាចរកបានឧបករណ៍តេស្តហ៊ីសរកមេរោគកូវីដ-១៩ និង ឱសថ ព្យាបាលជំងឺកូវីដ-១៩ ដែលមានគុណភាព និង ប្រសិទ្ធភាពនៅលើទីផ្សារ ក្នុងតម្លៃសមស្រប, ព្រមទាំងផ្តល់ការគាំទ្របច្ចេកទេស និង ការប្រឹក្សាយោបល់ដល់អ្នកជំងឺកូវីដ-១៩ ដែលមានរោគ-សញ្ញាស្រាលនៅព្យាបាលតាមផ្ទះ;
- បង្កើនសកម្មភាពអប់រំសុខភាព និង បន្តអនុវត្តវិធានការ **«៣ការពារ និង ៣កុំ»** និង វិធានការ ចាំបាច់ផ្សេងៗទៀត;
- ត្រៀមបម្រុងធនធានគ្រប់គ្រាន់នៅតាមមូលដ្ឋានសុខាភិបាល ជាពិសេស មន្ទីរពេទ្យទូទាំងប្រទេស ដូចជា អគារ, គ្រែអ្នកជំងឺ, គ្រូពេទ្យ, បុគ្គលិក, ឱសថ, សម្ភារៈបរិក្ខារ និង ឧបករណ៍ពេទ្យ ដោយរាប់បញ្ចូលទាំងឧបករណ៍សង្គ្រោះបន្ទាន់, ឧបករណ៍សម្រាប់សេវាមន្ទីរពិសោធន៍ និង រថ-យន្តគិលានសង្គ្រោះ ដើម្បីសង្គ្រោះជីវិតអ្នកជំងឺទាន់ពេល និង មានប្រសិទ្ធភាព ក្នុងករណីជំងឺកូវីដ-១៩ ផ្ទុះឡើងវិញ ឬ ផ្ទុះជំងឺឆ្លងកាចសាហាវផ្សេងទៀត;
- គ្រប់គ្រង និង កាត់បន្ថយគ្រោះអាសន្នសុខភាពសាធារណៈ ដែលបណ្តាលមកពីចំណីអាហារគ្មានសុវត្ថិភាព, ភាពស៊ាំនៃមេរោគជាមួយឱសថផ្សះព្យាបាលជំងឺ, ការប្រើប្រាស់មិនត្រឹមត្រូវសារជាតិគីមីកម្ចាត់សត្វល្អិត, ហានិភ័យសុខភាពបរិស្ថាន និង គ្រោះមហន្តរាយដោយថាហេតុផ្សេងទៀត;
- ទប់ស្កាត់ការនាំចូលមេរោគកូវីដ-១៩ បំប្លែងខ្លួនប្រភេទថ្មីៗ ឬ ជំងឺឆ្លងកាចសាហាវផ្សេងទៀតចូលកម្ពុជា តាមរយៈ ការត្រួតពិនិត្យចត្តាឡីស័ក និង វិធានសុវត្ថិភាពនៅតាមច្រកចេញចូលប្រទេស និង ការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយប្រទេស ក្នុងតំបន់ និង សកលលោក

ដើម្បីគ្រប់គ្រងជំងឺឆ្លង និង ការគំរាមសុខភាពសាធារណៈ ស្របតាមនិយ័តកម្មសុខភាពអន្តរជាតិ (ឆ្នាំ ២០០៥) ។

៤. លើកកម្ពស់ទំនើបភាវូបនីយកម្មប្រព័ន្ធផ្តល់សេវាថែទាំសុខភាព ឆ្ពោះទៅសម្រេចការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា នៅដំណាច់ឆ្នាំ ២០៣០ ដោយផ្តោតលើ ៖

- ការលើកកម្ពស់សុខភាពបន្តពូជ, ការកាត់បន្ថយមរណភាពមាតា, ទារក និង កុមារ និង ការកែ-លម្អកង្វះអាហារូបត្ថម្ភ, ការកាត់បន្ថយការឈឺ និង ស្លាប់បណ្តាលមកពីជំងឺឆ្លងចម្បងៗ ដូចជា មេរោគអេដស៍, ជំងឺអេដស៍, ជំងឺគ្រុនចាញ់, ជំងឺរបេង និង ជំងឺមិនឆ្លង/ជំងឺរ៉ាំរ៉ៃ ដូចជា ជំងឺទឹកនោម-ផ្អែម, ជំងឺឡើងសម្ពាធឈាម, ជំងឺបេះដូងសរសៃឈាម, ជំងឺមហារីក, ជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ និង កាត់-បន្ថយហានិភ័យសុខភាពសាធារណៈចម្បងផ្សេងៗទៀត ដូចជា ជំងឺផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន-ស្រវឹង, ចំណីអាហារគ្មានសុវត្ថិភាព, របួសពិការបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍ ហានិ-ភ័យសុខភាពបរិស្ថាន ។ល។;
- ការផ្តល់សេវាថែទាំសុខភាពសាកល្បងជាប្រចាំជូនប្រជាពលរដ្ឋទូទៅ នៅគ្រប់មូលដ្ឋានសុខាភិបាល បង្កើនការអប់រំលើកកម្ពស់ការយល់ដឹង និង ការប្រតិបត្តិរបស់ប្រជាពលរដ្ឋក្នុងការបង្ការហានិភ័យនៃជំងឺ និង ការទទួលខុសត្រូវចំពោះសុខភាពផ្ទាល់ខ្លួន ព្រមទាំងការផ្លាស់ប្តូរឥរិយាបថមិនត្រឹមត្រូវក្នុងការស្វែងរកការថែទាំសុខភាពនៅពេលមានបញ្ហាសុខភាព ឬ ជំងឺផ្សេងៗ;
- ការផ្តល់សេវាថែទាំសុខភាពបឋមមានគុណភាព និង ប្រសិទ្ធភាព ស្របតាមនិយាមបច្ចេកទេស និង ទំនៀមទម្លាប់របស់ប្រជាពលរដ្ឋ នៅមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព និង ការចុះផ្តល់សេវាសុខភាពតាមមូលដ្ឋានភូមិ-ឃុំក្នុងតំបន់ជនបទនៅគ្រប់កម្រិត; និង ការថែទាំសុខភាពប្រកបដោយនវានុវត្តន៍ ក្នុងប្រព័ន្ធសុខាភិបាលទាំងមូល ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានសេវាថែទាំសុខភាពគ្រប់ជ្រុងជ្រោយ និង សេវាថែទាំបន្តប្រកបដោយគុណភាព រួមមាន សេវាបង្ការ, ការអប់រំលើកកម្ពស់សុខភាព, ការធ្វើរោគវិនិច្ឆ័យ, ការព្យាបាលថែទាំ និង ការស្តារនីតិសម្បទា នៅមណ្ឌលសុខភាព, មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ, មន្ទីរពេទ្យរាជធានី-ខេត្ត និង មន្ទីរពេទ្យជាតិ ស្រប-តាមបទដ្ឋានបច្ចេកទេស និង ក្រមសីលធម៌វិជ្ជាជីវៈ;
- ការបន្តផ្តល់សេវាថែទាំសុខភាពបឋមនៅមណ្ឌលសុខភាព និង សេវាបង្ការ ធ្វើរោគវិនិច្ឆ័យ, ព្យាបាល, ថែទាំ និង ស្តារនីតិសម្បទាដោយមិនបង់ថ្លៃ នៅតាមមន្ទីរពេទ្យរដ្ឋទូទាំងប្រទេសជូនប្រជាពលរដ្ឋក្រីក្រ និង ងាយរងគ្រោះ ដូចជា ជនមានពិការភាព, ក្មេងកំព្រា និង ជនចាស់ជរាគ្មានទីពឹង និងក្រុមប្រជាពលរដ្ឋជាគោលដៅផ្សេងទៀត តាមរយៈ កម្មវិធីមូលនិធិសមធម៌, សុខាភិបាល និង ការ-ផ្តល់សេវាពិនិត្យថែទាំផ្ទៃពោះមុន និង ក្រោយសម្រាល, ការសម្រាលកូនមានសុវត្ថិភាព និង ការ-ចាក់វ៉ាក់សាំងបង្ការជំងឺ, ការតាមដានការលូតលាស់របស់កុមារ និង អាហារូបត្ថម្ភដល់ស្ត្រីមានផ្ទៃពោះ និង កូនអាយុក្រោមពីរឆ្នាំ ក្នុងគ្រួសារក្រីក្រ នៅក្រោមកម្មវិធីប្រាក់ឧបត្ថម្ភក្នុងការពង្រីកការគ្របដណ្តប់នៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សំដៅកាត់បន្ថយហានិភ័យហិរញ្ញវត្ថុក្នុងការមកប្រើប្រាស់សេវាថែទាំសុខភាពរបស់ប្រជាពលរដ្ឋ;

- ការកសាងភាពជាដៃគូរវាងផ្នែកសាធារណៈ និង ឯកជន ក្នុងការលើកកម្ពស់សេវាបង្ការព្យាបាល និង ថែទាំសុខភាព ឈរលើគោលការណ៍ផលប្រយោជន៍សុខភាពសាធារណៈ និង ធុរកិច្ច ដោយផ្តោតលើការផ្តល់សេវាសុខាភិបាល, ការអភិវឌ្ឍសមត្ថភាពធនធានមនុស្សសុខាភិបាល និង ការ-ប្រើប្រាស់បច្ចេកវិទ្យាសុខាភិបាលឌីជីថល និង បច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ក្នុងវិស័យសុខាភិបាលប្រកបដោយសមានគតិភាព ។

ការពង្រឹងប្រព័ន្ធស្បៀង

១. បន្តលើកកម្ពស់របបអាហារសុខភាព ដើម្បីបំបែកវដ្តអន្តរជំនាន់នៃបញ្ហាអាហារូបត្ថម្ភ និង ធ្វើឱ្យ-របបអាហារសុខភាព, អាហារមានសុវត្ថិភាព, មានភាពងាយស្រួលអាចរកបាន និង មានតម្លៃសមរម្យសម្រាប់ប្រជាពលរដ្ឋកម្ពុជា ។

២. បន្តពង្រឹងភាពធន់លើមុខរបរចិញ្ចឹមជីវិត និង ភាពធន់ក្នុងប្រព័ន្ធស្បៀង ដើម្បីឆ្លើយតបទៅនឹងវិបត្តិ និង បញ្ហានានា ដែលអាចកើតឡើងជាយថាហេតុ តាមរយៈ ការធ្វើសកម្មភាពដើម្បីកាត់បន្ថយភាពក្រីក្រ, ការ-ពង្រឹងភាពធន់របស់គួអង្គពាក់ព័ន្ធ, និង ការពង្រឹងបណ្តាញការងារ និង ហេដ្ឋារចនាសម្ព័ន្ធនានា ។

៣. បន្តពង្រឹងអភិបាលកិច្ចដើម្បីធ្វើឱ្យប្រព័ន្ធស្បៀងកាន់តែមានបរិយាប័ន្ន តាមរយៈ ការបន្តរៀបចំកិច្ចសន្ទនា, ការសម្របសម្រួល និង កិច្ចសហប្រតិបត្តិការជាមួយគ្រប់គួអង្គពាក់ព័ន្ធក្នុងប្រទេស, តំបន់ និង ពិភពលោក ដើម្បីលើកកម្ពស់ប្រព័ន្ធស្បៀងឱ្យកាន់តែមានភាពរឹងមាំធន់នឹងភាពងាយរងគ្រោះ និង វិបត្តិផ្សេងៗ ឆ្លើយតបទៅនឹងតម្រូវការអ្នកប្រើប្រាស់, ការពារបរិស្ថាន និង ជួយកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាស-ធាតុ តាមរយៈការជំរុញឱ្យប្រព័ន្ធស្បៀងឆ្ពោះទៅរកការអភិវឌ្ឍបៃតង ។

១៥. ការអភិវឌ្ឍការងារ និង ប្រព័ន្ធគាំពារសង្គម

ការអភិវឌ្ឍការងារ និង មុខរបរ

១. បន្តអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និង ការងារ ដើម្បីរក្សាការងារ, បង្កើតការងារ, បង្កើនឱកាសទទួលបានការងារសមរម្យ/ផលិតភាពខ្ពស់ជូនប្រជាពលរដ្ឋ និង ធានាភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ នៅកន្លែងការងារ ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍជំនាញជាប្រចាំ ។

២. បន្តលើកកម្ពស់ជីវភាពរបស់កម្មករ-និយោជិត តាមរយៈ ការបន្តដំឡើងប្រាក់ឈ្នួលអប្បបរមា និង អត្ថប្រយោជន៍ផ្សេងៗ, ការពិនិត្យលទ្ធភាពពង្រីកវិសាលភាពប្រាក់ឈ្នួលអប្បបរមាទៅវិស័យផ្សេងៗ, ការបន្តជួយសម្រាលបន្ទុកចំណាយរបស់កម្មករ-និយោជិត ដោយបន្តពង្រីកការតបណ្តាញអគ្គិសនី និង ទឹកស្អាត ក្នុងតម្លៃសមរម្យ ជូនកម្មករ-និយោជិតនៅតាមផ្ទះជួល និង ជំរុញការអនុវត្តច្បាប់ស្តីពីភតិសន្យាពិសេស, ការបន្តលើកលែងពន្ធលើប្រាក់អត្ថប្រយោជន៍បន្ថែមរបស់កម្មករ-និយោជិត និង កែសម្រួលកម្រិតបៀវត្សអប្បបរមាត្រូវជាប់ពន្ធ និង ការធានាការបើកប្រាក់ឈ្នួល ២ ដង ក្នុងមួយខែ ព្រមទាំងការទូទាត់ប្រាក់បំណាច់អតីតភាពការងាររៀងរាល់ ៦ ខែ ម្តង ។

៣. ពង្រឹងគុណភាព និង ប្រសិទ្ធភាពអធិការកិច្ចការងារ ដោយបន្តធ្វើទំនើបកម្មប្រព័ន្ធអធិការកិច្ចការងារតាមបែបព័ត៌មានវិទ្យា; ពង្រឹង និង ពង្រីកយន្តការអធិការកិច្ចអន្តរស្ថាប័ន; ធ្វើអធិការកិច្ចការងារដោយផ្អែកលើចំណាត់ថ្នាក់ហានិភ័យ; រៀបចំស្តង់ដាប្រតិបត្តិអធិការកិច្ចការងារ និង អធិការពេទ្យការងារ; វាយតម្លៃ និង ផ្តល់

នីតិសម្បទាជាអធិការការងារ និង អធិការពេទ្យការងារជាប្រចាំ; និង គាំទ្រគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ។

៤. ពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ដោយពង្រឹងយន្តការ គុណភាព និង ប្រសិទ្ធភាពនៃការដោះស្រាយវិវាទការងារ, ពង្រឹងការអនុវត្តសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ស្របតាមច្បាប់ពាក់ព័ន្ធវិស័យការងារ និង អនុសញ្ញាអន្តរជាតិខាងការងារ, លើកកម្ពស់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈ, លើកកម្ពស់កិច្ចសន្ទនាសង្គម និង យន្តការត្រីភាគី, គាំទ្រ និង អភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ តំណាងកម្មករ-និយោជិត និង បុគ្គលទទួលបន្ទុកគ្រប់គ្រងធនធានមនុស្សនៅតាមរោងចក្រ, សហគ្រាស, រៀបចំស្តង់ដាប្រតិបត្តិស្តីពីការផ្សះផ្សាវិវាទការងារ, ពង្រឹងសមត្ថភាព និង ផ្តល់ការគាំទ្រដល់មន្ត្រីផ្សះផ្សាវិវាទការងារ, រៀបចំក្រមសីលធម៌ និង បទបញ្ជាផ្ទៃក្នុងសម្រាប់មន្ត្រីផ្សះផ្សាវិវាទការងារ, ពង្រឹងយន្តការដោះស្រាយកូដកម្ម បាតុកម្ម ក្នុងវិស័យការងារ, ជំរុញការដាក់ឱ្យដំណើរការតុលាការការងារ និង បង្កើតកម្មវិធីប្រឡងប្រណាំងថ្នាក់ជាតិលើប្រធានបទ "**សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ**" ដោយបង្កើតយន្តការថ្នាក់ជាតិមួយ ដើម្បីការពារសិទ្ធិពេញលេញ និង សេចក្តីថ្លៃថ្នូររបស់កម្មករជាទូទៅ ជាពិសេស កម្មករ ក្នុងវិស័យកាត់ដេរ និង សំណង់ ។

៥. ពង្រឹងការអនុវត្តលក្ខខណ្ឌសុវត្ថិភាព និង សុខភាពការងារ ដោយបង្កើនការយកចិត្តទុកដាក់កែ-លម្អគុណភាព និង សុវត្ថិភាពមធ្យោបាយដឹកជញ្ជូនកម្មករ-និយោជិត; កាត់បន្ថយគ្រោះថ្នាក់ការងារ; លើកកម្ពស់អនាម័យ និង សុវត្ថិភាពនៅកន្លែងធ្វើការងារ; ជំរុញការអនុវត្តឱ្យបានត្រឹមត្រូវនូវគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការដំណើរការ និង ការគ្រប់គ្រងរោងចក្រ, សហគ្រាស, គ្រប់គ្រង តាមដាន និង វាយតម្លៃស្ថានភាពជំងឺវិជ្ជាជីវៈ; និង ជំរុញការរៀបចំកន្លែងស្នាក់នៅ, កន្លែងទទួលទានអាហារ ឬ អាហារដ្ឋាន ដែលមានតម្លៃសមរម្យ នៅក្នុងរោងចក្រ និង តាមសួនឧស្សាហកម្ម ឬ តំបន់សេដ្ឋកិច្ចពិសេស ។

៦. បន្តពង្រឹងអភិបាលកិច្ចទីផ្សារការងារ និង បង្កើនសេវារកការងារឱ្យធ្វើក្នុងស្រុកដល់ប្រជាពលរដ្ឋ ដោយពង្រឹងសេវាកម្មរបស់ទីភ្នាក់ងារជាតិមុខរបរ និង ការងារ; បង្កើនកិច្ចសហការជាមួយឃុំ-សង្កាត់ និង ដៃគូពាក់ព័ន្ធនានា ក្នុងការផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ; និង ពង្រឹងយន្តការគ្រប់គ្រងហត្ថពលកម្មបរទេស និង បង្ការការជួញដូរកម្លាំងពលកម្មឆ្លងដែនខុសច្បាប់ ដោយតម្រូវឱ្យជនបរទេសត្រូវមានកិច្ចសន្យាការងារ និង លិខិតអនុញ្ញាតការងារជាមុន មុននឹងចូលមកស្វែងរក ឬ ប្រកបមុខរបរ និង ការងារនៅកម្ពុជា ស្របតាមបទដ្ឋានអនុសញ្ញាអន្តរជាតិស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរពលកម្មឆ្លងដែន ។

៧. ពង្រឹងប្រសិទ្ធភាពការអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារ ដោយពង្រឹង និង បង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាមិត្ត ដើម្បីបើកទូលាយទីផ្សារការងារបន្ថែម; ព្រមទាំងការពារ, លើកកម្ពស់សិទ្ធិ, ផលប្រយោជន៍, សេចក្តីថ្លៃថ្នូរ និង ជំរុញការធ្វើចល័តភាពរបបសន្តិសុខសង្គមរបស់ពលករកម្ពុជាពេលវិលត្រលប់មកស្រុកកំណើតវិញ ។ យកចិត្តទុកដាក់ជួយកូនចៅនៃពលករទេសន្តរប្រវេសន៍កម្ពុជាឱ្យទទួលបានការអប់រំសមរម្យនៅបណ្តាប្រទេសទទួលពលករ និង ឧបត្ថម្ភគាំទ្រដល់គ្រួសារពលករនៅពេលជួបគ្រោះមហន្តរាយជាយថាហេតុ ។

៨. បន្តគាំទ្រ និង អភិវឌ្ឍមុខរបរជូនប្រជាពលរដ្ឋ ដោយបញ្ជ្រាបចំណេះដឹងមូលដ្ឋានអំពីសហ-គ្រិនភាព, ទំនាក់ទំនងវិជ្ជាជីវៈ និង ការប្រកបមុខរបរ និង ការងារដល់សិស្សថ្នាក់វិទ្យាល័យ, ព្រមទាំងបញ្ជ្រាបនូវ

បច្ចេកទេស និង វិធីសាស្ត្រកែច្នៃកសិផល និង ផលិតផលជូនប្រជាពលរដ្ឋនៅតាមសហគមន៍ ។

៩. លើកកម្ពស់តួនាទី, កិត្តិយស និង សេចក្ដីថ្លៃថ្នូររបស់សហគ្រិន និង កម្មករ-និយោជិតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ, គាំទ្រដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការរៀបចំគោលនយោបាយលើកទឹកចិត្តនានា និង បង្កើនភាព-ងាយស្រួលក្នុងការចុះបញ្ជីសហគ្រាស និង ស្នើសុំឯកសារនានា ។

ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម

ក. ប្រព័ន្ធជំនួយសង្គម

១. បង្កើនអន្តរាគមន៍សង្គមកិច្ច តាមរយៈ មូលនិធិជាតិជំនួយសង្គមប្រកបដោយបរិយាប័ន្ន, ប្រសិទ្ធ-ភាព, ចីរភាពហិរញ្ញវត្ថុ និង គោលការណ៍វដ្ដនៃជីវិត; និង យកចិត្តទុកដាក់បង្កើតឱ្យមានបុគ្គលិកសង្គមកិច្ចស្ម័គ្រ-ចិត្ត (កម្លាំងសេវាសង្គម) ដើម្បីពង្រឹកសមត្ថភាពផ្ដល់កិច្ចគាំពារ និង សង្គ្រោះបន្ទាន់ដល់ប្រជាជនក្រីក្រ, ជនងាយ-រងគ្រោះ និង ជនរងគ្រោះដោយគ្រោះមហន្តរាយនានា ។

២. បន្តពង្រឹកកម្មវិធីដោះស្រាយបញ្ហាជនអនាថា និង ជនវិបល្លាសស្មារតី ឱ្យទទួលបានសេវាសង្គមកិច្ច និង សេវាស្ថាប័នវេជ្ជសាស្ត្រផ្នែកសុខភាពផ្លូវចិត្ត, ព្រមទាំងការជួយធ្វើសមាហរណកម្ម ទៅក្នុងសហគមន៍ និង គ្រួសារវិញ ។ ពង្រឹងការគ្រប់គ្រងការធ្វើចំណាកស្រុកដោយប្រជុយប្រជាន និង ពង្រឹងសេវាមណ្ឌលសំចតពលករ នៅតាមព្រំដែន ។

៣. ជំរុញ និង លើកទឹកចិត្តការបង្កើតកម្មវិធីមនុស្សធម៌នានា ដើម្បីរួមចំណែកអភិវឌ្ឍសហគមន៍ក្រីក្រ និង កសាងលំនៅឋានជូនប្រជាជនក្រីក្រ, ជនងាយរងគ្រោះ និង ជនមានពិការភាព ស្របតាមស្មារតីវប្បធម៌ចែករំលែក ។

៤. បន្តប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និង បង្កើនការជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សតាមរូបភាពផ្សេងៗ ដូចជា ទេសន្តរប្រវេសន៍ការងារខុសច្បាប់, ការរៀបអាពាហ៍ពិពាហ៍ឆ្លងប្រទេស ។ល។

៥. បន្តជួយប្រជាជនក្រីក្រ និង ជនងាយរងគ្រោះ តាមរយៈ ការពង្រឹងមូលនិធិសមធម៌សុខាភិបាល, កម្មវិធីជំនួយសង្គម និង កម្មវិធីកញ្ចប់គ្រួសារ ដែលរួមមាន : ១). ការឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីមានផ្ទៃពោះ និង កុមារក្រោម២ឆ្នាំ, ការឧបត្ថម្ភដល់មនុស្សវ័យចាស់ចាប់ពីអាយុ ៦០ ឆ្នាំឡើង, ជនមានពិការភាព និង ជនផ្ទុកមេ-រោគអេដស៍ក្នុងគ្រួសារក្រីក្រ, និង ការផ្ដល់អាហារនៅតាមសាលារៀន និង អាហារូបករណ៍ដល់សិស្សក្រីក្រពីថ្នាក់ទី ១ ដល់ថ្នាក់ទី ១២; ២). ការរៀបចំកម្មវិធីបង្កើតមុខរបរដល់គ្រួសារក្រីក្រ និង ងាយរងគ្រោះ; ៣). ការរៀបចំកម្មវិធីស្ពានចម្លងសេវាសង្គម ដែលប្រែក្លាយបុគ្គលមិនមានវិជ្ជាជីវៈជាមន្ត្រីសង្គមកិច្ច ឱ្យក្លាយទៅជាមន្ត្រីសង្គម-កិច្ចអាជីព សម្រាប់ជួយផ្ដល់សេវាសង្គមកិច្ចនៅតាមសហគមន៍; និង ៤). សិក្សាលទ្ធភាពផ្ដល់សាច់ប្រាក់ដល់យុវជននៃគ្រួសារក្រីក្រ ក្នុងកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

៦. បន្តជំរុញកិច្ចការពារ និង លើកកម្ពស់សុខុមាលភាព និង សិទ្ធិជនមានពិការភាព តាមរយៈ ការ-កំណត់ អត្តសញ្ញាណកម្មជនមានពិការភាពឡើងវិញ, ការបង្កើនគុណភាពការផ្ដល់សេវាស្ថារលទ្ធភាពពលកម្ម, ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ, ការជួយលើកទឹកចិត្តការកកការងារធ្វើ និង ការឧបត្ថម្ភ ជនមានពិការភាពក្រីក្រតាមសហគមន៍ ។ បន្តជំរុញការទទួលយកជនមានពិការភាពចូលធ្វើការតាមស្ថាប័នរដ្ឋ, ឯកជន និង សង្គមស៊ីវិល ស្របតាមច្បាប់ និង លិខិតបទដ្ឋានពាក់ព័ន្ធនឹងសិទ្ធិជនមានពិការភាព ។ រៀបចំដំណើរការមជ្ឈមណ្ឌលជាតិជនមាន

ពិការភាព ដើម្បីប្រមូលផ្តុំសេវាកម្មសម្រាប់ជនមានពិការភាព ឱ្យមានលក្ខណៈស្តង់ដា ។

៧. បន្តអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ដោយបន្តជំរុញការអនុវត្តកម្មវិធីអភិវឌ្ឍមនុស្សវ័យចាស់សកម្មតាមសហគមន៍ និង កម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារឱ្យបានប្រសើរ ។ ពង្រឹង និង គាំទ្រសកម្មភាពសមាគមមនុស្សចាស់នៅតាមឃុំ-សង្កាត់ លើកទឹកចិត្តការបង្កើតកម្មវិធីមនុស្សធម៌នានា ដើម្បីជួយដល់ជនចាស់ជរា ។ ជំរុញការរៀបចំ, គ្រប់គ្រង និង ដំណើរការសេវាជនចាស់ជរា ដើម្បីបណ្តុះបណ្តាលក្នាក់ងារផ្តល់សេវាថែទាំជនចាស់ជរា ។

៨. បន្តជំរុញ និង លើកកម្ពស់ការងារយុវនីតិសម្បទា និង កម្មវិធីយុត្តិធម៌អនីតិជន តាមរយៈការ-បង្ការ, ទប់ស្កាត់, ព្យាបាល និង ស្តារនីតិសម្បទាជនរងគ្រោះ ដែលប្រើប្រាស់បំពានសារធាតុញៀនតាមមណ្ឌល និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍; ព្រមទាំងលើកទឹកចិត្ត និង គាំទ្រកម្មវិធីព្យាបាល និង ស្តារនីតិសម្បទាជនរងគ្រោះ ដែលប្រើប្រាស់បំពានសារធាតុញៀននៅតាមសហគមន៍ និង នៅតាមគ្រួសារ។

ខ. ប្រព័ន្ធសន្តិសុខសង្គម

១. បន្តពង្រឹងប្រព័ន្ធសន្តិសុខសង្គមឱ្យកាន់តែរឹងមាំ តាមរយៈ ការពង្រឹងបេឡាជាតិសន្តិសុខសង្គមនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ, បេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល, បេឡាជាតិអតីតយុទ្ធជន, មូលនិធិជនមានពិការភាព, មូលនិធិសមធម៌សុខាភិបាល និង មូលនិធិគន្ធបុប្ផា ។

២. បន្តពង្រឹងយន្តការប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ប្រព័ន្ធសោធន និង អត្ថប្រយោជន៍ផ្សេងៗនៃការ-បើកផ្តល់របបសន្តិសុខសង្គមជូនអតីតមន្ត្រីរាជការស៊ីវិល, អតីតយុទ្ធជន ព្រមទាំងគ្រួសារ និង អ្នកនៅក្នុងបន្ទុកឱ្យបានទាន់ពេល ។

៣. បន្តអនុវត្តគោលនយោបាយតម្រូវឱ្យនិយោជកមានកាតព្វកិច្ចបង់ភាគទានជំនួសកម្មករ-និយោជិត ១០០% សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និង ផ្នែកថែទាំសុខភាព និង បន្តសិក្សាលទ្ធភាពដាក់ឱ្យដំណើរការរបបនិកម្មភាពការងារ ។

៤. បន្តអនុវត្តគោលនយោបាយរដ្ឋបង់ភាគទានជំនួសមន្ត្រីសាធារណៈ ចំពោះរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ, ផ្នែកថែទាំសុខភាព និង ផ្នែកប្រាក់សោធន និង បង់ជំនួសអតីតមន្ត្រីរាជការ និង អតីតយុទ្ធជន, ព្រមទាំងអ្នកនៅក្នុងបន្ទុកចំពោះរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ។

៥. បន្តពង្រឹងគុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាលនៅតាមមូលដ្ឋានសុខាភិបាលជាដៃគូបេឡាជាតិសន្តិសុខសង្គម ។

៦. រៀបចំគោលនយោបាយ និង លិខិតបទដ្ឋានគតិយុត្ត ដើម្បីពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គម ដល់សហគ្រិន និង កម្មករនិយោជិតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និង អ្នកស្ម័គ្រចិត្តដទៃផ្សេងទៀត ។

៧. សិក្សាលទ្ធភាពក្នុងការប្រើប្រាស់មូលនិធិបេឡាជាតិសន្តិសុខសង្គម ដើម្បីវិនិយោគលើគម្រោងដែលមានហានិភ័យទាប សំដៅបង្កើនអត្ថប្រយោជន៍បន្ថែមដល់សមាជិក ។

៨. ជំរុញការពិភាក្សា និង ចុះកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសនានា ដើម្បីផ្លាស់ប្តូរទិន្នន័យសន្តិសុខសង្គមផ្នែកសោធន សំដៅអនុវត្តចល័តភាពនៃរបបសន្តិសុខសង្គមពីប្រទេសមួយទៅប្រទេសមួយ។

១៦. ការលើកកម្ពស់ស្ថានភាពស្ត្រី និង កុមារ, ការអភិវឌ្ឍយុវជន និង កីឡា

ការលើកកម្ពស់ស្ថានភាពស្ត្រី និង កុមារ

១. បន្តយកចិត្តទុកដាក់លើកស្ទួយតម្លៃស្ត្រីខ្មែរក្នុងសង្គម, លើកកម្ពស់ស្ថានភាព, តួនាទី និង សិទ្ធិស្ត្រីនៅក្នុងសង្គម និង លុបបំបាត់រាល់ទស្សនៈ ឬ ឥរិយាបថរើសអើងចំពោះស្ត្រី និង ជនងាយរងគ្រោះ ដើម្បីធានាសម្រេចបាននូវសមភាពយេនឌ័រ និង បរិយាប័ន្ននៅក្នុងការអភិវឌ្ឍ ។

២. ជំរុញការបញ្ជាបយេនឌ័រទៅក្នុងក្របខ័ណ្ឌគោលនយោបាយ និង កម្មវិធីជាតិ រួមទាំងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ, កម្មវិធីកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌, ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម, និង កម្មវិធីប្រែប្រួលអាកាសធាតុ និង អភិវឌ្ឍបៃតង ។

៣. លើកកម្ពស់ការចូលរួម និង ពង្រឹងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងវិស័យសាធារណៈ:វិស័យឯកជន និង នយោបាយ ។ ពង្រឹងភាពអង់អាចស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច តាមរយៈ ការអភិវឌ្ឍសហគ្រិនភាពរបស់ស្ត្រី, ការគាំទ្រស្ត្រីដែលដឹកនាំ និង គ្រប់គ្រងអាជីវកម្មខ្នាតមីក្រូ តូច និង មធ្យម, ការលើកកម្ពស់ចំណេះដឹង និង ជំនាញ, ការលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ស្ត្រី និង សេដ្ឋកិច្ចដែលគិតគូរដល់សុខុមាលភាព, ការការពារសិទ្ធិរបស់ស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ចក្នុង និង ក្រៅប្រព័ន្ធ និង ការលើកកម្ពស់កម្មវិធីតុល្យភាពជីវិត ការងារ និង គ្រួសារ ។

៤. ទប់ស្កាត់អំពើហិង្សាគ្រប់រូបភាពលើស្ត្រី និង ក្មេងស្រី តាមរយៈ ការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី, ការពង្រីកវិសាលភាពសេវាជួយជនរងគ្រោះ និង ការពង្រឹងការអនុវត្តច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។ លើកកម្ពស់សីលធម៌សង្គម, តម្លៃស្ត្រី និង គ្រួសារខ្មែរ តាមរយៈ ការបន្តអនុវត្តកម្មវិធីមាតាបិតាភាព, ការអប់រំកូនតាមបែបវិជ្ជមាន, ការពង្រីកវប្ប‌ធម៌អហិង្សា និង ការកសាងគ្រួសារ ប្រកបដោយសុភមង្គលនៅក្នុងសង្គម ។

៥. លើកកម្ពស់ប្រព័ន្ធសុវត្ថិភាពដើម្បីសុខុមាលភាព និង សិទ្ធិរបស់កុមារ ជាពិសេសកុមារ ដែលបានបាត់បង់ឪពុកម្តាយ ឬ អាណាព្យាបាលធ្វើទេសន្តរប្រវេសន៍រយៈពេលយូរ ដោយជំរុញឱ្យទទួលបានការអប់រំ និង អនុវត្តយ៉ាងម៉ត់ចត់នូវអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ សំដៅធានាសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺ **«សិទ្ធិរស់រានមានជីវិត, សិទ្ធិទទួលបានការអភិវឌ្ឍ, សិទ្ធិទទួលបានការការពារ និង សិទ្ធិចូលរួមរបស់កុមារ»** ។ យកចិត្ត-ទុកដាក់ថែទាំអប់រំកុមារឱ្យក្លាយជា **«កូនល្អ សិស្សល្អ និង មិត្តល្អ»** ដែលជាអនាគតពលរដ្ឋល្អ ។

៦. ពង្រឹងការអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ, ការថែទាំកុមារតាមគ្រួសារកំណើត គ្រួសារសាច់ញាតិ និង គ្រួសារធម៌ ក្នុងសហគមន៍សំដៅទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់, បង្កើនការគ្រប់គ្រងគុណភាពនៃការថែទាំកុមារនៅតាមមណ្ឌលរដ្ឋ និង មណ្ឌលនៃអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងសិក្សាលទ្ធភាពបង្កើតមណ្ឌលថែទាំកុមាររយៈពេលថ្ងៃគ្រប់រូបភាព ។ ពង្រឹងកិច្ចការពារកុមារ, ទប់ស្កាត់ និង ឆ្លើយតបចំពោះអំពើហិង្សាលើកុមារ, ទាំងក្នុងគ្រួសារកំណើត គ្រួសារសាច់ញាតិ គ្រួសារធម៌ និង សហគមន៍ ។ ជំរុញការរៀបចំច្បាប់ស្តីពីកិច្ចការពារកុមារ និង អនុវត្តដោយម៉ឹងម៉ាត់នូវអនុសញ្ញាអន្តរជាតិ និង ច្បាប់ជាធរមាន ដើម្បីរកគ្រួសារល្អ នៅក្នុង និង ក្រៅប្រទេស សម្រាប់កុមារ, រាំងស្កាត់ការធ្វើអាជីវកម្មកុមារ តាមគ្រប់រូបភាព និង ទប់ស្កាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និង ការងារដោយបង្ខំ ។

ការអភិវឌ្ឍយុវជន និង កីឬា

១. អភិវឌ្ឍយុវជនលើគ្រប់ទិដ្ឋភាព និង តាមគ្រប់រូបភាព រួមមាន : ១). កម្មវិធីអភិវឌ្ឍយុវជន, ទាំងបំណិនរឹង និង បំណិនទន់, ដោយផ្តោតលើបំណិនសតវត្សទី ២១ និង លើកកម្ពស់ភាពជាអ្នកដឹកនាំ; ២). ការ-បង្កើតទំនាក់ទំនងល្អរវាងយុវជន និង យុវជន និង លើកកម្ពស់តម្លៃមិត្តភាព; ៣). ការបង្កើតថ្នាល សម្រាប់យុវជនហាត់ការឱ្យមានភាពរឹងមាំ, មានភាពចាស់ទុំគំនិត និង ចេះគិតយ៉ាងហ្មត់ចត់; ៤). ការជំរុញចលនាកាយឬទ្ធិ, ក្រុម-ប្រឹក្សាកុមារ, ក្រុមប្រឹក្សាយុវជន, យុវជនកាកបាទក្រហម ឱ្យចូលរួមសកម្មក្នុងការអភិវឌ្ឍសង្គម ព្រមទាំងការពង្រីកស្មារតីមនុស្សធម៌ និង ការទទួលខុសត្រូវចំពោះខ្លួនឯង, គ្រួសារ និង សង្គម; និង ៥). ការបណ្តុះយុវជនឱ្យក្លាយជាពលរដ្ឋល្អ, មានបំណិន, មានបុគ្គលិកលក្ខណៈពេញលេញ, ទាំងផ្នែករាងកាយ បញ្ញា ស្មារតី សីលធម៌ និង តម្លៃ, មានស្មារតីស្រឡាញ់ជាតិ សកម្មចូលរួមក្នុងការកសាង ការពារមាតុភូមិ និង ការអភិវឌ្ឍសង្គម, ព្រមទាំងការលើកកម្ពស់ការអប់រំភាពជាពលរដ្ឋសកល ដើម្បីក្លាយជាធនធានមនុស្សប្រកបដោយចំណេះដឹង, ជំនាញ, វិន័យ សីលធម៌ ចរិយាសម្បត្តិ, ការគិតបែបវិជ្ជមាន, ចេះស្រឡាញ់គ្រួសារ វប្បធម៌ ប្រពៃណី ជាតិមាតុភូមិ ដែលជាបំណងប្រាថ្នារបស់ឪពុកម្តាយ, សង្គមជាតិ និង និយោជក ។

២. ជំរុញការបោះជំរំវិទ្យាសាស្ត្របច្ចេកវិទ្យា, លើកកម្ពស់ការអនុវត្តកម្មវិធីអប់រំសហគ្រិនភាព; ពង្រីកចលនាយុវជនស្ម័គ្រចិត្តនៅក្នុងសាលា និង នៅតាមសហគមន៍; ពង្រឹងការផ្តល់កម្មវិធីប្រឹក្សាអាជីពមុខរបរ, ការ-តម្រង់ទិសការសិក្សាដល់យុវជន និង ការផ្តល់សេវាព័ត៌មានទីផ្សារការងារ ដល់យុវជននៅក្នុងសាលា និង យុវជននៅតាមសហគមន៍ សំដៅលើកកម្ពស់តួនាទីរបស់យុវជនក្នុងវិស័យសេដ្ឋកិច្ច ។

៣. បង្កើនការចូលរួមរបស់យុវជនក្នុងការដឹកនាំ និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង ការពារារាល់សមិទ្ធផលសង្គម តាមរយៈការបន្តអនុវត្តជាជំហានៗនូវទិសដៅយុវភាវូបនីយកម្ម ក្នុងការផ្តល់ការទទួលខុសត្រូវនៅគ្រប់លំដាប់ថ្នាក់ ។ បង្កលក្ខណៈឱ្យយុវជនបានចូលរួមពេញលេញក្នុងកិច្ចការសហគមន៍នៃមូលដ្ឋាន និង ស្ថាប័ននានា ។ ជំរុញឱ្យមានតំណាងយុវជនក្នុងគណៈកម្មការ ឬ ក្រុមប្រឹក្សានៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់សិទ្ធិក្នុងការចូលរួម, ការសម្តែងមតិ និង ការសម្រេចចិត្តរបស់យុវជន ដោយផ្អែកលើការទទួលបានព័ត៌មានត្រឹមត្រូវ ។ ជំរុញការបញ្ជាបសេចក្តីត្រូវការរបស់យុវជន នៅក្នុងគោលនយោបាយ និង ផែនការអភិវឌ្ឍគ្រប់វិស័យ និង គ្រប់កម្រិត ។

៤. បន្តលើកកម្ពស់វិស័យកីឬាជាវិស័យអាទិភាពមួយរបស់ជាតិ ដើម្បីកសាងមនុស្សគ្រប់រូបឱ្យមានសុខភាព និង សុខុមាលភាពល្អ, កាយសម្ព្ធទាមាំមួន, ឆន្ទៈមោះមុត, អំណត់ព្យាយាម, មានវិន័យ, មានស្មារតីជាក្រុម, គំនិតច្នៃប្រឌិត និង មានការតស៊ូស្វិតស្វាញ សំដៅដណ្តើមបានលទ្ធផលល្អប្រសើរ ក្នុងការប្រកួតកីឬាលើឆាកអន្តរជាតិ និង មានជវភាពស្របតាមពាក្យស្លោក "**កីឬារស់ប្រកបដោយសុខដុមរមនាក្នុងសង្គម ក្រោមម្លប់សន្តិភាព**" ។

៥. ជំរុញការអនុវត្តការកែទម្រង់ស៊ីជម្រៅវិស័យអប់រំកាយ និង កីឬា តាមរយៈ ការពង្រឹងការគ្រប់-គ្រងវិស័យអប់រំកាយនិងកីឬា និង ការពង្រឹងយន្តការដែលមានស្រាប់ ដើម្បីអភិវឌ្ឍវិស័យអប់រំកាយ និង កីឬា, ទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឬា ទាំងការបណ្តុះបណ្តាលធនធានមនុស្ស និង ការលើកទឹកចិត្ត, ដែលជាកត្តាចម្បងក្នុងការបង្កើនប្រសិទ្ធភាព និង គុណភាពនៃការត្រៀមខ្លួនរបស់អត្តពលិក និង ការពង្រឹង គុណភាពនៃ

ការប្រកួតគ្រប់កម្រិត តាមរយៈ ការពង្រឹងសហព័ន្ធកីឡាជាតិ ការពង្រឹងការអនុវត្តកម្មវិធីអប់រំកាយនិងកីឡា ក្នុងម៉ោងសិក្សា និង ការពង្រឹងការអនុវត្តកម្មវិធីកីឡាក្រៅម៉ោងសិក្សា ។

៦. ជំរុញការលើកទឹកចិត្ត និង បណ្តុះវប្បធម៌អប់រំកាយ និង កីឡា ដល់ប្រជាជនឱ្យយល់ដឹងអំពីសារៈ-សំខាន់នៃការហាត់ប្រាណ និង លេងកីឡាជាប្រចាំ ដើម្បីសុខភាពផ្សារភ្ជាប់នឹងកិច្ចការសង្គម វប្បធម៌ និង ដើម្បីចូលរួមលុបបំបាត់ភាពអសកម្មផ្សេងៗនៅក្នុងសង្គម សំដៅឱ្យប្រជាជនរស់នៅប្រកបដោយភាពស៊ីវិល័យ និងសុខដុមនីយកម្មក្នុងសង្គម តាមគោលការណ៍ "**ប្រជាជនម្នាក់លេងកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត**" ។

១៧. ការការពារជាតិ ការការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម

ការការពារជាតិ

១. ពង្រឹងខឿនការពារជាតិរបស់ប្រជាជនឱ្យរឹងមាំខ្លាំងក្លា ដែលមានកងយោធពលខេមរភូមិន្ទជា-ស្នូល ដើម្បីធានាការការពារសន្តិភាព, ឯករាជ្យ, អធិបតេយ្យ, បូរណភាពទឹកដីឱ្យបានគង់វង្ស, ស្ថិតស្ថេរគ្រប់កាលៈទេសៈ ធ្វើឱ្យប្រជាជនបានរស់នៅដោយសុខដុមរមនាលើទឹកដីរបស់ខ្លួន និង មានឱកាសពេញលេញសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

២. បន្តជំរុញការកែទម្រង់កងយោធពលខេមរភូមិន្ទ លើកកម្ពស់ការកសាងបណ្តុះបណ្តាលធនធានមនុស្ស ការអភិវឌ្ឍសមត្ថភាពកងទ័ពទាំងវិជ្ជាជីវៈ ទាំងស្មារតី និង សម្ភារៈ, បច្ចេកទេស, យុទ្ធោបករណ៍, ភ័ស្តុភារ និងហិរញ្ញវត្ថុ សំដៅឈានទៅធ្វើទំនើបកម្មកងទ័ព ឱ្យឆ្លើយតបនឹងភាពជឿនលឿននៃបច្ចេកវិទ្យាទំនើប និង ការធ្វើនវានុវត្តយោធាក្នុងតំបន់ និង លើពិភពលោក ព្រមទាំងធានាចីរភាពនៃការអភិវឌ្ឍវិស័យការពារជាតិ ។ លើមូលដ្ឋាននេះ ធានាបានការកសាងកងកម្លាំងប្រដាប់អាវុធមួយ ដែលមានឧត្តមគតិស្នេះត្រង់ចំពោះជាតិមាតុភូមិ និងមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការការពារបូរណភាពទឹកដី, ការពាររាជរដ្ឋាភិបាល ដែលកើតចេញពីឆន្ទៈប្រជាជន តាមរយៈ ការបោះឆ្នោត និង ការការពាររាល់សមិទ្ធផលសង្គមជាតិ ។

៣. អភិវឌ្ឍ, ពង្រឹង និង ពង្រីកកងយោធពលខេមរភូមិន្ទជាកម្លាំងដ៏សំខាន់ចូលរួមក្នុងការថែរក្សាសន្តិសុខជាតិ, ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម, ការកសាងហេដ្ឋារចនាសម្ព័ន្ធ, ការការពារធនធានធម្មជាតិ, ការ-បោសសម្អាតមីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះ និង ការជួយសង្គ្រោះប្រជាជន ពេលកើតមានគ្រោះមហន្តរាយផ្សេងៗ ដូចជា គ្រោះទឹកជំនន់, គ្រោះរាំងស្ងួត, ជំងឺឆ្លងរាតត្បាត ជាដើម ។

៤. ពង្រឹងប្រៀបយុទ្ធសាស្ត្រការពារជាតិ, ធានាកិច្ចការពារយ៉ាងរឹងមាំនូវអធិបតេយ្យ និង បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា លើដែនគោក, ដែនអាកាស, ដែនទឹក, កោះ, ផ្ទៃ, ដែនសមុទ្រ, តំបន់តភ្ជាប់, តំបន់សេដ្ឋកិច្ចផ្តាច់មុខ និង ខ្ពង់រាបបាតសមុទ្រ ។ កសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវយុទ្ធសាស្ត្រខ្សែព្រំដែន, កសាងភូមិ ឃុំ និង អភិវឌ្ឍសហគមន៍ប្រជាពលរដ្ឋនៅតាមព្រំដែន និង យកចិត្តទុកដាក់បង្កើត និង អភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រយោធានៅតាមព្រំដែន សំដៅលើកកម្ពស់ការពង្រឹងយុទ្ធសាស្ត្រការពារព្រំដែនយូរអង្វែងដែលជាមូលដ្ឋានរឹងមាំមួយ សម្រាប់កិច្ចការពារបូរណភាពទឹកដី និង កសាងព្រំដែនជាតំបន់សន្តិភាព, មិត្តភាព, សហប្រតិបត្តិការ និងការអភិវឌ្ឍ ព្រមទាំងប្រែក្លាយអតីតសមរភូមិជាតំបន់ផលិតកម្ម, ទីផ្សារ និង ទេសចរណ៍ ។

៥. កសាងតំបន់ប្រវត្តិសាស្ត្រយោធា, វិមានរំលឹកគុណ និង ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ-ឈ្នះនៅតាមទីតាំងប្រវត្តិសាស្ត្រនានា ដើម្បីចារិកទុក និង តម្កល់និមិត្តរូបវត្ថុតាង និង សមិទ្ធផលនានាសម្រាប់ជាថ្នាល

បណ្តុះមនសិការ "**កតញ្ញូ សុខដុម និង ការចូលរួម**" និង ជាមេរៀនសម្រាប់អ្នកជំនាន់ក្រោយចងចាំ, រៀនសូត្រ, គោរព ដឹងគុណ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ស្ថាបនិកមគ្គុទ្ទេសក៍ឯក និង ប្រតិបត្តិការនយោបាយ ឈ្នះ-ឈ្នះ ដែលបាននាំមកនូវសន្តិភាព និង ការឯកភាពជាតិ ឯកភាពទឹកដីទាំងស្រុង ព្រមទាំងចងចាំនូវគុណូប-ការៈដ៏ថ្លៃថ្លារបស់យុទ្ធជន, យុទ្ធនារីស្នេហាជាតិ ដែលបានធ្វើពលិកម្មប្រកបដោយវីរភាព ដើម្បីជាតិមាតុភូមិ ។

៦. ធានាប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយនានា ដើម្បីលើកកម្ពស់ជីវភាពកងទ័ព, ជីវភាពយោធិនពិការ, យោធិនចូលនិវត្តន៍, យោធិនបាត់បង់សមត្ថភាពការងារ, គ្រួសារយោធិនពលីមរណៈ និង អតីតយុទ្ធជន ។ បង្កើនការអប់រំ នយោបាយ, ចិត្តសាស្ត្រ ក្នុងជួរកងទ័ពឱ្យមានឆន្ទៈមោះមុត, ជាកម្លាំងការពារជាតិដ៏-រឹងមាំ, មានវិន័យម៉ឺងម៉ាត់, មានសមត្ថភាព, សីលធម៌ និង ភាពថ្លៃថ្នូរ, ជាកងទ័ពប្រសូតចេញពីប្រជាជន គោរពស្រឡាញ់ និង បម្រើប្រជាជន ។

៧. ជំរុញការចងសម្ព័ន្ធមេត្រីភាព រវាងអង្គភាពទ័ពដែលកំពុងឈរជើងការពារព្រំដែន ជាមួយក្រសួង-ស្ថាប័ន, ក្រុមហ៊ុនឯកជន, សង្គមស៊ីវិល និង មជ្ឈដ្ឋានផ្សេងៗទៀតក្នុងសង្គម សំដៅពង្រឹងការផ្សារភ្ជាប់រវាងប្រជាជន និង កងទ័ព ។ បង្កើនការអប់រំប្រជាជន ជាពិសេស សិស្ស-និស្សិត, យុវជន អំពីប្រវត្តិសាស្ត្រ អំពីមោទនភាពជាតិ និង អំពីករណីយកិច្ចរបស់ពលរដ្ឋ, លើកកម្ពស់ស្មារតីស្នេហាជាតិ, ប្តេជ្ញាការពារមាតុភូមិ ។

៨. ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេស ក្នុងវិស័យការពារជាតិ ដោយផ្អែកលើរដ្ឋធម្ម-នុញ្ញ, ច្បាប់ជាតិ និង ច្បាប់អន្តរជាតិ ដើម្បីពង្រីកសមត្ថភាពការពារជាតិ ពង្រឹងអធិបតេយ្យជាតិ និង លើកកម្ពស់ការចូលរួមសកម្មរបស់កម្ពុជា ក្នុងបុព្វហេតុសន្តិភាព, ស្ថិរភាព និង រីបុលភាពតំបន់ និង ពិភពលោក ។ បន្តបញ្ជូនកងកម្លាំងកម្ពុជាចូលរួម ក្នុងបេសកកម្មថែរក្សាសន្តិភាព ក្រោមឆត្រអង្គការសហប្រជាជាតិ នៅបណ្តាប្រទេស ។

ការការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម

១. ការពារសន្តិភាព, ពង្រឹងខឿនសន្តិសុខជាតិឱ្យបានរឹងមាំ ដែលមានកងកម្លាំងនគរបាលជាតិជាស្នូល និង ជាបង្អែករបស់ប្រជាជន លើមូលដ្ឋានលើកកម្ពស់ប្រសិទ្ធភាព ក្នុងការទប់ស្កាត់អំពើភេរវកម្ម, ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ជាពិសេស បទល្មើសសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម, ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ និង អំពើជួញដូរមនុស្សគ្រប់ទម្រង់, ព្រមទាំងរួមចំណែកការពារអធិបតេយ្យជាតិ, បូរណភាពទឹកដី និង បន្តជំរុញកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ដើម្បីរក្សានូវព្រំដែនសន្តិភាព, មិត្តភាព, សហ-ប្រតិបត្តិការ និង ការអភិវឌ្ឍ ព្រមទាំងប្រឆាំងរាល់សកម្មភាព ដែលលួចឆ្លៀតឱកាសប្រើប្រាស់ទឹកដីកម្ពុជា ធ្វើជាមូលដ្ឋានប្រឆាំងប្រទេសជិតខាង ។

២. រក្សាស្ថិរភាពសន្តិសុខផ្ទៃក្នុង, ធានាប្រក្រតីកម្មស្ថាប័នជាតិ, ធានាសុវត្ថិភាពជូនឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ ព្រមទាំងព្រឹត្តិការណ៍នយោបាយ ជាតិ, តំបន់ និង អន្តរជាតិ ដែលប្រព្រឹត្តធ្វើឡើងនៅកម្ពុជា, ទប់-ស្កាត់ការបង្កើតកងកម្លាំងប្រដាប់អាវុធខុសច្បាប់ ឬ ការបង្កើតតំបន់អប្បគមន៍ ព្រមទាំងប្រឆាំងរាល់ឧបាយកលសកម្មភាព នៃការប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់, ផ្ទុយពីគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ។

៣. បន្តជំរុញចលនាអនុវត្តគោលនយោបាយ «**ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព**» ដែលជាផែនទីបង្ហាញផ្លូវក្នុងការដាក់ចេញនូវវិធានការនានា ដើម្បីទប់ស្កាត់បង្ក្រាបបទល្មើសនានាឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

៤. បន្តជំរុញ និង លើកកម្ពស់ប្រសិទ្ធភាពនូវយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់, ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និង សិក្សាស្រាវជ្រាវរកវិធានការសមស្រប និង មានប្រសិទ្ធភាព ដើម្បីបង្ការ ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ក្នុងគោលបំណងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ។

៥. ពង្រឹង និង លើកកម្ពស់ការថែទាំជីវភាព, សុខភាព, ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់ទណ្ឌិត និង បន្តអនុវត្តវិធានការលើកលែងទោស និង បន្ធូរបន្ថយទោស ។ ទន្ទឹមនេះ, ជំរុញការអនុវត្តនីតិវិធីដោះលែងដោយមានលក្ខខណ្ឌចំពោះទណ្ឌិតដែលភ្ជាក់រឭក, កែប្រែខ្លួនបានល្អ ព្រមទាំងជំរុញការអនុវត្តនីតិវិធីប្រកាសទោសការងារសហគមន៍ចំពោះទណ្ឌិតដែលប្រព្រឹត្តបទល្មើសស្រាល សំដៅលើកកម្ពស់ការធ្វើសមាហរណកម្មក្នុងសង្គម និង ការចូលរួមបំពេញកាតព្វកិច្ចការងារដែលផ្តល់ផលប្រយោជន៍ដល់សង្គម ។

៦. លើកកម្ពស់សមត្ថភាពក្នុងការបំពេញតួនាទីរបស់នគរបាលប៉ុស្តិ៍រដ្ឋបាល ដោយបន្តពង្រឹងគុណធម៌, សីលធម៌, វិន័យ, សេចក្តីថ្លៃថ្នូ, ក្រមសីលធម៌, ឥរិយាបថបំពេញការងារ ក្នុងការបម្រើសេវាចាំបាច់ជូនប្រជាពលរដ្ឋ ប្រកបដោយមនសិការវិជ្ជាជីវៈ និង ភក្តីភាព ព្រមទាំងបន្ត ឧបត្ថម្ភ, គាំទ្រទាំងស្មារតី និង សម្ភារៈ លើកទឹកចិត្តដល់មន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាល និង ប្រជាការពារតាមភូមិ ដែលជាកម្លាំងនៅកៀកជាប់ជាមួយប្រជាពលរដ្ឋតាមមូលដ្ឋាន និង ជាចលករដ៏សំខាន់ ក្នុងការបំផុសចលនាប្រជាពលរដ្ឋចូលរួមអនុវត្តគោលនយោបាយ **«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»** ។

៧. ពង្រឹងការគ្រប់គ្រងការចេញ-ចូលព្រះរាជាណាចក្រកម្ពុជា, ការគ្រប់គ្រងការស្នាក់នៅ និង ប្រកបមុខរបររបស់ជនបរទេស, ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យអន្តោប្រវេសន៍ សំដៅបង្ការ និង ទប់ស្កាត់ ការ-លួចជ្រៀតចូល, ការស្នាក់នៅ និង ការប្រកបរបរធ្វើការដោយខុសច្បាប់ ។

៨. ពង្រឹងការអនុវត្តបែបបទ, នីតិវិធីក្នុងការផ្តល់ទិដ្ឋាការ និង ការអនុញ្ញាតបន្តស្នាក់នៅបណ្តោះ-អាសន្នឱ្យបានហ្មត់ចត់ ដើម្បីបង្ការ ទប់ស្កាត់ មិនឱ្យឧក្រិដ្ឋជនបរទេសណាម្នាក់យកកម្ពុជា ធ្វើជាជម្រកលាក់ខ្លួន ឬ ប្រព្រឹត្តសកម្មភាពល្មើសច្បាប់ ។

៩. សិក្សាកែសម្រួលច្បាប់ស្តីពីអន្តោប្រវេសន៍ថ្មី ឱ្យបានសមស្របតាមការវិវឌ្ឍរបស់ប្រទេសជាតិ សំដៅធានាប្រសិទ្ធភាពនៃការគ្រប់គ្រងកិច្ចការអន្តោប្រវេសន៍ ។

១០. ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ២០១៧-២០២៦ ឱ្យទទួលបានលទ្ធផលតាមការគ្រោងទុក ដោយបង្កើតឱ្យមានមជ្ឈមណ្ឌលជាតិគ្រប់គ្រងទិន្នន័យប្រជាជន និង រៀបចំដាក់ឱ្យប្រើប្រាស់លេខសម្គាល់អត្តសញ្ញាណបុគ្គល ដែលជាលេខសម្គាល់ខ្លួនពិសេស ផ្តល់ជូនប្រជាពលរដ្ឋប្រើប្រាស់ពេញមួយជីវិត ។ ជំរុញការកសាងច្បាប់ស្តីពីអត្រានុកូលដ្ឋាន, ស្ថិតិអត្រានុកូលដ្ឋាន និង អត្តសញ្ញាណកម្ម និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។ បន្តពង្រឹងប្រសិទ្ធភាពផ្តល់សេវាអត្តសញ្ញាណកម្មជូនប្រជាពលរដ្ឋ ធ្វើឱ្យសេវាកាន់តែងាយស្រួល, កាន់តែឆាប់ និង ចំណាយតិច ។

១១. បន្តជំរុញការកែទម្រង់កងកម្លាំងនគរបាលជាតិ ដោយធ្វើការអភិវឌ្ឍស្ថាប័ន និង កសាងធនធានមនុស្ស, យកចិត្តទុកដាក់ខ្ពស់ចំពោះជីវភាព និង សុខុមាលភាពកងកម្លាំងនគរបាលជាតិ, និង ជំរុញការអនុវត្តគោលនយោបាយ ចំពោះមន្ត្រីនគរបាលចូលនិវត្តន៍ បាត់បង់សមត្ថភាព ពលី ពិការ ដោយសារបុព្វហេតុសន្តិសុខជាតិ ។

១២. បន្តពង្រឹងពង្រីកទំនាក់ទំនងសហប្រតិបត្តិការជាលក្ខណៈទ្វេភាគី ពហុភាគី ក្នុងក្របខ័ណ្ឌតំបន់

និង អន្តរជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋឆ្លងដែន ដែលមានអង្គការចាត់តាំងគ្រប់ប្រភេទ ជាអាទិ៍ បទល្មើសគ្រឿងញៀន, អំពើជួញដូរមនុស្ស, បទល្មើសបច្ចេកវិទ្យាព័ត៌មាន ។ល។ ជាមួយនេះ បន្តពង្រឹងការកសាងភូមិឃុំសតាមព្រំដែន ។

ការបំបាត់គ្រាប់មីន និង គ្រាប់មិនទាន់ផ្ទុះ

១. ជំរុញការអនុវត្ត «**គម្រោងសម្តេចតេជោសម្រាប់សកម្មភាពមីន**» ក្រោមមូលបទ «**ផ្តល់ដីសុវត្ថិភាព បង្កើតស្នាមញញឹម**» ដើម្បីបំបាត់គ្រាប់មីនឱ្យអស់ត្រឹមឆ្នាំ ២០២៥ ។

២. ជំរុញការអនុវត្តគម្រោងមូលនិធិកម្ពុជាគ្មានគ្រាប់មីន ឆ្នាំ ២០២៥ និង ខិតខំកៀរគរជំនួយ និងសហការជាមួយដៃគូអភិវឌ្ឍនៃវិស័យសកម្មភាពមីន ដើម្បីអនុវត្តគម្រោងបោសសម្អាតមីនតាមផែនការយុទ្ធ-សាស្ត្រសកម្មភាពមីន ឆ្នាំ ២០១៨-២០២៥ ។

១៨. ការពង្រឹង ពង្រីកចំណងមិត្តភាព និង កិច្ចសហប្រតិបត្តិការ ជាមួយបណ្តាប្រទេស, ជំរុញសមាហរណ-កម្មកម្ពុជាក្នុង តំបន់ និង ពិភពលោក

១. បន្តការពារផលប្រយោជន៍ស្នូលរបស់កម្ពុជាដោយគោរព និង ការពារយ៉ាងម៉ឺងម៉ាត់នូវរដ្ឋធម្មនុញ្ញ និង បន្តអនុវត្តការងារការទូតបុរេសកម្ម ដើម្បីទទួលបាននូវការគោរពដល់អធិបតេយ្យ, បូរណភាពទឹកដី, ឯករាជ្យ និង ការទទួលស្គាល់នូវបំណងប្រាថ្នា និង ភាពចាំបាច់ ក្នុងការរក្សាសន្តិភាព, ស្ថិរភាព និង ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ។ ប្រមូល និង ប្រើប្រាស់កិច្ចប្រឹងប្រែងរួមរបស់រាជរដ្ឋាភិបាល, ស្ថាប័ននីតិប្ញញ្ញត្តិ និង ស្ថាប័នអង្គការមហាជន ដើម្បីប្រឆាំងនឹងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង ការពារផលប្រយោជន៍ពលរដ្ឋកម្ពុជានៅក្រៅប្រទេស ការពារកិត្តិយស និង កិត្តិនាមប្រទេសជាតិ ។

២. បន្តអនុវត្តនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់ ការគោរពនិយាម គោលបំណង និង គោលការណ៍នានា នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និង អាស៊ាន ។ បន្តអនុវត្តការទូតទន់ភ្លន់, ប៉ុន្តែម៉ឺងម៉ាត់, បត់បែន និង ច្នៃងច្នៃង ស្របតាមការផ្លាស់ប្តូរផ្នែកយុទ្ធសាស្ត្រ, ភូមិសាស្ត្រនយោបាយតំបន់ និង ពិភព-លោក ។ ស្តារឡើងវិញនូវទំនាក់ទំនងប្រពៃណីជាមួយប្រទេសជាមិត្តចាស់, កសាងទំនាក់ទំនងមិត្តភាព, សហ-ប្រតិបត្តិការជាមួយមិត្តថ្មី បន្ថែមការយកចិត្តទុកដាក់ទៅកាន់បណ្តាប្រទេសក្នុងតំបន់អាមេរិកណ្តាល, អាមេរិក-ឡាទីន, អាហ្វ្រិក, មជ្ឈិមបូព៌ា, អាស៊ីកណ្តាល ។ល។ ថែទាំ និង ពង្រឹង ពង្រីកទំនាក់ទំនងជាមួយប្រទេសជាមិត្តជិតខាង និង ក្នុងតំបន់ ។

៣. រួមចំណែកកាន់តែសកម្មក្នុងកិច្ចប្រឹងប្រែងតំបន់ និង សកលលោក ដើម្បីថែរក្សា និង ពង្រឹងសន្តិភាព, ស្ថិរភាព និង វិបុលភាព បន្តប្រយុទ្ធប្រឆាំងនឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ, ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ, អំពើភេរវកម្ម, ជំងឺឆ្លងនានា ។ល។ បន្តរួមចំណែកក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និង ការបោសសម្អាតមីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះ ។ រួមចំណែកក្នុងការពង្រឹងពហុ-ភាគីនិយម ចូលរួមយ៉ាងសកម្ម ក្នុងវេទិកាតំបន់ និង អន្តរជាតិ ។ ប្រើប្រាស់សម្ទុះវិជ្ជមាន ដែលបានមកពីជោគ-ជ័យនៃការធ្វើប្រធានអាស៊ាន ដើម្បីពង្រឹងតួនាទីរបស់កម្ពុជាក្នុងសហគមន៍នេះផង និង ក្នុងឆាកអន្តរជាតិផង តាមរយៈ តួនាទីកាន់តែសំខាន់របស់អាស៊ានក្នុងកិច្ចសន្ទនា, ការពិគ្រោះយោបល់ និង ការសម្របសម្រួល ។ បន្តដើរតួនាទីជាអ្នកសម្រួលការចរចា ការស្វែងរកច្រកសន្ទនា និង ដោះស្រាយបញ្ហានានាតាមផ្លូវនយោបាយ ក្នុង

ហាន:ជាប្រទេស ដែលមិនស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួនអ្វីក្រៅពីសន្តិភាព ស្ថិរភាព និង ការផ្សះផ្សា ។

៤. តែចំណងខាងសេដ្ឋកិច្ចជាមួយដៃគូចាស់ និង ថ្មី, ជំរុញការទាក់ទាញវិនិយោគ, ស្វែងរកទីផ្សារ សម្រាប់ផលិតផល និង គាំទ្រដល់ឧស្សាហកម្មនាំចេញ, លើកស្ទួយវិស័យទេសចរណ៍ និង វប្បធម៌ខ្មែរ ដោយផ្អែកលើប្រៀបខ្លាំងនៃសក្តានុពលសេដ្ឋកិច្ច និង បេតិកភណ្ឌប្រវត្តិសាស្ត្រសម័យអង្គររបស់យើង, និង ជំរុញអនុវត្តកិច្ច-ព្រមព្រៀងពាណិជ្ជកម្មសេរី និង យន្តការសហប្រតិបត្តិការទ្វេភាគី និង ពហុភាគី ដើម្បីគាំទ្រផលិតកម្ម និងកំណើនសេដ្ឋកិច្ច ក្នុងស្រុក ។ បន្តខិតខំស្វែងរកធនធានហិរញ្ញវត្ថុពីប្រទេសដៃគូ ដើម្បីចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធ, ទាំងផ្នែកទន់ និង រឹង និង ស្វែងរកអាហារូបករណ៍ ដើម្បីអភិវឌ្ឍធនធានមនុស្ស ដែលជាកត្តាចាំបាច់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និង បង្កើនចំណូល សម្រាប់ប្រជាពលរដ្ឋ ខណៈដែលកម្ពុជាកំពុងបោះជំហានឆ្ពោះទៅរកហាន:ជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ ខាងមុខ ។

៥. បន្តយកចិត្តទុកដាក់ដល់ការបណ្តុះបណ្តាលធនធានមនុស្សខាងវិស័យការទូត ដែលត្រូវការពេល, មធ្យោបាយ, ធនធានបញ្ញា និង ការលើកទឹកចិត្តសមស្រប ដើម្បីរក្សាទុក និង ទាក់ទាញអ្នកមានសមត្ថភាព និង ទេពកោសល្យ ។

IV. កម្មវិធីគោលនយោបាយអាទិភាព ទាំង ៦ សម្រាប់ចាប់ផ្តើមអនុវត្ត នៅក្នុងឆ្នាំ ២០២៣

បន្ថែមលើយុទ្ធសាស្ត្រអាទិភាពដែលបានដាក់ចេញតាមផ្នែកនីមួយៗនេះ, រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវកម្មវិធីគោលនយោបាយអាទិភាព ចំនួន ៦ សម្រាប់ចាប់ផ្តើមអនុវត្ត នៅក្នុងឆ្នាំ ២០២៣ ដូចខាងក្រោម៖

កម្មវិធីទី ១ : ការផ្តល់ការថែទាំសុខភាពឆ្លោះទៅកម្មវិធីគ្របដណ្តប់សុខភាពជាសកល ដោយចាប់ផ្តើមពី : ១). ការផ្តល់សេវាថែទាំសុខភាពជូនគ្រួសារងាយរងហានិភ័យប្រមាណជាង ៤៥ ម៉ឺនគ្រួសារ, ស្មើនឹងសមាជិកសរុបជាង ១,៥ លាននាក់ តាមរយៈ ការប្រើប្រាស់មូលនិធិសមធម៌សុខាភិបាល; និង ២). ការពង្រីករបបថែទាំសុខភាពរបស់របបសន្តិសុខសង្គម (ប.ស.ស.), ទាំងសម្រាប់កម្មករ-និយោជិត និង សម្រាប់មន្ត្រីសាធារណៈ ដែលគ្របដណ្តប់បន្ថែមដល់សមាជិកគ្រួសារ និង អ្នកក្នុងបន្ទុកពួកគាត់ ប្រមាណជាង ៣ លាននាក់ តាមគោលការណ៍ស្ម័គ្រចិត្ត ។ ជាសរុប, គម្រោងទាំងពីរនេះ នឹងធ្វើឱ្យប្រជាជនប្រមាណ ៧,៤ លាននាក់ មានលទ្ធភាពទទួលបាននូវ ប.ស.ស. ផ្នែកសេវាថែទាំសុខភាព។

កម្មវិធីទី ២ : ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង បច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ដែលមានចំនួនប្រមាណជាង ១,៥ លាននាក់ នៅតាមបណ្តាគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនានារបស់រដ្ឋ ក្នុងកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត ១ ដោយមិនបង់ថ្លៃសិក្សា និង ទទួលបាននូវប្រាក់ឧបត្ថម្ភប្រចាំខែ ។

កម្មវិធីទី ៣ : ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម សម្រាប់គ្រួសារក្រីក្រ, ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យ នៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និង គ្រាមានគ្រោះអាសន្ន ដើម្បីជួយទ្រទ្រង់ និង ផ្តល់ការគាំពារទាន់ពេល និង ក្នុងលក្ខណៈជាប្រព័ន្ធជូនប្រជាពលរដ្ឋ, ជាពិសេស គ្រួសារក្រីក្រ និង ងាយរងគ្រោះ និង គ្រួសារងាយរងហានិភ័យ, ទៅតាមស្ថានភាពជាក់ស្តែងនៃវិបត្តិ ឬ គ្រោះអាសន្ន នៅតាមគ្រប់ទីតាំងភូមិសាស្ត្រទូទាំងប្រទេស ដែលនឹងគ្របដណ្តប់លើប្រជាជនសរុបប្រមាណ ៤,៣ លាននាក់ ។

កម្មវិធីទី ៤ : ការដាក់ចេញ និង ការជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និង អាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ តាមរយៈ ១). ការផ្តល់នូវការគាំពារ និង ការបង្កើតនូវបរិយាកាសអំណោយផល សម្រាប់ធ្វើធុរកិច្ច និង ពាណិជ្ជកម្ម ព្រមជាមួយនឹងការផ្តល់នូវការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈដល់ក្រុមហ៊ុន, សហគ្រាសធុនមីក្រូ តូច និង មធ្យម; និង ២). ការផ្តល់ការគាំពារសង្គម ដល់បុគ្គលស្វ័យនិយោជន៍ ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយផ្តោតការយកចិត្តទុកដាក់ជាបឋម លើការផ្តល់សេវាថែទាំសុខភាព នៅក្រោមមូលនិធិសមធម៌សុខាភិបាល ។

កម្មវិធីទី ៥ : ការដាក់ចេញនូវយន្តការសម្របសម្រួល និង កម្មវិធីហិរញ្ញប្បទាន សំដៅលើស្នូលផលិតកម្ម, រកទីផ្សារ និង រក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ តាមរយៈ ការដាក់ចេញកញ្ចប់ថវិកាជាក់លាក់ ដោយចាប់ផ្តើមពីចំនួន ១០០ លានដុល្លារអាមេរិក និង អាចវិភាជថវិកាបន្ថែម, ប្រសិនបើមានតម្រូវការចាំបាច់, ដើម្បីធ្វើអន្តរាគមន៍ឱ្យបានទាន់ពេលក្នុងការទិញកសិផលពីប្រជាកសិករ ជាមួយនឹងគោលដៅរក្សាស្ថិរភាពថ្លៃនៅរាល់រដូវប្រមូលផល, ជាពិសេស លើផលិតផលកសិកម្មមួយចំនួន ជាអាទិ៍ ស្រូវ ស្វាយកែវរមៀត មៀនប៉ែលិន ស្វាយចាន់ទី ដំឡូង ពោត និង ផលិតផលផ្សេងទៀត តាមការចាំបាច់ ។

កម្មវិធីទី ៦ : ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ ដែលមានសកម្មភាពកសិកម្ម នៅទូទាំងប្រទេស ដើម្បីជំរុញការលើកកម្ពស់ផលិតភាពកសិកម្ម និង ជួយដល់គ្រួសារកសិករ ក្នុងការ-លើកស្ទួយផលិតផលកសិកម្មរបស់ខ្លួន ។ រាជរដ្ឋាភិបាល នីតិកាលទី ៧ នឹងយកចិត្តទុកដាក់ផងដែរ ទៅលើការរៀបចំឱ្យមានសមាគមកសិករនៅតាមទីជនបទ ដើម្បីរក្សាកម្លាំងរបស់កសិករ ក្នុងការផលិត ក៏ដូចជា ការតម្លៃជាមួយអ្នកទទួលទិញ ។

សន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជាដាក់កម្មវិធីនយោបាយនេះ ជូនរដ្ឋសភា, និង តាមរយៈរដ្ឋសភា, ជូនជនរួមជាតិ និង សាធារណៈមតិទូទៅ សំដៅបង្ហាញឱ្យឃើញ និង បញ្ជាក់ច្បាស់អំពីគោលបំណង, ឧត្តមគតិស្នេហាជាតិដ៏បរិសុទ្ធ និង ការប្តេជ្ញាឥតរាថយរបស់ខ្លួន ចំពោះការពុះពារ និង កិច្ចខិតខំប្រឹងប្រែងបម្រើជាតិ និង ប្រជាជនក្នុងគ្រប់កាលៈទេសៈ ព្រមទាំងបង្ហាញច្បាស់ អំពីចក្ខុវិស័យ និង គោលនយោបាយ លើគ្រប់វិស័យ ដើម្បីបន្តការពារ និង កសាងមាតុភូមិ ឆ្ពោះទៅរកអនាគតមួយដ៏រុងរឿង, ពិសេសប្រែក្លាយកម្ពុជា ជាអារ្យប្រទេសជឿនលឿនមួយ ក្នុងតំបន់ ស្របតាមធនៈ និង បំណងប្រាថ្នារបស់ប្រជាជន ។

រាជរដ្ឋាភិបាល សូមរដ្ឋសភាផ្តល់នូវការគាំទ្រ និង តាមរយៈរដ្ឋសភា, សូមជនរួមជាតិទាំងអស់ ចូលរួមអនុវត្តយ៉ាងសកម្មនូវកម្មវិធីនយោបាយនេះ ឱ្យទៅជាចលនារួមដ៏ខ្លាំងក្លា ដោយប្រកាន់ក្តាប់នូវគោលការណ៍សាមគ្គីប្រជាជាតិទាំងមូល ប្រកបដោយជវភាព សំដៅសម្រេចឱ្យបានជោគជ័យជាផ្លែផ្កាសម្រាប់ឧត្តមប្រយោជន៍របស់ជាតិ ។ ដើម្បីគោលដៅនេះ, រាជរដ្ឋាភិបាល នឹងដាក់ចេញ ព្រមទាំងនឹងជំរុញអនុវត្តឱ្យបានជោគជ័យនូវ «**យុទ្ធសាស្ត្របញ្ចកោណ-ជំណាក់កាលទី ១ ឆ្នាំ ២០២៣-២០២៨**» **ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព : កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** ដែលជា «**រចៀម-ទារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច**» នៃ «**កម្មវិធីនយោបាយ**» នេះ សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា ។

រាជរដ្ឋាភិបាលកម្ពុជា សូមសម្តែងនូវសេចក្តីគោរព និង ការដឹងគុណដ៏ជ្រាលជ្រៅបំផុត ជូនជនរួមជាតិនៅគ្រប់ទិសទី ដែលបានឃើញយ៉ាងច្បាស់នូវសច្ចភាពនៃការរស់ឡើងវិញ និង ការរីកចម្រើនរបស់ប្រទេសជាតិ ដែលជាមូលដ្ឋាននៃដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ហើយបានផ្តល់ជំនឿ និង ការគាំទ្រដ៏ធំធេងចំពោះរាជ-រដ្ឋាភិបាលនៅគ្រប់ជំណាក់កាល ។ ដោយផ្អែកលើមូលដ្ឋាននៃការគាំទ្ររបស់ប្រជាជន, ធនៈដ៏មោះមុត និងទេពកោសល្យ ព្រមទាំងផ្អែកលើបទពិសោធន៍ និងសមត្ថភាព ដែលយើងមាន, រាជរដ្ឋាភិបាល ប្តេជ្ញាប្រមូលផ្តុំកម្លាំង, ប្រឹងប្រែងជំរុញអនុវត្តបេសកកម្មជាប្រវត្តិសាស្ត្រ ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា ឱ្យបានសម្រេចជោគជ័យដ៏ត្រចះត្រចង់ លើមាគ៌ានៃសុខសន្តិភាពដ៏រឹងមាំ និង ការអភិវឌ្ឍដ៏រស់រវើក, ឆ្ពោះទៅកាន់វឌ្ឍនភាព, វិបុលភាព និង ភាពថ្កើងថ្កាន ប្រកបដោយគុណធម៌ និង ភាពជឿជាក់, ជាមួយនឹងមនសិការទទួលខុសត្រូវខ្ពស់, សាមគ្គី-ភាព និង ឯកភាពផ្ទៃក្នុង យ៉ាងរឹងមាំ សំដៅបង្កើតឡើងនូវសមិទ្ធផលថ្មីៗទៀត លើគ្រប់វិស័យ និង កាន់តែធំធេងជូនជាតិ និង ប្រជាជន ។